**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ២១)
ភាគីដាក់ឯកសារ៖ មេធាវីការពារក្តីរបស់ មាស មុត
ដាក់ជូន៖ អង្គបុរេជំនុំជម្រះ
ភាសាដើម៖ អង់គ្លេស
កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 16-Jun-2015, 14:24
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**
ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖ សម្ងាត់/Confidential
ចំណាត់ថ្នាក់ប្រភេទឯកសារ៖
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖
ឈ្មោះមន្ត្រីកត់ត្រា៖
ហត្ថលេខា៖

---

**បណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត HARMON ដែលសម្រេចដាក់ មាស មុត ឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ***

---

**ដាក់ដោយ៖**

**សហមេធាវី**
អាង ឧត្តម
Michael G. KARNAVAS

**ផ្ញើជូន៖**

**ចៅក្រមអង្គបុរេជំនុំជម្រះ៖**
ចៅក្រម ប្រាក់ គឹមសាន
ចៅក្រម ន័យ ថុល
ចៅក្រម ហួត វុទ្ធី
ចៅក្រម Olivier BEAUVALLET
ចៅក្រមបម្រុង Steven J. BWANA
ចៅក្រមបម្រុង ប៉ែន ពេជ្រសាលី

០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ២១)

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**ភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

# មាតិកា

**I. បញ្ហាដែលបានលើកឡើង** ........ 1

**II. សាវតារ** ........ 2

**III. បញ្ហាបឋម** ........ 7

ក. ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ ........ 7

ខ. បទដ្ឋាននៃការពិនិត្យឡើងវិញ ........ 11

**IV. ច្បាប់ និង ឧទ្ធរណ៍** ........ 12

ក. សហចៅក្រមស៊ើបអង្កេត Harmon បានបំពេញកិច្ច *ហួសពីសមត្ថកិច្ច* និង មានកំហុសក្នុងការចេញដីកាសម្រេចរងការជំទាស់ដោយឯកតោភាគី ........ 12

ខ. ដើម្បីជា *ទឡ្ហីករណ៍* (arguendo) សន្មតថា សហចៅក្រមស៊ើបអង្កេត Harmon អាចចេញដីកាសម្រេចរងការជំទាស់នេះដោយឯកតោភាគីបាន គាត់បានបំពេញកិច្ច *ហួសពីសមត្ថកិច្ច* និង មានកំហុសនៅក្នុងការអនុវត្តវិធាន ៥៧ និង វិធាននីតិវិធីកម្ពុជា និង អន្តរជាតិ នៅពេលគាត់សម្រេចដាក់លោក មាស មុត ឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ........ 18

លោក មាស មុត តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្តី”) អនុលោមតាមវិធាន ៧៤(៣)(ក) និង វិធាន ២១ នៃវិធានផ្ទៃក្នុង អ.វ.ត.ក. (“វិធានផ្ទៃក្នុង”) តាមរយៈនេះ ប្តឹងឧទ្ធរណ៍នឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត Harmon ដែល ដាក់ មាស មុត ឲ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* (“ដីកាសម្រេចរងការជំទាស់”) ដែលក្នុងនោះសហចៅក្រមស៊ើបអង្កេត Harmon ដាក់លោក មាស មុត ឲ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* ដោយអះអាងថានេះគឺជាវិធីតែមួយគត់ ដើម្បីធានាឲ្យមានកិច្ចដំណើរការនីតិវិធីប្រកបដោយភាពយុត្តិធម៌ និង ភាពឆាប់រហ័ស[1]។ បណ្តឹងឧទ្ធរណ៍នេះត្រូវបានធ្វើឡើងជាចាំបាច់ ពីព្រោះសហចៅក្រមស៊ើបអង្កេត Harmon បានយល់ខុសនូវវិធាន និង វិធាននីតិវិធីកម្ពុជា និង អន្តរជាតិ ដើម្បីឈានទៅរកលទ្ធផលមួយដែលត្រូវបានកំណត់ជាមុនគឺ៖ ដាក់លោក មាស មុត ឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ដើម្បីអាចឲ្យកិច្ចស៊ើបសួរប្រព្រឹត្តទៅមុខបាន។ គាត់បានបំពេញកិច្ច*ហួសពីសមត្ថកិច្ច (ultra vires)* និង បានរំលោភបំពានលើសិទ្ធិរបស់លោក មាស មុត ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ជាពិសេស សិទ្ធិរបស់គាត់នៅក្នុងការបង្ហាញខ្លួននៅឯការបង្ហាញខ្លួនលើកដំបូងដែលមានសុពលភាព នៅចំពោះមុខសហចៅក្រមស៊ើបអង្កេតទាំងពីរនាក់។ មេធាវីការពារក្តីដាក់បណ្តឹងឧទ្ធរណ៍នេះជាឯកសារសាធារណៈ។ បណ្តឹងឧទ្ធរណ៍នេះមិនបានយោងព័ត៌មានណាមួយដែលទាមទារឲ្យរក្សាការសម្ងាត់ឡើយ។ យើងខ្ញុំស្នើសុំឲ្យមានសវនាការមួយ សួរដេញដោលផ្ទាល់មាត់ និង ជាសាធារណៈ។

## I. បញ្ហាដែលបានលើកឡើង

### *សំណួរ មួយ*

*ក្របខ័ណ្ឌច្បាប់នៅ អ.វ.ត.ក. ចែងថា សហចៅក្រមស៊ើបអង្កេតត្រូវបើកកិច្ចស៊ើបសួររួមគ្នា ដែលរួមទាំង ការដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការពិនិត្យតាមវិធាន ៥៧ ។ កិច្ចព្រមព្រៀង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. និង វិធានផ្ទៃក្នុង មិនបានចែងថា ជនត្រូវចោទអាចត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់នោះទេ។ តើសហចៅក្រមស៊ើបអង្កេត Harmon បានបំពេញកិច្ច* ហួសពីសមត្ថកិច្ច (ultra vires) *និង មានកំហុសដែរឬទេ នៅក្នុងការចេញដីកាសម្រេចរងការជំទាស់នេះដោយឯកតោភាគី ដោយគ្មានហត្ថលេខារបស់សហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង នោះ?*

---

[1] ដីកាសម្រេចដាក់ មាស មុត ឲ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* ចុះថ្ងៃទី ៣ ខែមីនា ឆ្នាំ ២០១៥ ឯកសារ D128 កថាខណ្ឌ ៧២។

***ចម្លើយ***

*ពិតជាបានបំពេញកិច្ច ហួសពីសមត្ថកិច្ច និង មានកំហុសមែនពិតមែន ពីព្រោះ តាមអត្ថន័យធម្មតា នៃមាត្រា ៥(៤) នៃកិច្ចព្រមព្រៀង និង មាត្រា ២៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. សហចៅក្រម ស៊ើបអង្កេត Harmon មិនអាចដាក់លោក មាស មុត ឱ្យស្ថិតនៅក្រោមការពិនិត្យដោយឯកតោភាគីបានទេ។*

***សំណួរ ពីរ***

*អ.វ.ត.ក. អនុវត្តតាមប្រព័ន្ធច្បាប់ស៊ីវិល (civil law) ដែលអនុលោមតាមប្រព័ន្ធច្បាប់នេះសហចៅក្រមស៊ើបអង្កេតមិនអាចបំពេញកិច្ចណាមួយ ដែលមិនមានចែងនៅក្នុងវិធានឡើយ។ វិធាន ៥៧ និង វិធាននីតិវិធីកម្ពុជា និង អន្តរជាតិដែលពាក់ព័ន្ធ តម្រូវឱ្យជនត្រូវចោទមកបង្ហាញខ្លួនលើកដំបូងដោយផ្ទាល់ ដើម្បីឱ្យសហចៅក្រមស៊ើបអង្កេតអាចធ្វើការសួរចម្លើយ ផ្តល់ដំណឹងដល់ជនត្រូវចោទពីបទចោទប្រកាន់នានាដែលកំពុងត្រូវបានស៊ើបអង្កេត និង ផ្តល់ដំណឹងដល់ពួកគេអំពី សិទ្ធិទាំងឡាយរបស់ខ្លួន ដែលទាក់ទងនឹងកិច្ចស៊ើបសួរ។ តើសហចៅក្រមស៊ើបអង្កេត Harmon បានបំពេញកិច្ច ហួសពីសមត្ថកិច្ច និង មានកំហុសដែរឬទេ ក្នុងការអនុវត្តវិធាន ៥៧ និង វិធាននីតិវិធីកម្ពុជា និង អន្តរជាតិ នៅពេលគាត់សម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យ* ដោយកំបាំងមុខ*?*

***ចម្លើយ***

*ពិតជាបានបំពេញកិច្ច ហួសពីសមត្ថកិច្ច និង មានកំហុសមែន ពីព្រោះតាមអត្ថន័យធម្មតា និង បទប្បញ្ញត្តិនៃវិធាន ៥៧ និង ការបកស្រាយ សមហេតុផលនូវវិធាននីតិវិធីកម្ពុជា និង អន្តរជាតិ ដែលពាក់ព័ន្ធ ជនត្រូវចោទត្រូវតែមានវត្តមាននៅក្នុងការបង្ហាញខ្លួនលើកដំបូង និង មិនអាចត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យ* ដោយកំបាំងមុខ *ឡើយ។*

## II. សាវតារ

១. នៅថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ ២០០៩ ការស៊ើបអង្កេតតាមផ្លូវតុលាការទៅលើលោក មាស មុត ត្រូវបានចាប់ផ្តើម ដោយផ្អែកលើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីររបស់ការិយាល័យសហព្រះរាជអាជ្ញា ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០០៨ ទាក់ទងទៅនឹងកងទ័ពបដិវត្តន៍កម្ពុជា[2]។

២. នៅថ្ងៃទី ៧ និង ២២ ខែកុម្ភៈ ឆ្នាំ ២០១៣ និង ម្តងទៀត នៅថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០១៤ សហ

[2] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីររបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងកងទ័ពបដិវត្តន៍កម្ពុជា ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ D1។

ចៅក្រមស៊ើបអង្កេត បានដាក់បញ្ជូនឯកសារស្ដីពីការខ្វែងយោបល់គ្នា។ សហចៅក្រមស៊ើបអង្កេត Harmon បានផ្ដល់ដំណឹងដល់មេធាវីការពារក្ដីថា យ៉ាងហោចណាស់ មានការខ្វែងយោបល់គ្នាដំបូងចំនួនពីរ មិនត្រូវបានបញ្ជូនទៅអង្គបុរេជំនុំជម្រះ អនុលោមតាមវិធាន ៧២ ស្ដីពីនីតិវិធីនៃការដោះស្រាយការខ្វែងយោបល់គ្នា[3]។

៣. នៅថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេត Harmon បានកោះហៅលោក មាស មុត និង សហមេធាវីរបស់គាត់មកបង្ហាញខ្លួនលើកដំបូង នៅថ្ងៃទី ៨ ខែធ្នូ ឆ្នាំ ២០១៤[4]។ ដីកាកោះហៅលោក មាស មុត បានថ្លែងថា "ប្រសិនបើ មាស មុត មិនមកបង្ហាញខ្លួនតាមកាលបរិច្ឆេទដូចបានបញ្ជាក់ខាងលើទេ វិធានការបន្ថែមទៀត ដោយអនុលោមតាមវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក. នឹងត្រូវយកមកពិចារណា"[5]។

៤. នៅថ្ងៃទី ២ ខែធ្នូ ឆ្នាំ ២០១៤ មេធាវីការពារក្ដីបានជួបជាមួយលោក មាស មុត ដើម្បីពិភាក្សាពីដីកាកោះនោះ។ លោក មាស មុត មិនបានចាត់ទុកថា ដីកាកោះនោះមានសុពលភាពទេ ដោយសារតែសហចៅក្រមស៊ើបអង្កេត Harmon បានចេញដីកានោះតែម្នាក់ឯង។ មេធាវីការពារក្ដីបានរៀបចំសេចក្ដីជូនដំណឹងស្ដីពីការមិនទទួលស្គាល់ដីកាកោះ ទៅតាមការយល់ឃើញនេះ សម្រាប់លោក មាស មុត[6]។ សេចក្ដីជូនដំណឹងនេះត្រូវបានដាក់បញ្ជូននៅថ្ងៃបន្ទាប់ គឺថ្ងៃទី ៣ ខែធ្នូ ឆ្នាំ ២០១៤។

៥. នៅថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេត Harmon បានចេញដីកាបង្គាប់ឲ្យនាំខ្លួន អនុលោមតាមវិធាន ៤២ ដោយបង្គាប់ឲ្យនគរបាលយុត្តិធម៌នាំខ្លួនលោក មាស មុត មកចំពោះមុខខ្លួន សម្រាប់ការបង្ហាញខ្លួនលើកដំបូង[7]។

---

[3] *សូមមើល* លិខិតរបស់សហចៅក្រមស៊ើបអង្កេត Harmon ផ្ញើទៅមេធាវីការពារក្ដី *សំណើសុំព័ត៌មានទាក់ទងនឹងករណីខ្វែងយោបល់គ្នាដែលបានកត់ត្រានៅថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៣ និង ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣* ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០១៤ ឯកសារ D82/3/2។

[4] ដីកាកោះឲ្យបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ A66។ កំណត់ហេតុស្ដីពីការប្រគល់ដីកាកោះ ចុះថ្ងៃទី ៥ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ A66/1។ ដីកាកោះហៅមេធាវី ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ A67។

[5] ដីកាកោះឲ្យបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ A66។

[6] *សូមមើល* សេចក្ដីជូនដំណឹងទាក់ទងនឹងសេចក្ដីសម្រេចចិត្តរបស់លោក មាស មុត មិនទទួលស្គាល់ដីកាកោះ ចុះថ្ងៃទី ៣ ខែធ្នូ ឆ្នាំ ២០១៤ ("សេចក្ដីសម្រេចចិត្តរបស់ មាស មុត ពាក់ព័ន្ធនឹងដីកាកោះ") ឯកសារ A67/1។ សេចក្ដីជូនដំណឹងស្ដីពីការមិនទទួលស្គាល់ដីកាកោះ ចុះថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៤ ("សេចក្ដីជូនដំណឹងរបស់ មាស មុត") ឯកសារ A67/1.1។

[7] ដីកាបង្គាប់ឲ្យនាំខ្លួន ចុះថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ C1 ទំព័រ ៣។ កថាខណ្ឌ ២១ នៃដីកាសម្រេចរងការជំទាស់។

៦. នៅថ្ងៃទី ១២ខែ ធ្នូ ឆ្នាំ ២០១៤ ដីកាបង្គាប់ឲ្យនាំខ្លួននោះ ត្រូវបានប្រគល់ជូននគរបាលយុត្តិធម៌[8]។

៧. នៅថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ២០១៤ ដោយមិនបានដឹងថាមានដីកាបង្គាប់ឲ្យនាំខ្លួន មេធាវីការពារក្តីបាន ដាក់ពាក្យសុំមួយទៅសហចៅក្រមស៊ើបអង្កេត ដែលស្នើឲ្យសហចៅក្រមស៊ើបអង្កេតប្តឹងទៅ អង្គបុរេជំនុំជម្រះឲ្យទទួលពិនិត្យ និង ចាត់ការលើសំណើសុំមោឃភាពដីកាកោះនោះ។ មេធាវី ការពារក្តីបានលើកទឡ្ហីករណ៍ថា ដីកាកោះមានវិការៈខាងនីតិវិធី ដោយសារតែត្រូវបានចេញដោយ សហចៅក្រមស៊ើបអង្កេត Harmon តែម្នាក់ឯង[9]។

៨. នៅថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេត Harmon បានចេញដីកាសម្រេចមួយ បដិសេធមិនប្តឹងឲ្យអង្គបុរេជំនុំជម្រះទទួលពិនិត្យ និង ចាត់ការលើសំណើសុំមោឃភាពដីកាកោះ ដោយយល់ឃើញថា វិធាន ៧៦(២) អនុញ្ញាតឲ្យត្រឹមតែ *ភាគី* ប៉ុណ្ណោះ ដាក់ពាក្យសុំមោឃភាព និង ថា ជនសង្ស័យមិនមែនជាភាគីនោះទេ[10]។

៩. នៅថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០១៤ ដដែល បុគ្គលិកពីរនាក់នៃការិយាល័យសហចៅក្រមស៊ើបអង្កេត បានជួបជាមួយអ្នកតំណាងនគរបាលយុត្តិធម៌ ដើម្បីពិភាក្សាពីការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួន[11]។ អ្នកតំណាងនគរបាលយុត្តិធម៌មិនអាចនិយាយបានទេថា តើពេលណាទើបអនុវត្តដីកាបង្គាប់ឲ្យនាំ ខ្លួននេះ ដោយថ្លែងថា សេចក្តីសម្រេចចុងក្រោយទៅលើការអនុវត្តដីកានេះ គឺជាការសម្រេចរបស់ គណៈកម្មការសន្តិសុខប្រចាំ អ.វ.ត.ក. (“ECSC”)[12]។

១០. នៅថ្ងៃទី ៣០ ខែមករា ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេត Harmon បានផ្ញើលិខិតទៅប្រធាន គណៈកម្មការសន្តិសុខប្រចាំ អ.វ.ត.ក. ដែលថ្លែងថា ប្រសិនបើលោក មាស មុត ខកខានមិនមក បង្ហាញខ្លួននៅ អ.វ.ត.ក. ឬ ក៏មិនត្រូវបាននាំខ្លួននៅមុនថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ២០១៥ ទេ គាត់នឹង

---

[8] កថាខណ្ឌ ២១ នៃដីកាសម្រេចរងការជំទាស់។

[9] ពាក្យសុំរបស់ មាស មុត សុំប្តឹងអង្គបុរេជំនុំជម្រះឲ្យទទួលពិនិត្យ និង ចាត់ការលើសំណើសុំមោឃភាពដីកាកោះឲ្យបង្ហាញខ្លួន បឋម ចុះថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ A77។

[10] ដីកាសម្រេចលើពាក្យសុំរបស់ មាស មុត សុំប្តឹងអង្គបុរេជំនុំជម្រះ ឲ្យទទួលពិនិត្យ និង ចាត់ការលើសំណើសុំមោឃភាពដីកា កោះឲ្យបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ A77/1 កថាខណ្ឌ ១៣។

[11] *សូមមើល* កថាខណ្ឌ ២៤ នៃដីកាសម្រេចរងការជំទាស់។

[12] *ដូចខាងលើ*។

សម្រេចដាក់លោក មាស មុត ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ*[13]។

១១. នៅថ្ងៃទី ៣ ខែមីនា ឆ្នាំ ២០១៥ នៅវេលាម៉ោង ៤:៣០ នាទីរសៀល ដោយសារថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ២០១៥ បានកន្លងផុតទៅ ដោយគ្មានការបង្ហាញខ្លួនរបស់លោក មាស មុត នៅចំពោះមុខ អ.វ.ត.ក. ឬ ដោយឥតមានការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួនដោយនគរបាលយុត្តិធម៌ សហចៅក្រម ស៊ើបអង្កេត Harmon បានចេញដីកាសម្រេចរងការជំទាស់នេះ និង អមមកជាមួយនូវការផ្ដល់ដំណឹងអំពីបទចោទប្រកាន់។ សហចៅក្រមស៊ើបអង្កេត Harmon បានសន្និដ្ឋានថា លោក មាស មុត "មានឆន្ទៈ និង ចេតនា មិនចូលមកបង្ហាញខ្លួន" នៅឯការបង្ហាញខ្លួនលើកដំបូង ហេតុនេះ គាត់បានលះបង់សិទ្ធិមកបង្ហាញខ្លួន ហើយវិធានការសមស្របទាំងអស់ត្រូវបានអនុវត្តដើម្បីធានាឱ្យមានការបង្ហាញខ្លួនរបស់គាត់[14]។ ដោយពិចារណាឃើញថា មាន "ភាពមិនច្បាស់លាស់ទាល់តែសោះ" ថាតើដីកានាំខ្លួននឹងត្រូវអនុវត្តនៅពេលណា ហើយនឹងត្រូវអនុវត្តដែរឬក៏អត់ យល់ពីចរិតលក្ខណៈនៃកិច្ចដំណើរការនីតិវិធី យល់ពីសិទ្ធិរបស់លោក មាស មុត ក្នុងការទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ យល់ពីផលប្រយោជន៍របស់ជនរងគ្រោះ និង យល់ពីរូបភាពរបស់ អ.វ.ត.ក. សហចៅក្រមស៊ើបអង្កេតបានសម្រេចដាក់លោក មាស មុត ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ*[15]។ ការជូនដំណឹងអំពីបទចោទប្រកាន់កំណត់ពីៈ ព័ត៌មានស្ដីពីអត្តសញ្ញាណរបស់លោក មាស មុត តួនាទីរបស់គាត់ដែលត្រូវបានចោទប្រកាន់ក្នុងអំឡុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក. ឧក្រិដ្ឋកម្មនានាដែលត្រូវបានចោទប្រកាន់ ទម្រង់នៃការទទួលខុសត្រូវដែលលោក មាស មុត ត្រូវបានចោទប្រកាន់ និង សិទ្ធិនានារបស់លោក មាស មុត តាមវិធានផ្ទៃក្នុង រួមទាំងសិទ្ធិទទួលការតំណាងក្ដីដោយមេធាវី តាមការជ្រើសរើសរបស់ខ្លួន និង សិទ្ធិនៅស្ងៀមមិនឆ្លើយតប[16]។

១២. នៅថ្ងៃទី ៣ ខែមីនា ឆ្នាំ ២០១៥ ក្នុងពេលប៉ុន្មាននាទីបន្ទាប់ពីជូនដំណឹងដល់ភាគីអំពីដីកាសម្រេចរងការជំទាស់នេះ និង សេចក្ដីជូនដំណឹងអំពីបទចោទប្រកាន់ សហចៅក្រមស៊ើបអង្កេត Harmon បានចេញសេចក្ដីប្រកាសព័ត៌មានមួយដែលរៀបរាប់ពីបទចោទ និង ទីតាំងឧក្រិដ្ឋកម្មត្រូវបានចោទ

---

[13] *ដូចខាងលើ* កថាខណ្ឌ ២៥។ *សូមមើល* លិខិតរបស់ ស.ច.ស.អ. ផ្ញើជូនឯកឧត្តម ឯម សំអាន ចុះថ្ងៃទី ៣០ ខែមករា ឆ្នាំ ២០១៥ ឯកសារ D127។

[14] កថាខណ្ឌ ៥៩ កថាខណ្ឌ ៦៦ នៃដីកាសម្រេចរងការជំទាស់។

[15] *ដូចខាងលើ* កថាខណ្ឌ ៦៨ ដល់កថាខណ្ឌ ៧២ កថាខណ្ឌ ៧៥។

[16] ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំងនឹង មាស មុត ចុះថ្ងៃទី ៣ ខែមីនា ឆ្នាំ ២០១៥ ("ការជូនដំណឹងអំពីបទចោទប្រកាន់") ឯកសារ D128.1។

ប្រកាន់នានា ដែលស្ថិតក្រោមការស៊ើបអង្កេត ដោយកត់សម្គាល់ថា៖

> ដោយសារការដាក់ឱ្យស្ថិតក្រោមការពិនិត្យ អំពីពីបទចោទប្រកាន់ទាំងនេះ វិធានផ្ទៃក្នុង អ.វ.ត.ក. អនុញ្ញាតឱ្យ [លោក មាស] មុត តាមរយៈមេធាវីរបស់គាត់ មានសិទ្ធិចូលពិនិត្យមើលសំណុំរឿង និង ចូលរួមកិច្ចស៊ើបសួរ ដូច្នេះ វានឹងជួយបង្កើនល្បឿននៃកិច្ចដំណើរការរបស់ខ្លួន។ ការធ្វើដូច្នេះ នឹងអនុញ្ញាតឱ្យកិច្ចស៊ើបសួរប្រព្រឹត្តទៅ ដោយការគោរពពេញលេញនូវសិទ្ធិរបស់ភាគីទាំងអស់ និង អាចបញ្ចប់កិច្ចស៊ើបសួរក្នុងថិរវេលាសមស្រប ដោយមានការចេញដីកាដំណោះស្រាយ[17]។

ខ្លឹមសារនៃសេចក្តីប្រកាសព័ត៌មាននេះ ត្រូវបានរាយការណ៍យ៉ាងទូលំទូលាយទាំងនៅក្នុងសារព័ត៌មានក្នុងស្រុក និង អន្តរជាតិ[18]។

---

[17] សេចក្តីប្រកាសព័ត៌មាន *សេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទាក់ទងនឹងរឿងក្តី ០០៣* ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥។

[18] *សូមមើល ឧទាហរណ៍* Holly Robertson *សាលាក្តីខ្មែរក្រហមចោទប្រកាន់មេបញ្ជាការកងទ័ពជើងទឹក ប្រធានស្រុក (KR Tribunal Charges Navy Commander, District Chief)* សារព័ត៌មានឌឹខាំបូឌាដេលី ចុះផ្សាយថ្ងៃទី ៤ ខែមីនា ឆ្នាំ ២០១៥។ Stuart White និង អ្នកផ្សេងទៀត *សាលាក្តីខ្មែរក្រហមចោទប្រកាន់បុគ្គលពីរនាក់បន្ថែមទៀត (KRT charges two more)* សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ចុះផ្សាយថ្ងៃទី ៤ ខែមីនា ឆ្នាំ ២០១៥។ Stuart White និង អ្នកផ្សេងទៀត *ខ្មែរក្រហមពីរនាក់ត្រូវបានចោទប្រកាន់ (Khmer Rouge duo charged)* សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ចុះផ្សាយថ្ងៃទី ៣ ខែមីនា ឆ្នាំ ២០១៥។ គង់ សុឋានរិទ្ធិ *អតីតកម្មាភិបាលមេខ្មែរក្រហមពីរនាក់ត្រូវតុលាការចោទប្រកាន់* វិទ្យុវីអូអេជាភាសាខ្មែរ ផ្សាយថ្ងៃទី ៣ ខែមីនា ឆ្នាំ ២០១៥។ ប្រាក់ ចាន់ធុល *សាលាក្តី អ.ស.ប-កម្ពុជា ចោទប្រកាន់អតីតកម្មាភិបាលខ្មែរក្រហមពីរនាក់បន្ថែមទៀត (U.N.-Cambodia tribunal charges two more ex-Khmer Rouge cadres)* សារព័ត៌មាន REUTERS ចុះផ្សាយថ្ងៃទី ៣ ខែមីនា ឆ្នាំ ២០១៥។ Lindsay Murdoch *សាលាក្តីចោទប្រកាន់អតីតមេបញ្ជាការខ្មែរក្រហមពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (Tribunal charges ex-Khmer Rouge commander with crimes against humanity)* សារព័ត៌មាន THE SYDNEY MORNING HERALD ចុះផ្សាយថ្ងៃទី ៤ ខែមីនា ឆ្នាំ ២០១៥។ Elizabeth LaForgia *សាលាក្តីខ្មែរក្រហមនៅកម្ពុជាចោទប្រកាន់ជនសង្ស័យថ្មីពីរនាក់ (Cambodia Khmer Rouge tribunal charges 2 new suspects)* សារព័ត៌មាន JURIST ចុះផ្សាយថ្ងៃទី ៣ ខែមីនា ឆ្នាំ ២០១៥។ Tu Thanh Ha *កម្មាភិបាលខ្មែរក្រហមត្រូវបានចោទប្រកាន់ពីការសម្លាប់ Stuart Glass ជាជនជាតិកាណាដានៅឆ្នាំ ១៩៧៨ (Khmer Rouge official charged in 1978 killing of Canadian Stuart Glass)* សារព័ត៌មាន THE GLOBE AND MAIL ចុះផ្សាយថ្ងៃទី ៣ ខែមីនា ឆ្នាំ ២០១៥។ Lauren Crothers *កម្មាភិបាលខ្មែរក្រហមពីរនាក់ទៀតត្រូវបានចោទប្រកាន់នៅកម្ពុជា (Two more Khmer Rouge cadre charged in Cambodia)* សារព័ត៌មាន ANADOLU AGENCY ចុះផ្សាយថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥។ *សាលាក្តីខ្មែរក្រហមនៅកម្ពុជាចោទប្រកាន់ជនសង្ស័យថ្មីពីរនាក់ (Cambodia's Khmer Rouge tribunal charges 2 new suspects)* សារព័ត៌មាន THE ASSOCIATED PRESS ចុះផ្សាយថ្ងៃទី ៣ ខែមីនា ឆ្នាំ ២០១៥។ *ជនសង្ស័យជាអតីតកម្មាភិបាលខ្មែរក្រហមពីរនាក់*

## III. បញ្ហាបឋម

### ក. ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

#### ១. វិធាន ៧៤(៣)(ក)

១៣. វិធាន ៧៤(៣)(ក) ចែងថា៖ "ជនត្រូវចោទ ឬ ជនជាប់ចោទអាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា ឬ សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដូចខាងក្រោម៖ ក. ការបញ្ជាក់ពីយុត្តាធិការរបស់ អ.វ.ត.ក."។ បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន តាមវិធាន ៧៤(៣)(ក)។

១៤. យោងតាមដីកាសម្រេចរងការជំទាស់នេះ សហចៅក្រមស៊ើបអង្កេត Harmon បានកំណត់ថា គាត់មានយុត្តាធិការ[19] ដើម្បីដាក់លោក មាស មុត ឲ្យស្ថិតនៅក្រោមការពិនិត្យដោយឯកតោភាគី *ក្នុងចំណោមនោះ* ពីឧក្រិដ្ឋកម្មតាមច្បាប់ជាតិ និង ការរំលោភបំពានធ្ងន់ធ្ងរ តាមទ្រឹស្តីសហឧក្រិដ្ឋកម្មរួម និង ការទទួលខុសត្រូវរបស់ថ្នាក់លើ[20] ដោយពុំចាំបាច់មានហត្ថលេខារបស់សហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង។ មេធាវីការពារក្តីជំទាស់ទៅនឹងការកំណត់នេះ[21]។

១៥. ដូចដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ("ICTY") បានសម្រេចថា៖

> យុត្តាធិការមិនត្រឹមតែជាព្រំដែន ឬ ជាដែនកំណត់មួយនៃអំណាចប៉ុណ្ណោះទេ (គួរតែហៅថា "សមត្ថកិច្ច" ល្អជាង)។ ជាគោលការណ៍ ដូចដែលមើលឃើញពីប្រភពភាសាឡាតាំង *jurisdiction* ជាអំណាចតាមផ្លូវច្បាប់ ហេតុនេះ វាចាំបាច់ត្រូវតែជាអំណាចធម្មានុរូប "ដើម្បីថ្លែងពីច្បាប់" (*dire le droit*) ក្នុងព្រំដែន

---

*ទៀតត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (Two more Khmer Rouge suspects charged with crimes against humanity)* សារព័ត៌មាន THE AGENCE FRANCE-PRESS ចុះផ្សាយថ្ងៃទី ៣ ខែមីនា ឆ្នាំ ២០១៥។

[19] វចនានុក្រម Black's Law កំណត់ន័យទូលាយនៃពាក្យថា "jurisdiction" ("យុត្តាធិការ") ថាជា "សិទ្ធិអំណាចរបស់តុលាការក្នុងការសម្រេចលើរឿងក្តីណាមួយ ឬ ចេញបទបញ្ជាណាមួយ"។ BLACK'S LAW DICTIONARY 927 (9th ed. ឆ្នាំ ២០០៤) ("វចនានុក្រម BLACK'S LAW")។

[20] កថាខណ្ឌ ៧៥ នៃដីកាសម្រេចរងការជំទាស់។ សេចក្តីជូនដំណឹងពីបទចោទប្រកាន់។

[21] *សូមមើលខាងក្រោម* ផ្នែក IV (ក) សម្រាប់ការសន្និដ្ឋានបន្ថែមទៀតអំពីអលទ្ធភាពរបស់សហចៅក្រមស៊ើបអង្កេត Harmon ក្នុងការចេញដីកាសម្រេចរងការជំទាស់ដោយឯកតោភាគី។

អំណាចនេះ នៅក្នុងរបៀបជាអាជ្ញាបញ្ញា និង ស្ពាពរ[22]។

តាមរយៈដីកាសម្រេចរងការជំទាស់នេះ សហចៅក្រមស៊ើបអង្កេត Harmon យល់ថា គាត់មានអំណាចតាមផ្លូវច្បាប់ក្នុងការថ្លែងពីច្បាប់អាជ្ញាបញ្ញា[23] ដោយការសម្រេចដាក់លោក មាស មុត ឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ*។ សេចក្ដីសម្រេចរបស់គាត់បញ្ជាក់ពីយុត្តាធិការរបស់ អ.វ.ត.ក.។

១៦. វិធាន ៧៤(៣)(ក) ត្រូវតែបានបកស្រាយពន្យល់យ៉ាងទូលំទូលាយ ដើម្បីទទួលយកបណ្ដឹងឧទ្ធរណ៍លើបញ្ហាយុត្តាធិការ។ ទស្សនទានបែបចង្អៀតនៃយុត្តាធិការ ដែលកំហិតត្រឹមតែបណ្ដឹងឧទ្ធរណ៍តាមសាច់រឿង ហើយនិងយុត្តាធិការពេលវេលា និង យុត្តាធិការបុគ្គល មិនមែនជាការចាំបាច់ឡើយនៅទីនេះ។ ជាតុលាការដែលអនុវត្តច្បាប់អន្តរជាតិ អ.វ.ត.ក. គឺជា "ប្រព័ន្ធដែលមានស្វ័យភាព" ជាជាង ជា"ប្រព័ន្ធតុលាការបែបបញ្ចូលគ្នា ដែលប្រតិបត្តិការបែងចែកការងារមួយតាមលំដាប់លំដោយក្នុងចំណោមសាលាក្ដីមួយចំនួន"[24] ដូចនៅក្នុងប្រព័ន្ធតុលាការក្នុងស្រុក។ សេចក្ដីសម្រេចទាំងឡាយដែលជាចំណុចសំខាន់នៃសមត្ថកិច្ចរបស់ចៅក្រម ឬ អង្គជំនុំជម្រះ ក្នុងការចោទប្រកាន់ ឬ នាំយកជនណាម្នាក់ទៅកាត់ទោសនៅ អ.វ.ត.ក. ត្រូវតែឆ្លងកាត់ការត្រួតពិនិត្យឡើងវិញដោយបណ្ដឹងឧទ្ធរណ៍។ ដីកាសម្រេចរងការជំទាស់នេះគឺជាសេចក្ដីសម្រេចលើយុត្តាធិការបែបនេះឯង។ មេធាវីការពារក្ដីជំទាស់ទៅនឹងការកំណត់ដោយឯកតោភាគីរបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលថា គាត់មានយុត្តាធិការ និង សមត្ថកិច្ចដាក់លោក មាស មុត ឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ*។ មេធាវីការពារក្ដីសុំបញ្ចូលដោយយោងសារណាទាំងអស់ស្ដីពីភាពអាចទទួលយកបានតាមវិធាន ៧៤(៣)(ក) ដែលបានធ្វើឡើងនៅក្នុងបណ្ដឹងឧទ្ធរណ៍របស់ខ្លួន ប្រឆាំង

---

[22] *រឿងក្ដី រដ្ឋអាជ្ញា* តទល់នឹង *Tadić* សំណុំរឿងលេខ IT-94-1 សេចក្ដីសម្រេចលើញត្តិរបស់មេធាវីការពារក្ដីសុំដាក់បណ្ដឹងឧទ្ធរណ៍បន្ទាន់បង្គំស្ដីពីយុត្តាធិការ ចុះថ្ងៃទី ២ ខែតុលា ឆ្នាំ ១៩៩៥ កថាខណ្ឌ ១០។ សេចក្ដីសម្រេចនេះ បានដោះស្រាយនូវទឡ្ហីករណ៍របស់មេធាវីការពារក្ដីក្នុង*រឿងក្ដី Tadić* ដែលថា តុលាការ ICTY ពុំមានសមាសភាពពេញលេញ ហើយហេតុដូច្នេះ តុលាការនេះពុំមានយុត្តាធិការលើលោក Tadić ទេ។

[23] *ដូចខាងលើ*។

[24] *សូមមើល ដូចខាងលើ* កថាខណ្ឌ ១១ ដែលអង្គជំនុំជម្រះឧទ្ធរណ៍នៃតុលាការ ICTY លើកឡើងថា៖ "ដោយសារខ្វះរចនាសម្ព័ន្ធរួម ច្បាប់អន្តរជាតិមិនបានចែងឲ្យមានប្រព័ន្ធតុលាការបែបបញ្ចូលគ្នាដែលដំណើរការការបែងចែកការងារមួយតាមលំដាប់លំដោយនៅក្នុងចំណោមសាលាក្ដីមួយចំនួន ដែលទិដ្ឋភាព ឬ សមាសភាគមួយចំនួននៃយុត្តាធិការជាអំណាចមួយដែលអាចត្រូវបានប្រមូលផ្ដុំ ឬ ផ្ទេរឲ្យសាលាក្ដីណាមួយក្នុងចំណោមនោះ តែមិនផ្ទេរឲ្យសាលាក្ដីផ្សេងឡើយ"។

នឹងការជូនដំណឹងអំពីបទចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេត Harmon[25]។

**ខ. វិធាន ២១**

១៧. វិធាន ២១ ចែងពីគោលការណ៍គ្រឹះដែលគ្រប់គ្រងកិច្ចដំណើរការនីតិវិធីទាំងអស់នៅ អ.វ.ត.ក.[26] ដែលជាសមាសភាគស្នូល គឺ "ការពិចារណាលើសលុប" លើភាពត្រឹមត្រូវយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី[27]។ អង្គបុរេជំនុំជម្រះអាចទទួលយកបណ្តឹងឧទ្ធរណ៍តាមវិធាន ២១ ទៅតាមករណីជាក់ស្តែង នៅពេលដែល៖ **ក.** បណ្តឹងឧទ្ធរណ៍លើកឡើងពីបញ្ហាទាំងឡាយ ដែលមិនអាចកែតម្រូវបានដោយអង្គជំនុំជម្រះសាលាដំបូង ឬ **ខ.** ការមិនអនុញ្ញាតឱ្យមានបណ្តឹងឧទ្ធរណ៍នឹង "បង្កការខូចខាតដែលមិនអាចជួសជុលបាន" ដល់សិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌[28]។ ដើម្បីឱ្យមានតុល្យភាព នៅពេលដែលអង្គហេតុ និង កាលៈទេសៈនៃបណ្តឹងឧទ្ធរណ៍តម្រូវឱ្យមានការបកស្រាយតាមន័យទូលាយនូវសិទ្ធិប្តឹងឧទ្ធរណ៍តាមវិធាន ២១ នោះអង្គបុរេជំនុំជម្រះនឹងអនុញ្ញាតឱ្យមានបណ្តឹងឧទ្ធរណ៍បែបនេះ[29]។ នៅទីនេះ តម្រូវឱ្យមានការបកស្រាយតាមន័យទូលាយនូវសិទ្ធិប្តឹងឧទ្ធរណ៍។

១៨. បណ្តឹងឧទ្ធរណ៍នេះ លើកឡើងនូវបញ្ហានានាដែលអង្គជំនុំជម្រះសាលាដំបូងមិនអាចកែតម្រូវបាន។ បណ្តឹងនេះជំទាស់ទៅនឹងការបកស្រាយ និង ការអនុវត្តរបស់សហចៅក្រមស៊ើបអង្កេត Harmon

---

[25] *សូមមើល* បណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេត Harmon អំពីបទចោទប្រកាន់ប្រឆាំងនឹង មាស មុត ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០១៥ នឹងដាក់ជូននាពេលខាងមុខ។

[26] វិធាន ២១ ចែងថា (ការគូសបញ្ជាក់បន្ថែម)៖ "ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ញារដ្ឋបាលទាំងអស់ជាធរមាន *ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍* របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និង ជនរងគ្រោះ និង *ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និង កិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព* ដោយគិតដល់លក្ខណៈពិសេសរបស់ អ.វ.ត.ក. ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. និង កិច្ចព្រមព្រៀង"។

[27] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ៤៨ ដល់ ៤៩។

[28] *ដូចខាងលើ* កថាខណ្ឌ ៤៨។

[29] *ដូចខាងលើ* កថាខណ្ឌ ៤៩។ អង្គបុរេជំនុំជម្រះ យោងសេចក្តីសម្រេចពីមុនរបស់ខ្លួន ដែលបានទទួលយកបណ្តឹងឧទ្ធរណ៍មួយប្រឆាំងនឹងការបដិសេធរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ចំពោះសំណើសុំផ្អាកកិច្ចដំណើរការនីតិវិធី ដោយផ្អែកលើការបំពានលើដំណើរការនីតិវិធី និង បណ្តឹងឧទ្ធរណ៍មួយដែលថា តើជនត្រូវចោទបានទទួលការជូនដំណឹងពេញលេញ ឬទេ អំពីបទចោទប្រកាន់សហឧក្រិដ្ឋកម្មរួមដែលជាទម្រង់មួយនៃការទទួលខុសត្រូវ។

នូវវិធាននីតិវិធីនៃ អ.វ.ត.ក. វិធាននីតិវិធីកម្ពុជា និង អន្តរជាតិ ទាក់ទងនឹងការបង្ហាញខ្លួនលើកដំបូង។ ដោយសារការបង្ហាញខ្លួនលើកដំបូង គឺជាសវនាការមុនអង្គសេចក្តី នោះវាមិនមែនជាបញ្ហាដែលអង្គជំនុំជម្រះសាលាដំបូងអាចដោះស្រាយ ឬ កែតម្រូវបានឡើយ។ អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានសម្រេចថា ខ្លួនពុំមែនជាស្ថាប័នសម្រាប់ទទួលបណ្តឹងឧទ្ធរណ៍ ឬ ជាស្ថាប័នសម្រាប់ពិនិត្យឡើងវិញ ទាក់ទងនឹងវិធានការនានាដែលចាត់ដោយអង្គភាពតុលាការដទៃៗទៀត ក្នុងអំឡុងដំណាក់កាលស៊ើបសួរឡើយ[30]។ ប្រសិនបើមេធាវីការពារក្តីរង់ចាំរហូតដល់ដំណាក់កាលជំនុំជម្រះលើអង្គសេចក្តី ដើម្បីដាក់សំណើសុំការពិចារណាលើដីកាសម្រេចរងការជំទាស់នេះ នោះអង្គជំនុំជម្រះសាលាដំបូងនឹងគ្រាន់តែតម្កល់យុត្តិសាស្ត្រពីមុនរបស់ខ្លួន ហើយបដិសេធមិនស្តាប់ការតតាំងជំទាស់ណាមួយទៅនឹងដីកាសម្រេចរងការជំទាស់នេះ។ ជាងនេះទៀត កាលណាសេចក្តីសម្រេចមួយរំលោភលើសិទ្ធិរបស់លោក មាស មុត ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ដូចជាដីកាសម្រេចរងការជំទាស់នេះ ដំណោះស្រាយមិនគួរត្រូវបានពន្យារពេលរហូតដល់ដំណាក់កាលជំនុំជម្រះលើអង្គសេចក្តី ដែលអាចមានរយៈពេលជាងមួយឆ្នាំទៀតឡើយ។ ឥឡូវ ដីកាសម្រេចរងការជំទាស់នេះ ប៉ះពាល់ដល់លោក មាស មុត ហើយត្រូវតែកែតម្រូវនៅពេលនេះ។

១៩. ការមិនព្រមទទួលយកបណ្តឹងឧទ្ធរណ៍នេះ នឹងបង្កការខូចខាតដែលមិនអាចជួសជុលបាន ដល់សិទ្ធិរបស់លោក មាស មុត ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌។ ការដាក់លោក មាស មុត ឱ្យស្ថិតក្រោមការពិនិត្យ ដោយឯកតោភាគី គឺរំលោភលើសិទ្ធិរបស់គាត់ក្នុងការចូលបង្ហាញខ្លួនលើកដំបូងដែលមានសុពលភាព ដែលធ្វើឡើងនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត *ទាំងពីរនាក់*[31]។ ការដាក់លោក មាស មុត ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* រំលោភលើសិទ្ធិរបស់គាត់ ក្នុង

---

[30] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីទាក់ទងនឹងភាពមិនប្រក្រតី ដែលត្រូវបានចោទប្រកាន់ថាបានកើតឡើងនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ (ឯកសារ E221, E223, E224, E224/2, E234, E234/2, E241 និង E241/1) ចុះថ្ងៃទី ៧ ខែធ្នូ ឆ្នាំ ២០១២ ឯកសារ E251 កថាខណ្ឌ ២២។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ សេចក្តីសម្រេចលើញត្តិរបស់ នួន ជា ស្តីពីភាពត្រឹមត្រូវយុត្តិធម៌នៃកិច្ចស៊ើបសួរ (ឯកសារ E51/3, E82, E88 និង E92) ចុះថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ២០១១ ឯកសារ E116 កថាខណ្ឌ ១៨។

[31] *សូមមើល ខាងក្រោម* ផ្នែក IV (ក) សម្រាប់ការសន្និដ្ឋានបន្ថែមទៀតអំពីសិទ្ធិរបស់លោក មាស មុត ក្នុងការចូលរួមក្នុងការបង្ហាញខ្លួនលើកដំបូងដែលមានសុពលភាព។

ការមានវត្តមាននៅក្នុងការបង្ហាញខ្លួនលើកដំបូងបែបនេះ[32]។ មេធាវីការពារក្ដីជំទាស់ទៅនឹងការវិភាគ និង ការអនុវត្តវិធានផ្ទៃក្នុង និង វិធាននីតិវិធីកម្ពុជា និង អន្តរជាតិរបស់សហចៅក្រមស៊ើបអង្កេត Harmon។ ការដាក់ជនត្រូវចោទឱ្យស្ថិតក្រោមការពិនិត្យដោយឯកតោភាគី មិនត្រូវបានអនុញ្ញាតឡើយនៅក្នុងក្របខ័ណ្ឌច្បាប់នៃ អ.វ.ត.ក.។ ការដាក់ជនត្រូវចោទឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* មិនត្រូវបានអនុញ្ញាតដោយវិធាន ៥៧ ឬ ច្បាប់កម្ពុជាទេ។ *ទោះបីជា* ការដាក់ជនត្រូវចោទឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ត្រូវបានអនុញ្ញាតដោយវិធាន ៥៧ ឬ វិធាននីតិវិធីកម្ពុជាក៏ដោយ ក៏វិធាននីតិវិធីអន្តរជាតិបង្ហាញថា ទង្វើបែបនេះអាចត្រូវបានអនុញ្ញាត *ត្រឹមតែ* នៅពេលដែលលក្ខខណ្ឌជាក់លាក់មួយចំនួនត្រូវបានបំពេញប៉ុណ្ណោះ[33]។ នៅទីនេះ លក្ខខណ្ឌទាំងនេះមិនត្រូវបានបំពេញទេ។ ក្នុងការជ្រើសរើសយកការបំពេញកិច្ចងាយស្រួល ជាជាងជ្រើសរើសយកករណីកិច្ចរបស់គាត់ក្នុងការការពារផលប្រយោជន៍របស់លោក មាស មុត[34] សហចៅក្រមស៊ើបអង្កេត Harmon បានរំលោភបំពានលើសិទ្ធិរបស់លោក មាស មុត ក្នុងការចូលបង្ហាញខ្លួនលើកដំបូងដែលមានសុពលភាព និង សិទ្ធិមានវត្តមាននៅឯសវនាការបែបនេះ។

២០. ប្រសិនបើអង្គបុរេជំនុំជម្រះយល់ឃើញថា បណ្ដឹងឧទ្ធរណ៍នេះមិនអាចទទួលយកបានតាមវិធាន ៧៤(៣)(ក) នោះនឹងពុំមានវិធីណាផ្សេងទៀត ដើម្បីឱ្យលោក មាស មុត អាចប្ដឹងឧទ្ធរណ៍បានឡើយ។ បណ្ដឹងឧទ្ធរណ៍នេះត្រូវតែទទួលយកបាន តាមការបកស្រាយទូលាយនៃវិធាន ២១ ដើម្បីកែតម្រូវកំហុសនានានៅក្នុងដីកាសម្រេចរងការជំទាស់ និង ដើម្បីទប់ស្កាត់ការបន្តឱ្យមានការខូចខាតដែលមិនអាចជួសជុលបានដល់សិទ្ធិរបស់លោក មាស មុត ក្នុងការទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌។

### ខ. បទដ្ឋាននៃការពិនិត្យឡើងវិញ

២១. ដីកាសម្រេចរងការជំទាស់នេះអាចត្រូវបានទុកជាមោឃៈ ប្រសិនបើដីកានេះ៖ **ក.** បានពឹងផ្អែកលើការបកស្រាយមិនត្រឹមត្រូវនូវច្បាប់ពាក់ព័ន្ធ ដែលធ្វើឱ្យពុលកម្មសេចក្ដីសម្រេច **ខ.** បានពឹងផ្អែកលើ

---

[32] *សូមមើល ខាងក្រោម* ផ្នែក IV(ខ)៤ សម្រាប់ការសន្និដ្ឋានបន្ថែមទៀតអំពីសិទ្ធិរបស់លោក មាស មុត ក្នុងការមានវត្តមាននៅក្នុងការបង្ហាញខ្លួនលើកដំបូងដែលមានសុពលភាព។

[33] *សូមមើល ខាងក្រោម* ផ្នែក IV(ខ)៤ និង V(ខ)៥ ដែលពិភាក្សាថា តើលក្ខខណ្ឌសម្រាប់កិច្ចដំណើរការនីតិវិធី*ដោយកំបាំងមុខ* ត្រូវបានបំពេញ ឬទេ។

[34] *សូមមើល* កថាខណ្ឌ ៦៩ នៃដីកាសម្រេចរងការជំទាស់។

ការសន្និដ្ឋានខុសយ៉ាងច្បាស់ក្រឡែតទៅលើអង្គហេតុ ដែលនាំឱ្យយុត្តិធម៌មានការថ្លោះធ្លោយ ឬ គ. មានភាពអយុត្តិធម៌ ឬ មិនសមហេតុផលខ្លាំង ដែលនាំឲ្យមានការរំលោភបំពានឆន្ទានុសិទ្ធិ[35]។

## IV. ច្បាប់ និង ឧទ្ទិករណ៍

### ក. សហចៅក្រមស៊ើបអង្កេត Harmon បានបំពេញកិច្ច *ហួសពីសមត្ថកិច្ច* និង *មានកំហុស* ក្នុងការចេញដីកាសម្រេចរងការជំទាស់ដោយឯកតោភាគី

#### ១. ក្របខ័ណ្ឌច្បាប់នៃ អ.វ.ត.ក. កំណត់ឲ្យសហចៅក្រមស៊ើបអង្កេតគិតដល់ការដឹកនាំការបង្ហាញខ្លួនលើកដំបូងរួមគ្នាតាមវិធាន ៥៧

២២. មាត្រា ៥(៤) នៃកិច្ចព្រមព្រៀង[36] ចែងក្នុងផ្នែកពាក់ព័ន្ធថា៖ "សហចៅក្រមស៊ើបអង្កេតត្រូវសហការគ្នា ដើម្បីឈានទៅដល់ការឯកភាពគ្នាមួយក្នុងការស៊ើបអង្កេត"។ មាត្រា ២៣ ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក.[37] បញ្ជាក់ឡើងវិញនូវលក្ខខណ្ឌតម្រូវនេះ ដោយចែងក្នុងផ្នែកដែលពាក់ព័ន្ធថា៖ "រាល់ការស៊ើបអង្កេត គឺជាការទទួលខុសត្រូវរួមគ្នារបស់ចៅក្រមស៊ើបអង្កេតពីរនាក់..."។

២៣. នៅក្នុងការកំណត់ពីចេតនានៃមាត្រាទាំងឡាយនៅក្នុងកិច្ចព្រមព្រៀង និង ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក. ការិយាល័យសហចៅក្រមស៊ើបអង្កេត និង អង្គបុរេជំនុំជម្រះ ត្រូវអនុវត្តគោលការណ៍នៃការបកស្រាយច្បាប់ ដែលមានចែងក្នុងអនុសញ្ញាទីក្រុងវីយែនស្ដីពីច្បាប់សន្ធិសញ្ញា ("អនុសញ្ញា VCLT")[38]។ អនុសញ្ញា VCLT ត្រូវបានអនុវត្តយ៉ាងច្បាស់លាស់ទៅលើការបកស្រាយកិច្ចព្រម

---

[35] *រឿងក្ដី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៦៤) សាលដីកាកោសល្យបជាសាធារណៈលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែលបដិសេធសំណើសុំអនុញ្ញាតថតសំឡេង/រូបភាពវីដេអូនៃការជួបជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ២០១០ ឯកសារ A371/2/12 កថាខណ្ឌ ២២។ ពាក់ព័ន្ធនឹងការរំលោភបំពានបទដ្ឋានឆន្ទានុសិទ្ធិ សេចក្ដីសម្រេច ឬដីកា ត្រូវតែមិនសមហេតុផលទាល់តែសោះ ដែល"នាំឲ្យមានសេចក្ដីសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតមិនបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនឲ្យបានត្រឹមត្រូវ" *ដូចខាងលើ*។

[36] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ("កិច្ចព្រមព្រៀង")។

[37] ច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក.")។

[38] អនុសញ្ញាទីក្រុងវីយែនស្ដីពីច្បាប់សន្ធិសញ្ញា អនុម័តនៅថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ១៩៦៩ ឯកសារ 1155 UNTS 331 (ឆ្នាំ ១៩៦៩)។

ព្រៀង[39]។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ក៏ត្រូវបកស្រាយ អនុលោមតាមអនុសញ្ញា VCLT ដែរ[40]។

២៤. មាត្រា ៣១ នៃអនុសញ្ញា VCLT ចែងថា៖

១. សន្ធិសញ្ញាត្រូវតែបានបកស្រាយដោយសុចរិតភាព អនុលោមទៅតាមន័យធម្មតា ដែលត្រូវបានផ្តល់ឲ្យពាក្យពេជន៍ទាំងឡាយនៃសន្ធិសញ្ញាទៅតាមបរិបទ និង ដោយគិតដល់កម្មវត្ថុ និង គោលបំណងនៃសន្ធិសញ្ញានោះ។

២. បរិបទសម្រាប់គោលបំណងនៃការបកស្រាយសន្ធិសញ្ញាត្រូវរាប់បញ្ចូលបុព្វកថា និង ឧបសម្ព័ន្ធបន្ថែមទៅលើអត្ថបទ៖

ក) កិច្ចព្រមព្រៀងណា ដែលទាក់ទងនឹងសន្ធិសញ្ញានេះ ដែលត្រូវបានបង្កើតឡើងរវាងភាគីទាំងអស់ ដែលទាក់ទងនឹងការឲ្យយោបល់សន្និដ្ឋានលើសន្ធិសញ្ញានេះ។

ខ) លិខិតុបករណ៍ណា ដែលត្រូវបានបង្កើតឡើងដោយភាគីមួយ ឬ ច្រើន ដែលទាក់ទងនឹងការឲ្យយោបល់សន្និដ្ឋានលើសន្ធិសញ្ញា ហើយត្រូវបានទទួលយកដោយភាគីដទៃៗផ្សេងទៀតថា ជាលិខិតុបករណ៍មួយដែលទាក់ទងនឹងសន្ធិសញ្ញានេះ។

៣. នេះគឺត្រូវយកមកគិតគូររាប់បញ្ចូលជាមួយនឹងបរិបទ៖

ក) កិច្ចព្រមព្រៀងណាដែលកើតមានក្រោយៗមក រវាងភាគីទាំងឡាយ ស្តីពីការបកស្រាយសន្ធិសញ្ញា ឬ បទប្បញ្ញត្តិនៃសន្ធិសញ្ញានេះ។

---

[39] មាត្រា ២(២) នៃកិច្ចព្រមព្រៀង។

[40] ឧទាហរណ៍ នៅឯតុលាការ ICTY និង តុលាការអន្តរជាតិសម្រាប់ប្រទេសរ្វាន់ដា (“ICTR”) វិធានស្តីពីនីតិវិធី និង ភស្តុតាង (“RPE”) ត្រូវបានបកស្រាយអនុលោមតាមអនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញា ពីព្រោះ៖ **ក.** វិធានទាំងនោះកើតចេញពីលក្ខន្តិកៈតុលាការ ICTY និង តុលាការ ICTR ដែលជាសន្ធិសញ្ញាដែលស្ថិតក្នុងអនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញា និង **ខ.** វិធាននៃការបកស្រាយច្បាប់នៅក្នុងអនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញា ឆ្លុះបញ្ចាំងច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ *សូមមើល ឧទាហរណ៍ រឿងក្តី រដ្ឋអាជ្ញា* តទល់នឹង *Delalić និង អ្នកផ្សេងទៀត* សំណុំរឿងលេខ IT-96-21-A សាលក្រម ចុះថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ ២០០១ កថាខណ្ឌ ៦៧ ។ *រឿងក្តី រដ្ឋអាជ្ញា* តទល់នឹង *Kanyabashi* សំណុំរឿងលេខ ICTR-96-15-A សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តី សុំដាក់បណ្តឹងឧទ្ធរណ៍បន្ទាន់បង្គំស្តីពីយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង I មតិយោបល់ដោយឡែក និង ស្របគ្នារួមរវាងចៅក្រម Wang Tieya និង ចៅក្រម Rafael Nieto-Navia ចុះថ្ងៃទី ៣ ខែមិថុនា ឆ្នាំ ១៩៩៩ កថាខណ្ឌ ១១។

ខ) ទម្លាប់អនុវត្តណាដែលកើតមានក្រោយៗមក នៅក្នុងការអនុវត្តសន្ធិសញ្ញានេះ ដែលបង្កើតកិច្ចព្រមព្រៀងរបស់ភាគីទាំងឡាយ ពាក់ព័ន្ធនឹងការបកស្រាយសន្ធិសញ្ញានេះ។

គ) វិធានពាក់ព័ន្ធនានានៃច្បាប់អន្តរជាតិ ដែលអាចអនុវត្តបានក្នុងទំនាក់ទំនងរវាងភាគីទាំងឡាយ។

៤. អត្ថន័យពិសេសត្រូវតែផ្តល់ឲ្យពាក្យពេចន៍មួយ ប្រសិនបើមានការបង្ហាញថា ភាគីមានបំណងធ្វើដូច្នេះ។

កាលណាអត្ថន័យធម្មតានៃពាក្យពេចន៍ណាមួយមានន័យមិនច្បាស់លាស់ ឬ ស្រពេចស្រពិល ឬ ជាក់ស្តែង នាំឲ្យមានលទ្ធផល មិនសមទំនង ឬ មិនសមហេតុផល នោះមធ្យោបាយបន្ថែមនៃការបកស្រាយអាចជាដំណោះស្រាយ[41]។ អនុសញ្ញា VCLT គាំទ្រវិធាននៃការបកស្រាយច្បាប់នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល[42]។

២៥. ក្នុងការសម្លឹងមើលអត្ថន័យធម្មតានៃមាត្រា ៥(៤) នៃកិច្ចព្រមព្រៀង និង មាត្រា ២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. សហចៅក្រមស៊ើបអង្កេតត្រូវសន្មតថា អ្នកព្រាងវិធានផ្ទៃក្នុងបាននិយាយពីអ្វីដែលពួកគេបានចង្អុលប្រាប់ និង បានចង្អុលប្រាប់អ្វីដែលបាននិយាយ[43]។ អត្ថន័យធម្មតានៃមាត្រាទាំងនេះបង្អុលបង្ហាញថា សហចៅក្រមស៊ើបអង្កេតត្រូវធ្វើការជាមួយគ្នាក្នុងដំណាក់កាលកិច្ចស៊ើបសួរ។ សហចៅក្រមស៊ើបអង្កេតម្នាក់មិនអាចដាក់ជនណាម្នាក់ឲ្យស្ថិតក្រោមការពិនិត្យតែឯងបានឡើយ។

២៦. ពាក្យ*សហការ* ដូចដែលត្រូវបានប្រើនៅក្នុងមាត្រា ៥(៤) នៃកិច្ចព្រមព្រៀង មានន័យថា "ធ្វើការជា

---

[41] មាត្រា ៣២ នៃអនុសញ្ញា VCLT ។

[42] *សូមមើល* Claire M. Germain *វិធីសាស្ត្រក្នុងការបកស្រាយច្បាប់ និង ប្រវត្តិនៃការធ្វើច្បាប់នៅប្រទេសបារាំង (Approaches to Statutory Interpretation and Legislative History in France)* 13 DUKE J. COMP. & INT'L L. 195, 201-02 (ឆ្នាំ ២០០៣)។

[43] *រឿងក្តី ធនាគារជាតិនៃរដ្ឋ Connecticut* តទល់នឹង *Germain* សំណុំរឿងលេខ 503 U.S. 249, 253-54 (ឆ្នាំ ១៩៩២) (ការដកស្រង់ខាងក្នុងត្រូវបានលុបចេញ)៖ "[ក្នុង] ការបកស្រាយលក្ខន្តិកៈមួយ តុលាការគួរតែដំបូងឡើយផ្អែកជានិច្ចទៅលើគោលការណ៍មូលដ្ឋាន មុនគោលការណ៍ដទៃទៀត ...។ [តុលាការ] ត្រូវសន្មតថា អង្គនីតិបញ្ញត្តិនិយាយនៅក្នុងច្បាប់នូវអ្វីដែលខ្លួនចង់និយាយ និង មានន័យនៅក្នុងច្បាប់ដូចដែលអ្វីនិយាយនៅក្នុងនោះ។ នៅពេលដែលពាក្យពេចន៍ច្បាប់មិនច្បាស់លាស់ ពេលនោះគោលការណ៍ដំបូងនេះក៏ជាគោលការណ៍ចុងក្រោយដែរ គឺថា៖ "ការស៊ើបអង្កេតតាមផ្លូវតុលាការគឺពេញលេញ""។

មួយគ្នា” ឬ “ធ្វើការជាមួយមនុស្សម្នាក់ទៀត ឬ ជាមួយក្រុមផ្សេងទៀត ដើម្បីធ្វើអ្វីមួយ”[44]។ ពាក្យ *រួមគ្នា* ដូចដែលត្រូវបានប្រើនៅក្នុងមាត្រា ២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. មានន័យថា “[ដាក់]ជាមួយគ្នា ចូលរួមគ្នា បញ្ចូលគ្នា [ឬ] រួបរួមគ្នា”[45]។ អត្ថន័យធម្មតានៃពាក្យទាំងនេះ គឺមិនស្រពេចស្រពិល និង ច្បាស់លាស់។

២៧. បរិបទនៅក្នុងកិច្ចព្រមព្រៀង និង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ត្រូវបានបង្កើតឡើង គាំទ្របន្ថែមទៀតដល់សេចក្តីសន្និដ្ឋានមួយដែលថា សហចៅក្រមស៊ើបអង្កេតត្រូវសហការគ្នា ក្នុងការដាក់ជនណាម្នាក់ឱ្យស្ថិតក្រោមការពិនិត្យ។ កិច្ចព្រមព្រៀង និង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. បង្កើតនូវប្រព័ន្ធទ្វេភាគីនៅ អ.វ.ត.ក.៖ ដូចសហចៅក្រមស៊ើបអង្កេតដែរ សហព្រះរាជអាជ្ញាពីររូប “ត្រូវសហការគ្នា ដើម្បីឈានទៅដល់ដំណើរការឯកភាពគ្នាមួយក្នុងការចោទប្រកាន់”[46]។ នៅក្នុងការិយាល័យរដ្ឋបាល ប្រធានការិយាល័យរដ្ឋបាលខ្មែរ និង អនុប្រធានការិយាល័យរដ្ឋបាលអន្តរជាតិ “ត្រូវសហការគ្នា ដើម្បីធានាឱ្យដំណើរកិច្ចការរដ្ឋបាលមានប្រសិទ្ធភាព និង ទទួលបានលទ្ធផលល្អ”[47]។ អង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និង អង្គជំនុំជម្រះតុលាការកំពូល រួមមានចៅក្រមជាតិ និង ចៅក្រមអន្តរជាតិ ដែល “ត្រូវព្យាយាមដើម្បីឈានទៅដល់ការមូលមតិគ្នា នៅក្នុងការសម្រេចសេចក្តីរបស់ខ្លួន”[48]។

---

[44] *សូមមើលផងដែរ* និយមន័យនៃពាក្យ *cooperate (សហការ)* នៅក្នុងវចនានុក្រមភាសាអង់គ្លេស Oxford លើអ៊ិនធឺណេត៖ “ធ្វើការជាមួយគ្នា បំពេញការងាររួមគ្នា (*ជាមួយ* មនុស្សម្នាក់ទៀត ឬ អ្វីមួយ *សម្រាប់* ទីបញ្ចប់មួយ ឬ គោលបំណងមួយ ឬ *នៅក្នុង*ការងារមួយ) *អាចរកបាននៅលើគេហទំព័រ៖* http://www.oed.com/view/Entry/41036?rskey=TfSQ4H&result=2&isAdvanced=false#eid។ *សូមមើលផងដែរ* និយមន័យនៃពាក្យ *cooperate (សហការ)* នៅក្នុងវចនានុក្រម Merriam-Webster នៅលើអ៊ិនធឺណិត *អាចរកបាននៅលើគេហទំព័រ៖* http://www.merriam-webster.com/dictionary/*cooperate*។

[45] *សូមមើល* និយមន័យនៃពាក្យ *joint (រួមគ្នា)* នៅក្នុងវចនានុក្រមភាសាអង់គ្លេស Oxford *អាចរកបាននៅលើគេហទំព័រ៖* http://www.oed.com/view/Entry/101546?rskey=uGvvbc&result=3&isAdvanced=false#eid។ *សូមមើលផងដែរ* និយមន័យនៃពាក្យ *joint (រួមគ្នា)* នៅក្នុងវចនានុក្រម Merriam-Webster នៅលើអ៊ិនធឺណិត៖ “ត្រូវបានធ្វើដោយ ឬ ពាក់ព័ន្ធនឹងមនុស្សពីរនាក់ ឬ ច្រើននាក់” ឬ “កំពុងធ្វើអ្វីមួយជាមួយគ្នា” *អាចរកបាននៅលើគេហទំព័រ៖* http://www.merriam-webster.com/dictionary/joint។

[46] មាត្រា ៦(៤) នៃកិច្ចព្រមព្រៀង។ *សូមមើលផងដែរ* មាត្រា ១៦ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។

[47] មាត្រា ៨(៣) ដល់ ៨(៤) នៃកិច្ចព្រមព្រៀង។

[48] *ដូចខាងលើ* មាត្រា ៩(១) មាត្រា ៣(១)-(២)។ *សូមមើលផងដែរ* មាត្រា ៩ ថ្មី មាត្រា ១៤ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។

២៨. វិធានផ្ទៃក្នុងគាំទ្រស្រដៀងគ្នាដល់សេចក្តីសន្និដ្ឋានដែលថា សហចៅក្រមស៊ើបអង្កេតត្រូវសហការ និង ធ្វើការជាមួយគ្នា ដោយតម្រូវឱ្យមាន "តម្រុយច្បាស់លាស់ និង ស៊ីសង្វាក់គ្នា" ដើម្បីចោទប្រកាន់ជនសង្ស័យ[49]។ ការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេតចំពោះអត្ថិភាពនៃតម្រុយច្បាស់លាស់ និង ស៊ីសង្វាក់គ្នា ចង្អុលបង្ហាញថា ភស្តុតាងបែបនេះគឺ *មិន* មានទេ ពោលគឺថា ចៅក្រមដែលមានហេតុផលត្រឹមត្រូវយល់ផ្សេងពីគ្នាចំពោះការវាយតម្លៃទៅលើភស្តុតាង[50]។ នៅក្នុងករណីបែបនេះ វាមិនមែនជាការត្រឹមត្រូវទេ ដែលសហចៅក្រមស៊ើបអង្កេតម្នាក់ដាក់ជនសង្ស័យឱ្យស្ថិតក្រោមការពិនិត្យដោយខ្លួនឯងផ្ទាល់នោះទេ។

២៩. មាត្រា ៥(៤) នៃកិច្ចព្រមព្រៀងចែងថា នៅពេលសហចៅក្រមស៊ើបអង្កេត "មិនអាចចុះសម្រុងគ្នាថា ត្រូវបន្តការស៊ើបអង្កេតណាមួយ" ការស៊ើបអង្កេតនោះ ត្រូវធ្វើបន្តទៅមុខទៀត លើកលែងតែដំណើរការនៃការដោះស្រាយការខ្វែងយោបល់គ្នាតាមមាត្រា ៧ ត្រូវបានអនុវត្ត។ មាត្រា ២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ឆ្លុះបញ្ចាំងពាក្យពេចន៍នេះ[51]។

៣០. អ្នកព្រាងមាត្រា ៥(៤) នៃកិច្ចព្រមព្រៀង និង មាត្រា ២៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ត្រូវបានសន្មតថា បានធ្វើឡើងដោយចេតនា នៅក្នុងការតាក់តែងមាត្រាទាំងនេះ។ មាត្រាទាំងនេះទាក់ទងនឹងការខ្វែងយោបល់គ្នាអំពីថាតើ *កិច្ចស៊ើបសួរ* អាច ឬ មិនអាចបន្តដំណើរការទៅមុខ។ ការដាក់បុគ្គលណាម្នាក់ឱ្យស្ថិតនៅក្រោមការពិនិត្យតាមវិធាន ៥៧ មិនទាក់ទងនឹងថា តើកិច្ចស៊ើបសួរនឹងបន្តដំណើរការ ឬយ៉ាងណាទេ វាទាក់ទងនឹងថា តើ *ការជំនុំជម្រះ* ជាយថាហេតុមួយនឹងដំណើរការ ឬយ៉ាងណា។ កិច្ចព្រមព្រៀង និង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. *មិន* ពោលប្រស្រ័យឡើយអំពី

---

[49] វិធាន ៥៥(៤) នៃវិធានផ្ទៃក្នុង។

[50] នៅពេលមានវិមតិសង្ស័យណាមួយថាតើតម្រុយច្បាស់លាស់ និង ស៊ីសង្វាក់ ឬយ៉ាងណានោះ រដ្ឋធម្មនុញ្ញកម្ពុជាតម្រូវឱ្យវិមតិសង្ស័យបែបនេះ ត្រូវបានជាប្រយោជន៍ដល់លោក មាស មុត។ មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ត្រូវបានធ្វើវិសោធនកម្មដោយក្រម ចុះថ្ងៃទី ៨ ខែមីនា ឆ្នាំ ១៩៩៩ ដែលត្រូវបានប្រកាសឱ្យប្រើវិសោធនកម្មមាត្រា ១១, ១២, ១៣, ១៨, ២២, ២៤, ២៦, ២៨, ៣០, ៣៤, ៥១, ៩០, ៩១, ៩៣ និង មាត្រាផ្សេងៗទៀតពីជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានអនុម័តដោយរដ្ឋសភាជាតិនៅថ្ងៃទី ៤ ខែមីនា ឆ្នាំ ១៩៩៩។

[51] មាត្រា ២៣ ថ្មី ចែង (ការគូសបញ្ជាក់បន្ថែម)៖ ក្នុងករណីដែលមានភាពមិនយល់ស្របគ្នា រវាងសហចៅក្រមស៊ើបអង្កេត ត្រូវអនុវត្តគោលការណ៍ដូចខាងក្រោម៖ *ការស៊ើបអង្កេតត្រូវធ្វើបន្ត* ដរាបណាសហចៅក្រមស៊ើបអង្កេតទាំងពីរ ឬ មួយរូបក្នុងចំណោមពួកគេ ពុំបានប្តឹងសុខចិត្តក្នុងរយៈពេលសាមសិបថ្ងៃថាភាពខ្វែងយោបល់គ្នាត្រូវដោះស្រាយដោយអនុវត្តតាមបទប្បញ្ញត្តិដូចខាងក្រោម..."។

ការខ្វែងយោបល់គ្នា ដែលទាក់ទងនឹងថា តើ *ការជំនុំជម្រះ* ជាយថាហេតុមួយនឹងដំណើរការ ឬ យ៉ាងណានោះ។

៣១. អត្ថន័យធម្មតានៃមាត្រា ៥(៤) នៃកិច្ចព្រមព្រៀង និង មាត្រា ២៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. តម្រូវឱ្យមានសហចៅក្រមស៊ើបអង្កេតទាំងពីរនាក់ បើត្រូវដាក់ជនសង្ស័យណាម្នាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ។ ដីកាសម្រេចរងការជំទាស់នេះ គឺជាការបំពេញកិច្ច *ហួសពីសមត្ថកិច្ច*[52] ដែលប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិរបស់លោក មាស មុត ក្នុងការបង្ហាញខ្លួនលើកដំបូងដែលមានសុពលភាព។

**២. វិសាលភាពនៃវិធាន ៧២ មិនអាចត្រូវបានពង្រីកទៅរុំព័ទ្ធ ដីកាសម្រេចរងការជំទាស់នេះបានទេ**

៣២. នៅក្នុងរឿងក្តី ០០៤ អង្គបុរេជំនុំជម្រះបានសម្រេចថា សហចៅក្រមស៊ើបអង្កេតតែម្នាក់អាចចេញដីកាកោះបាន ប្រសិនបើគាត់បានអនុវត្តតាមវិធាន ៧២[53]។ អង្គបុរេជំនុំជម្រះមិនបានសម្រេចថា សហចៅក្រមស៊ើបអង្កេតម្នាក់អាចដាក់ជនត្រូវចោទឱ្យស្ថិតក្រោមការពិនិត្យតាមវិធាន ៥៧ ដោយគ្មានការយល់ព្រមពីសហចៅក្រមស៊ើបអង្កេតម្នាក់ទៀតឡើយ។

៣៣. សហចៅក្រមស៊ើបអង្កេត Harmon បានពង្រីកយុត្តិសាស្ត្រដែលមានព្រំដែនរបស់អង្គបុរេជំនុំជម្រះដោយឯកតោភាគី ដោយគ្មានការវិភាគសមហេតុផល ដើម្បីសន្និដ្ឋានថា គាត់តែឯងមានសិទ្ធិអំណាចក្នុងការកំណត់ពេលនៃការបង្ហាញខ្លួនលើកដំបូង និង ក្នុងការដាក់លោក មាស មុតឱ្យស្ថិតក្រោមការពិនិត្យ។ វាពុំមានការចង្អុលបង្ហាញថា សហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង បានផ្ទេរសិទ្ធិអំណាចរបស់ខ្លួនក្នុងការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ ទៅឱ្យសហចៅក្រមស៊ើបអង្កេត

---

[52] ការបំពេញកិច្ច *ហួសពីសមត្ថកិច្ច* មានន័យជាកិច្ចទាំងឡាយដែលធ្វើហួសពីអំណាចដែលប្រគល់ឱ្យនៅក្នុងច្បាប់ ឬ លក្ខន្តិកៈ វចនានុក្រម BLACK'S LAW នៅ ១៦៦២។

[53] *សូមមើល ឧទាហរណ៍* សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០៩) សេចក្តីសម្រេចលើសំណើបន្ទាន់របស់ [redacted] សុំ [redacted] ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ A122/6.1/3 កថាខណ្ឌ ១៤ (លេខក្នុងសំណុំរឿង ០០៣ គឺ D117/1.2)។ មេធាវីការពារក្តីមិនទទួលស្គាល់ភាពអាចអនុវត្តបាននៃសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះចំពោះរឿងក្តី ០០៣ ទេ ដោយសារសេចក្តីសម្រេចនេះអាចត្រូវបានកំហិតត្រឹមតែអង្គហេតុក្នុងរឿងក្តី ០០៤។ មេធាវីការពារក្តីមិនអាចធ្វើការកំណត់នេះបានទេ ដោយសារសេចក្តីសម្រេចនេះត្រូវបានកោសលុប។

Harmon ទេ[54]។ ដោយគ្មានការយល់ស្របពីសហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង សហចៅក្រមស៊ើបអង្កេត Harmon មិនអាចកំណត់ពេលនៃការចូលបង្ហាញខ្លួនលើកដំបូង ឬ ដាក់លោក មាស មុត ឱ្យស្ថិតក្រោមការពិនិត្យឡើយ។

## ៣. សេចក្តីសន្និដ្ឋាន

៣៤. ក្របខ័ណ្ឌច្បាប់នៃ អ.វ.ត.ក. ចែងថា សហចៅក្រមស៊ើបអង្កេតបើកកិច្ចស៊ើបសួររួមគ្នា។ ក្របខ័ណ្ឌច្បាប់នេះ មិនអនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេតម្នាក់ដាក់ជនសង្ស័យណាម្នាក់ឱ្យស្ថិតក្រោមការពិនិត្យដោយឯកតោភាគីតាមវិធាន ៥៧ ឡើយ។ ក្នុងការបំពេញកិច្ចដែលមិនត្រូវបានអនុញ្ញាតដោយកិច្ចព្រមព្រៀង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. ឬ វិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេត Harmon បានបំពេញកិច្ច *ហួសពីសមត្ថកិច្ច* និង បានប្រព្រឹត្តកំហុសលើអង្គច្បាប់ ដែលធ្វើឱ្យដីកាសម្រេចរងការជំទាស់នេះគ្មានសុពលភាព។

### ខ. ដើម្បីជា *ទឡ្ហីករណ៍ (arguendo)* សន្មតថា សហចៅក្រមស៊ើបអង្កេត Harmon អាចចេញដីកាសម្រេចរងការជំទាស់នេះដោយឯកតោភាគីបាន គាត់បានបំពេញកិច្ច *ហួសពីសមត្ថកិច្ច* និង មានកំហុសនៅក្នុងការអនុវត្តវិធាន ៥៧ និង វិធាននីតិវិធីកម្ពុជា និង អន្តរជាតិ នៅពេលគាត់សម្រេចដាក់លោក មាស មុត ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ*

#### ១. សហចៅក្រមស៊ើបអង្កេត Harmon បានបំពេញកិច្ច *ហួសពីសមត្ថកិច្ច* នៅក្នុងការដាក់លោក មាស មុត ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ*

៣៥. សហចៅក្រមស៊ើបអង្កេត Harmon ត្រូវតម្រូវឱ្យអនុវត្តនីតិវិធីជាធរមាននៅ អ.វ.ត.ក.[55]។ វិធាន ៥៧ ពុំមានចែងពីនីតិវិធីណាមួយសម្រាប់ដាក់បុគ្គលណាម្នាក់ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ឡើយ។ ទោះបីជាយ៉ាងនេះក្តី នៅក្នុងការដាក់លោក មាស មុត ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* អនុលោមតាមវិធាន ៥៧ នោះ សហចៅក្រមស៊ើបអង្កេត Harmon បានយល់ឃើញថាលក្ខខណ្ឌតម្រូវនានាផ្នែកច្បាប់សម្រាប់ការដាក់ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ត្រូវបាន

---

[54] វិធាន ១៤(៤) នៃវិធានផ្ទៃក្នុង ចែងថា សេចក្តីសម្រេចដើម្បីផ្ទេរភារកិច្ចបែបនេះ ត្រូវតែធ្វើឡើងរួមគ្នាដោយសហចៅក្រមស៊ើបអង្កេត៖ "វៀរលែងតែសកម្មភាពណា ដែលតម្រូវឱ្យអនុវត្តដោយរួមគ្នា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. និងវិធានផ្ទៃក្នុងនេះ សហចៅក្រមស៊ើបអង្កេតអាចផ្ទេរភារកិច្ច ទៅឱ្យសហចៅក្រមស៊ើបអង្កេតណាមួយក្នុងចំណោមសហចៅក្រមស៊ើបអង្កេតទាំងពីរ តាមរយៈលិខិតរួមគ្នាជាលាយលក្ខណ៍អក្សរ ដើម្បីឱ្យបំពេញកិច្ចតែម្នាក់ឯងបាន"។

[55] មាត្រា ១២(១) នៃកិច្ចព្រមព្រៀង។ មាត្រា ២៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។ វិធាន ២ នៃវិធានផ្ទៃក្នុង។

បំពេញរួចហើយ[56]។ គាត់បានលើកឡើងនូវកត្តាចំនួនបីធ្វើជាសំអាង៖ **ក.** លោក មាស មុត ត្រូវបានជូនដំណឹងអំពី ការចូលបង្ហាញខ្លួនលើកដំបូងដែលបានគ្រោងទុក ប៉ុន្តែ មានចេតនា និង មានបំណងខកខានមិនចូលបង្ហាញខ្លួន ដោយហេតុនោះ វាជាការលះបង់សិទ្ធិមានវត្តមានរបស់ខ្លួន **ខ.** លោក មាស មុត បានបង្ហាញច្បាស់ថាគាត់មិនមានចេតនាចូលបង្ហាញខ្លួននៅចំពោះមុខ អ.វ.ត.ក. នៅថ្ងៃណាមួយនោះទេ និង **គ.** វិធានការសមស្របទាំងអស់ត្រូវបានអនុវត្តរួចហើយ ដើម្បីធានាឲ្យមានការចូលបង្ហាញខ្លួនរបស់លោក មាស មុត នៅ អ.វ.ត.ក.[57]។ សហចៅក្រមស៊ើបអង្កេត Harmon បានបង្កើត និង បានអនុវត្តនីតិវិធីដែលពុំមានចែង ឬ អនុញ្ញាតឲ្យធ្វើបែបនេះនៅក្នុងវិធានផ្ទៃក្នុង។ ក្នុងការធ្វើដូច្នេះ គឺគាត់បានបំពេញកិច្ច *ហួសពីសមត្ថកិច្ច* ។

៣៦. កាលណាមានបញ្ហាចោទណាមួយកើតមានឡើង ដែលមិនត្រូវបានពោលប្រស្រ័យនៅក្នុងវិធានផ្ទៃក្នុង នោះសំណើសុំធ្វើវិសោធនកម្មលើវិធានផ្ទៃក្នុង "*ត្រូវដាក់ជូនទៅ* គណៈកម្មាធិការនីតិវិធី និង វិធានផ្ទៃក្នុងឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន"[58]។ នៅក្នុងកិច្ចប្រជុំពេញអង្គមួយ សហចៅក្រមស៊ើបអង្កេត ចៅក្រមនៃអង្គជំនុំជម្រះ និង កាលណាមានការអនុញ្ញាត សហព្រះរាជអាជ្ញានឹងពិនិត្យមើលឡើងវិញ និង ធ្វើវិសោធនកម្មលើវិធានផ្ទៃក្នុង បើចាំបាច់[59]។ លើកលែងតែមានការចង្អុលបង្ហាញផ្សេងពីនេះ វិសោធនកម្មមួយលើវិធានផ្ទៃក្នុងត្រូវចូលជាធរមាន នៅពេលបោះពុម្ពផ្សាយដោយការិយាល័យរដ្ឋបាល និង មិនត្រូវលើសពីរយៈពេល ១០ ថ្ងៃ ក្រោយពេលទទួលបានការអនុម័តពីកិច្ចប្រជុំពេញអង្គជាភាសាខ្មែរ អង់គ្លេស និង បារាំង[60]។

៣៧. វិធាន ៥៧ នៅមិនទាន់ត្រូវបានធ្វើវិសោធនកម្មនៅឡើយទេ ចាប់តាំងពីពេលដែលវិធានផ្ទៃក្នុងនេះត្រូវបានអនុម័តនៅក្នុងកិច្ចប្រជុំពេញអង្គលើកទីមួយ ដែលបានរៀបចំឡើងនៅថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០០៧។ គ្មានការចង្អុលបង្ហាញណាមួយថា សហចៅក្រមស៊ើបអង្កេត Harmon បានដាក់សំណើសុំធ្វើវិសោធនកម្មលើវិធាន ៥៧ នេះ ជូនគណៈកម្មាធិការនីតិវិធី និង វិធានផ្ទៃក្នុង នៅមុនពេលចេញដីកាសម្រេចរងការជំទាស់នេះទេ។ ទោះបីជាគាត់បានធ្វើសំណើបែបនេះក្តី ក៏គាត់ត្រូវបន្តអនុវត្តវិធាន ៥៧ ក្នុងទម្រង់បច្ចុប្បន្នដដែលសិន លើកលែង និង រហូតទាល់តែវិធាននេះត្រូវបាន

[56] កថាខណ្ឌ ៦៧ នៃដីកាសម្រេចរងការជំទាស់។

[57] *ដូចខាងលើ* កថាខណ្ឌ ៥៩ កថាខណ្ឌ ៦៦។

[58] ការគូសបញ្ជាក់បន្ថែម។

[59] សូមមើល វិធាន ៣(២) វិធាន ១៨(២)-(៤) វិធាន ១៨ (៦)(ក) នៃវិធានផ្ទៃក្នុង។

[60] វិធាន ៣(៣) នៃវិធានផ្ទៃក្នុង។

ធ្វើវិសោធនកម្មរួច។ ការអនុវត្តផ្ទុយពីនេះ នឹងរំលោភលើគោលការណ៍នីត្យានុកូលភាព។

៣៨. តុលាការអនុវត្តច្បាប់ដែលបង្កើតឡើងដោយអង្គនីតិបញ្ញត្តិ។ តុលាការពុំអាចបង្កើតច្បាប់បានឡើយ។ ការបែងចែកអំណាចគឺសំខាន់ នៅពេលគិតទៅដល់ការការពារនៃគោលការណ៍នីត្យានុកូលភាព។ លោក Montesquieu បានពណ៌នាការបែងចែកអំណាចរដ្ឋទាំងបីនៅក្នុងនិក្ខេបបទរបស់លោក ដែលមានចំណងជើងថា *De l'esprit des lois* (ស្មារតីច្បាប់) (ឆ្នាំ ១៧៤៨)។ ដំបូង មានអំណាចធ្វើច្បាប់ ដែលត្រូវបានប្រគល់ទៅឱ្យសភាជាអ្នកតំណាងប្រជាពលរដ្ឋ (អង្គនីតិបញ្ញត្តិ)។ បន្ទាប់ មានអំណាចនីតិប្រតិបត្តិ ដែលជាអ្នកប្រតិបត្តិច្បាប់ (អង្គនីតិប្រតិបត្តិ)។ ចុងក្រោយ មានអំណាចវិនិច្ឆ័យ ដែលដោះស្រាយវិវាទ (តុលាការ)[61]៖ ចៅក្រមគឺជា "មាត់ដែលនិយាយអំពីច្បាប់"៖ "*La juge est la bouche qui pronounce les paroles de la loi*"[62]។ នៅក្នុងច្បាប់ទំនៀមទម្លាប់ស៊ីវិល៖ "គឺអ្នកធ្វើច្បាប់ - រដ្ឋាភិបាល សភា - ដែលជាទូទៅជាអ្នកកំណត់និយមន័យនៃបទល្មើស ខណៈដែលចៅក្រមជាអ្នកវិនិច្ឆ័យក្ដីនៅក្នុងករណីជាក់ស្ដែង នូវទង្វើជាក់លាក់របស់បុគ្គលណាម្នាក់ថាជាជនឧក្រិដ្ឋ ... ចៅក្រមមិនត្រូវបានអនុញ្ញាតឱ្យបំពេញចន្លោះប្រហោងនៅក្នុងច្បាប់ ដែលបន្សល់ទុកដោយអ្នកធ្វើច្បាប់នោះទេ"[63]។

៣៩. ជាជាងអនុវត្តតាមវិធាន ៥៧ ឬ ស្នើសុំឱ្យធ្វើវិសោធនកម្មលើវិធាន ៥៧ ដើម្បីអាចដាក់បុគ្គលណាម្នាក់ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* បាន សហចៅក្រមស៊ើបអង្កេត Harmon បែរជាបានបង្កើតនីតិវិធីរបស់ខ្លួនផ្ទាល់។ គាត់បានដណ្ដើមដោយពុំសមហេតុផលនូវអំណាចនីតិប្រតិបត្តិ ដែលត្រូវអនុវត្តនៅក្នុងកិច្ចប្រជុំពេញអង្គ។ នៅក្នុងការបំពេញកិច្ច *ហួសពីសមត្ថកិច្ច នេះ* គាត់មានកំហុសអង្គច្បាប់ និង បានបំពានលើឆន្ទានុសិទ្ធិរបស់ខ្លួន។

---

[61] រឿងក្ដី ROELOF HAVEMAN និង អ្នកផ្សេងទៀត ច្បាប់ព្រហ្មទណ្ឌពហុជាតិ៖ ប្រព័ន្ធតែមួយគត់ (SUPRANATIONAL CRIMINAL LAW: A SYSTEM *SUI GENERIS*) ទំព័រ ៥១ ដល់ ៥២ (Intersentia ឆ្នាំ ២០០៣)។

[62] MACHTELD BOOT គ្មានបទល្មើស បើគ្មានច្បាប់ចែង និង យុត្តាធិការតាមសាច់រឿងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ៖ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង ឧក្រិដ្ឋកម្មសង្គ្រាម (NULLUM CRIMEN SINE LEGE AND THE SUBJECT MATTER JURISDICTION OF THE INTERNATIONAL CRIMINAL COURT: GENOCIDE, CRIMES AGAINST HUMANITY, AND WAR CRIMES) 83 (Intersentia ឆ្នាំ ២០០២)។

[63] រឿងក្ដី HAVEMAN និង អ្នកផ្សេងទៀត ត្រង់ ៥២។

## ២. សហចៅក្រមស៊ើបអង្កេត Harmon មានកំហុសនៅក្នុងការបកស្រាយ វិធានផ្ទៃក្នុង គិតដល់ការបញ្ជាក់អះអាង ច្បាប់ស៊ីវិលនៅ អ.វ.ត.ក.

### ក. សហចៅក្រមស៊ើបអង្កេត Harmon យល់ខុស និង បកស្រាយ ខុសវិធាន ៥៧

៤០. សហចៅក្រមស៊ើបអង្កេត Harmon បានបកស្រាយវិធាន ៥៧ ដោយភ័ន្តច្រឡំ ក្នុងការយល់ឃើញថា វិធាននេះពុំតម្រូវឱ្យមានវត្តមានផ្ទាល់របស់ជនត្រូវចោទនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ហើយថា វិធានផ្ទៃក្នុងពុំបានពោលប្រស្រ័យអំពីការដាក់ឱ្យស្ថិតក្រោមការពិនិត្យនូវជនត្រូវចោទដែលបដិសេធមិនចូលបង្ហាញខ្លួន ហើយដែលការចូលបង្ហាញខ្លួននោះមិនអាចត្រូវបានធានាឱ្យមានតាមការបង្គាប់បញ្ជា[64]។ គាត់បានប្រៀបធៀបដោយមិនត្រឹមត្រូវរវាងវិធាន ៥៧ ជាមួយនឹងវិធាន ៨១ ដោយបានទាញការសន្និដ្ឋានដោយមិនត្រឹមត្រូវថា ពីព្រោះវិធាន ៨១ មានបទប្បញ្ញត្តិស្តីពីការជំនុំជម្រះ*កំបាំងមុខ* កង្វះការអនុញ្ញាតច្បាស់លាស់ទាក់ទងនឹងការបង្ហាញខ្លួនលើកដំបូង *ដោយកំបាំងមុខ* របស់វិធាន ៥៧ មានន័យថា បញ្ហានេះមិនត្រូវបានបញ្ញត្តិដោយវិធានផ្ទៃក្នុងឡើយ[65]។

៤១. ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[66] អនុវត្តតែនៅក្នុងករណីដែល "បញ្ហាចោទណាមួយមិនត្រូវបានចែងដោយវិធានផ្ទៃក្នុងប៉ុណ្ណោះ"[67]។ សហចៅក្រមស៊ើបអង្កេត អាចពិនិត្យមើលវិធាននីតិវិធីអន្តរជាតិ កាលណាច្បាប់កម្ពុជាមិនបានដោះស្រាយបញ្ហាជាក់លាក់ណាមួយ ឬ កាលណាមានភាពមិនច្បាស់លាស់ណាមួយទាក់ទងនឹងវិធានពាក់ព័ន្ធក្នុងច្បាប់កម្ពុជា ឬ មានភាពមិនស៊ីសង្វាក់គ្នាជាសក្តានុភូត

---

[64] កថាខណ្ឌ ៣៦ នៃដីកាសម្រេចរងការជំទាស់។

[65] *សូមមើល ដូចខាងលើ* កថាខណ្ឌ ៣៥-៣៧។

[66] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧។

[67] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាបដិសេធពាក្យសុំមោឃភាព ចុះថ្ងៃទី ២៦ ខែ សីហាឆ្នាំ ២០០៨ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាបដិសេធពាក្យសុំមោឃភាព") ឯកសារ D55/I/8 កថាខណ្ឌ ១៥។ *សូមមើលផងដែរ រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ១៥) សេចក្តីសម្រេចលើពាក្យសុំបន្ថែមរបស់ ខៀវ សំផន សុំការដោះលែងឱ្យមានសេរីភាព ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ ២០០៨ ឯកសារ C26/5/5 កថាខណ្ឌ ១៧ ដោយបានយល់ឃើញថា បទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា "មិនអាចអនុវត្តបានទេ ដោយសារវិធានផ្ទៃក្នុងចែងយ៉ាងច្បាស់ពីបញ្ហាយុត្តាធិការលើការដោះលែងឱ្យមានសេរីភាពជាបណ្តោះអាសន្ន"។

ណាមួយជាមួយនឹងបទដ្ឋានអន្តរជាតិ[68]។ ក្នុងការអនុវត្តវិធាននីតិវិធី សហចៅក្រមស៊ើបអង្កេតត្រូវអនុវត្តស្របតាមវិធាន ២១ ជាប់ជានិច្ច[69]។ ដោយសារថា នីតិវិធី អ.វ.ត.ក. ត្រូវតែអនុលោមតាមនីតិវិធីកម្ពុជា ដែលមានមូលដ្ឋានមកពីច្បាប់ស៊ីវិល នោះវិធានផ្ទៃក្នុងត្រូវតែត្រូវបានបកស្រាយដោយប្រកាន់ស្របទៅតាមបរិបទច្បាប់ស៊ីវិលជានិច្ច។

៤២. នៅក្នុងយុត្តាធិការច្បាប់ស៊ីវិល ជំនឿទុកចិត្តត្រូវបានទុកដាក់លើក្រមច្បាប់ ដែលបញ្ជាក់ច្បាស់អំពីបញ្ហានានា ដែលអាចត្រូវបាននាំមកនៅចំពោះមុខតុលាការ លើវិធាននីតិវិធីជាធរមាន និង លើទណ្ឌកម្មនានាទៅតាមបទល្មើសដែលបានរៀបរាប់ទាំងនោះ[70]។ ចៅក្រមបំពេញកិច្ចនៅក្នុងដែនកំណត់នៃនីតិវិធីនៅក្នុងក្រម ក្នុងការស្រាវជ្រាវរកពីបទប្បញ្ញត្តិច្បាប់នានានូវអំពើទាំងឡាយដែលអាចត្រូវបានប្រព្រឹត្ត ។

៤៣. ដើម្បីកំណត់ចេតនានៃវិធានណាមួយបាន និង ដូចដែលបានលើកឡើង *ខាងលើ* នៅក្នុងកថាខណ្ឌ ២៣-២៤ សហចៅក្រមស៊ើបអង្កេត និង អង្គបុរេជំនុំជម្រះ ត្រូវអនុវត្តគោលការណ៍នៃការបកស្រាយច្បាប់ ដូចមានចែងនៅក្នុងអនុសញ្ញា VCLT។ ដោយហេតុថាវិធានផ្ទៃក្នុងកើតចេញពីកិច្ចព្រមព្រៀង ដែលត្រូវគោរពតាមអនុសញ្ញា VCLT វិធានផ្ទៃក្នុងនេះក៏ត្រូវតែបានបកស្រាយឱ្យស្របតាមអនុសញ្ញា VCLT ដែរ។

៤៤. វិធានផ្ទៃក្នុងត្រូវតែបានបកស្រាយដោយសុចរិត ស្របតាមអត្ថន័យធម្មតារបស់វា នៅក្នុងបរិបទរបស់វា និង ទៅគិតទៅដល់កម្មវត្ថុ និង គោលបំណងនៃវិធាននេះ[71]។ ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេត ដំបូង ត្រូវពិនិត្យទៅលើអត្ថន័យធម្មតានៃវិធាន ៥៧ ជាមុនសិន។ សហចៅក្រមស៊ើប

---

[68] មាត្រា ១២(១) នៃកិច្ចព្រមព្រៀង។ *សូមមើលផងដែរ* មាត្រា ២៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។ វិធាន ២ នៃវិធានផ្ទៃក្នុង។

[69] វិធាន ២ នៃវិធានផ្ទៃក្នុង។

[70] JAMES G. APPLE និង អ្នកផ្សេងទៀត ស្រទាប់ដំបូងគេនៃប្រព័ន្ធច្បាប់ស៊ីវិល (A Primer on the Civil Law System) ៣៧ (Federal Judicial Center ឆ្នាំ ១៩៩៥) នៅក្នុងច្បាប់ទំនៀមទម្លាប់ស៊ីវិល ការរកហេតុផលគឺធ្វើឡើងពីលើចុះក្រោម ចាប់ផ្តើមពីគោលការណ៍ទូទៅ ឬ វិធានច្បាប់ដែលមាននៅក្នុងក្រមច្បាប់ ទៅរកដំណោះស្រាយជាក់លាក់មួយ។ នៅក្នុងប្រទេសដែលអនុវត្តប្រព័ន្ធច្បាប់ខំមិនឡ (common law) ដំណើរការនេះគឺបញ្ច្រាស ពោលគឺ ចៅក្រមអនុវត្តតាមវិធីរកហេតុផលពីក្រោមឡើងទៅលើ ទាញពីគោលការណ៍ទូទៅ ឬ វិធានច្បាប់ដែលចេញមកពីយុត្តិសាស្ត្រ ឬ សេចក្តីសម្រេចជាក់លាក់នានា និង ដកស្រង់វិធានជាធរមាន ហើយអនុវត្តទៅលើករណីជាក់លាក់។ *អាចរកបានតាមគេហទំព័រ* http://www.fjc.gov/public/pdf.nsf/lookup/CivilLaw.pdf/$file/CivilLaw.pdf។

[71] មាត្រា ៣១(១) នៃអនុសញ្ញា VCLT។

អង្កេតត្រូវសន្មតថា អ្នកព្រាងវិធានផ្ទៃក្នុងបាននិយាយអ្វីដែលពួកគេមានបំណង និង មានបំណងចង់បានអ្វីដែលពួកគេបាននិយាយ រួមទាំងករណីលើកលែងនៅក្នុងវិធានផ្ទៃក្នុងផងដែរ។ អត្ថន័យធម្មតានៃវិធាន ៥៧ គូសបង្ហាញថា មិនដូចទៅនឹងការជំនុំជម្រះដែលចែងនៅក្នុងវិធាន ៨១ ទេ ការបង្ហាញខ្លួនដោយផ្ទាល់គឺតម្រូវឱ្យមានសម្រាប់ការបង្ហាញខ្លួនលើកដំបូង។ គ្មានការចាំបាច់ត្រូវពិនិត្យមើលវិធានកម្ពុជា ឬ អន្តរជាតិឡើយ។

៤៥. *ការបង្ហាញខ្លួនលើកដំបូង* គឺជា "សវនាការ ដែលក្នុងអំឡុងពេលនោះ ជនត្រូវចោទ *បង្ហាញខ្លួនជាលើកដំបូងនៅចំពោះមុខ* សហចៅក្រមស៊ើបអង្កេត ហើយជននោះត្រូវប្រាប់ឱ្យដឹងអំពីបទចោទប្រកាន់"[72]។ អត្ថន័យធម្មតានៃពាក្យថា *បង្ហាញខ្លួន* ចង្អុលបង្ហាញថា ត្រូវមានវត្តមាននៅទីកន្លែង ឧទាហរណ៍ *បង្ហាញខ្លួន*[73] ឬ *ចូលរួម* ឬ *មានវត្តមាន*[74]។ អត្ថន័យច្បាប់នៃពាក្យ *បង្ហាញខ្លួន* ឬ *ការបង្ហាញខ្លួន* មានន័យថា *ការចូលមកកាន់តុលាការក្នុងនាមភាគី ឬ បុគ្គលមានផលប្រយោជន៍ម្នាក់*[75] *ឈរនៅចំពោះមុខអាជ្ញាធរសាលាក្តីណាមួយ*[76] ឬ *បង្ហាញខ្លួនដោយផ្ទាល់ជាផ្លូវការនៅតុលាការ*[77]។ អត្ថន័យធម្មតានៃពាក្យទាំងនេះ គឺមិនស្រពិចស្រពិល និង ច្បាស់លាស់។

៤៦. បទប្បញ្ញត្តិនៃវិធាន ៥៧ បញ្ជាក់បន្ថែមទៀតថា ការបង្ហាញខ្លួនលើកដំបូងត្រូវធ្វើឡើងដោយផ្ទាល់។ "នៅពេលចូលបង្ហាញខ្លួនលើកដំបូង"[78] សហចៅក្រមស៊ើបអង្កេតត្រូវកត់ត្រាទុកនូវអត្តសញ្ញាណរបស់ជនត្រូវចោទ ប្រាប់អ្នកនោះពីបទចោទប្រកាន់ និង ពីសិទ្ធិរបស់គាត់ក្នុងការមានមេធាវី និង

---

[72] សទ្ទានុក្រមនៃវិធានផ្ទៃក្នុង (ការគូសបញ្ជាក់បន្ថែម)។

[73] *សូមមើល* និយមន័យនៃពាក្យ *បង្ហាញខ្លួន* នៅក្នុងវចនានុក្រម Merriam-Webster *អាចរកបាននៅ* http://www.merriam-webster.com/dictionary/appear។

[74] *សូមមើល* និយមន័យនៃពាក្យ *បង្ហាញខ្លួន* នៅក្នុងវចនានុក្រម Cambridge នៅលើអ៊ីនធើណេត *អាចរកបាននៅ* http://dictionary.cambridge.org/dictionary/british/appear។

[75] វចនានុក្រម Black's Law ត្រង់ ១១៣។

[76] *សូមមើល* និយមន័យនៃពាក្យ *បង្ហាញខ្លួន* នៅក្នុងវចនានុក្រម Webster *អាចរកបាននៅ* http://www.webster-dictionary.org/definition/Appear។

[77] *សូមមើល* និយមន័យនៃពាក្យ *បង្ហាញខ្លួន* នៅក្នុងវចនានុក្រម Oxford *អាចរកបាននៅ* http://www.oxforddictionaries.com/definition/english/appear។ *សូមមើលផងដែរ* និយមន័យនៃពាក្យ *បង្ហាញខ្លួន* នៅក្នុងវចនានុក្រម Collins *អាចរកបាននៅ* http://www.collinsdictionary.com/dictionary/english/appear?showCookiePolicy=true។

[78] វិធាន ៥៧(១) នៃវិធានផ្ទៃក្នុង។

សិទ្ធិនៅស្ងៀមមិនឆ្លើយតប[79]។ យ៉ាងសំខាន់បំផុតនោះ សហចៅក្រមស៊ើបអង្កេត "ត្រូវធ្វើការសួរចម្លើយភ្លាម" ប្រសិនបើជនត្រូវចោទយល់ព្រម[80]។ ជនត្រូវចោទ អាចអាងលើសិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ខ្លួន នៅឯការបង្ហាញខ្លួនលើកដំបូងរបស់គាត់ និង អាចបដិសេធមិនផ្តល់ចម្លើយបាន ដែលជាសិទ្ធិរបស់គាត់អនុលោមតាមវិធាន ៥៧។ ការបដិសេធនេះមិនធ្វើឲ្យការតម្រូវឲ្យជនត្រូវចោទចូលបង្ហាញខ្លួនជាលើកដំបូងនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ទៅជាឥតបានការនោះទេ។ ជនត្រូវចោទត្រូវផ្តល់ផងដែរនូវអាសយដ្ឋានរបស់ខ្លួនឲ្យសហចៅក្រមស៊ើបអង្កេត ប្រសិនបើជននោះពុំត្រូវបានឃុំខ្លួន នៅក្រោយពេលចូលបង្ហាញខ្លួនលើកដំបូង[81]។ ប្រសិនបើការបង្ហាញខ្លួនដោយផ្ទាល់មិនត្រូវបានតម្រូវឲ្យមាន នោះវាគ្មានហេតុផលអ្វីដែលត្រូវព្រាងវិធាន ៥៧ ដោយចែងពីសិទ្ធិក្នុងការផ្តល់ចម្លើយភ្លាមៗ និង ការតម្រូវឲ្យជូនដំណឹងអំពីអាសយដ្ឋានដល់សហចៅក្រមស៊ើបអង្កេតនោះឡើយ។

៤៧. សហចៅក្រមស៊ើបអង្កេត Harmon បកស្រាយវិធាន ៨១ នៃវិធានផ្ទៃក្នុង តាមបែបផែនមួយ ដើម្បីគាំទ្រសេចក្តីសន្និដ្ឋានដែលមានស្រាប់ជាមុនរបស់គាត់ ដែលថា វិធាន ៥៧ មិនតម្រូវឲ្យមានការបង្ហាញខ្លួនលើកដំបូងដោយផ្ទាល់។ វិធាន ៨១(៤) អនុញ្ញាតឲ្យធ្វើការជំនុំជម្រះ *ដោយកំបាំងមុខ* បាន នៅពេលដែលជនជាប់ចោទ *ក្រោយការបង្ហាញខ្លួនលើកដំបូង* បដិសេធ ឬ ខកខានមិនបានចូលរួម ឬ ត្រូវបានបណ្តេញចេញពីកិច្ចដំណើរការនីតិវិធី ។ ដូច្នេះ វិធាន ៨១ កំណត់ការបង្ហាញខ្លួនលើកដំបូងជា *បុរេលក្ខខណ្ឌ* សម្រាប់ដំណើរការជំនុំជម្រះ *ដោយកំបាំងមុខ*។

៤៨. វិធាន ៨១ និង វិធាន ៥៧ ទាក់ទងនឹងដំណាក់កាលនីតិវិធីខុសគ្នា៖ វិធាន ៨១ ទាក់ទងនឹងដំណាក់កាលជំនុំជម្រះ រីឯ វិធាន ៥៧ ទាក់ទងនឹងដំណាក់កាលមុនជំនុំជម្រះ។ ករណីលើកលែងនានានៅក្នុងវិធាន ៨១ មិនអាចត្រូវបានយកមកប្រើប្រាស់ ដើម្បីទាញសេចក្តីសន្និដ្ឋានអំពីអត្ថិភាព ឬ នត្ថិ

---

[79] នីតិវិធីទាំងនេះត្រូវបានអនុវត្តដោយសហចៅក្រមស៊ើបអង្កេត ឧទាហរណ៍ នៅពេលដែលលោក កាំង ហ្គេកអ៊ាវ *ហៅ* ឌុច លោក នួន ជា និង លោក អៀង សារី ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យ អនុលោមតាមវិធាន ៥៧ បន្ទាប់ពីចូលបង្ហាញខ្លួនលើកដំបូងដោយផ្ទាល់។ *រឿងក្តី កាំង ហ្គេកអ៊ាវ* ហៅ "*ឌុច*" ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៧ ឯកសារ E3/915។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ នួន ជា ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧ ឯកសារ E3/54។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ នួន ជា ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ឯកសារ E3/92។

[80] វិធាន ៥៧(១) នៃវិធានផ្ទៃក្នុង។

[81] វិធាន ៥៧(៣) នៃវិធានផ្ទៃក្នុង។

ភាពនៃវិធាននីតិវិធីនៅក្នុងដំណាក់កាលមុនជំនុំជម្រះបាននោះទេ។ ករណីលើកលែងនៅក្នុងច្បាប់ត្រូវតែត្រូវបានបកស្រាយក្នុងន័យចង្អៀត ជាពិសេស នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល ដែលពឹងផ្អែកលើវិធាន និង នីតិវិធី ដែលចងក្រងជាក្រម[82]។ ការបង្ហាញខ្លួនលើកដំបូងត្រូវធ្វើឡើងដោយមានវត្តមានផ្ទាល់។ គ្មានករណីលើកលែង។

### ខ. លោក Harmon មានកំហុសនៅក្នុងការអនុវត្ត និង ការបកស្រាយវិធាននីតិវិធីកម្ពុជា

៤៩. ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា អនុវត្តតែកាលណាមានបញ្ហាចោទណាមួយលេចឡើង ដែលពុំត្រូវបានពោលប្រស្រ័យដោយវិធានផ្ទៃក្នុងប៉ុណ្ណោះ[83]។ ដូចដែលបានពន្យល់បង្ហាញខាងលើ វាមិនមែនជាករណីនៅទីនេះទេ។ នៅពេលបកស្រាយឱ្យបានត្រឹមត្រូវតាមលក្ខណៈច្បាប់ស៊ីវិលនៃ អ.វ.ត.ក. វិធានផ្ទៃក្នុងមិនអនុញ្ញាតឱ្យមានការដាក់ក្រោមការពិនិត្យ *ដោយកំបាំងមុខ* នោះទេ។ សហចៅក្រមស៊ើបអង្កេត Harmon មានកំហុសនៅក្នុងការពិចារណាទៅលើក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[84]។

៥០. សហចៅក្រមស៊ើបអង្កេត Harmon ដកស្រង់បទប្បញ្ញត្តិក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាជាសំអាងទាក់ទងនឹងកិច្ចដំណើរការនីតិវិធីនៅដំណាក់កាលជំនុំជម្រះ ដើម្បីគាំទ្រសេចក្តីសន្និដ្ឋានថា ការបង្ហាញខ្លួនលើកដំបូងអាចត្រូវបានធ្វើឡើង *ដោយកំបាំងមុខ*បាន[85]។ការយោងបែបនេះគឺមិនត្រឹមត្រូវ។

---

[82] ក្រុមប្រឹក្សាធម្មនុញ្ញបារាំង ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៦ សេចក្តីសម្រេចលេខ ២០០៦-៥៤០ DC *ការសើរើធម្មនុញ្ញភាពនៃច្បាប់ទាក់ទងនឹងកម្មសិទ្ធិបញ្ញា និង សិទ្ធិពាក់ព័ន្ធផ្សេងទៀតនៅក្នុងសង្គមព័ត៌មាន* កថាខណ្ឌ ៩ (ឯកសារបកប្រែផ្លូវការ)៖ "សភាត្រូវអនុវត្តអំណាចពេញលេញដែលបានផ្តល់ឱ្យដោយរដ្ឋធម្មនុញ្ញ...។ ការអនុវត្តពេញលេញនៃអំណាចនេះ... តម្រូវឱ្យសភាមានភារកិច្ចអនុម័តបទប្បញ្ញត្តិទាំងឡាយ ដែលមានលក្ខណៈច្បាស់លាស់ និង ជាក់លាក់គ្រប់គ្រាន់។ ការការពារត្រូវអនុវត្តចំពោះគ្រប់បុគ្គលទាំងអស់ពីការបកស្រាយទាំងឡាយណាដែលផ្ទុយនឹងរដ្ឋធម្មនុញ្ញ ឬ ពីហានិភ័យនៃសេចក្តីសម្រេចតាមទំនើងចិត្ត ដោយមិនត្រូវទុកអំណាចនេះឱ្យតុលាការច្បាប់ ឬ អាជ្ញាធររដ្ឋបាលជាអ្នកចេញវិធានដែលរដ្ឋធម្មនុញ្ញផ្តល់ឱ្យ ដោយគួរតែទុកឱ្យបទប្បញ្ញត្តិច្បាប់តែគត់។" *អាចរកបាននៅលើ* គេហទំព័រ http://www.conseil-constitutionnel.fr/conseil-constitutionnel/root/bank/download/2006540DCen2006 _540dc.pdf។

[83] កថាខណ្ឌ ១៥ នៃសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព។

[84] កថាខណ្ឌ ៣៩ នៃដីកាសម្រេចរងការជំទាស់។

[85] *សូមមើល ឧទាហរណ៍* មាត្រា ៣៣៣ មាត្រា ៣៥១ មាត្រា ៣៦១-៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

វិធាននីតិវិធីទាក់ទងនឹងដំណាក់កាលជំនុំជម្រះ មិនអាចត្រូវបានពន្លាត ដោយធៀបទៅនឹងដំណាក់កាលស៊ើបសួរបានឡើយ[86]។

៥១. សហចៅក្រមស៊ើបអង្កេត Harmon ព្រងើយកន្តើយចំពោះបទប្បញ្ញត្តិក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដែលពោលប្រស្រ័យអំពីការបង្ហាញខ្លួនលើកដំបូង។ បទប្បញ្ញត្តិទាំងនេះចែងថា កាលណាជនសង្ស័យត្រូវបានកោះហៅត្រឹមត្រូវតាមផ្លូវច្បាប់ឱ្យចូលបង្ហាញខ្លួនលើកដំបូង ការបង្ហាញខ្លួននេះត្រូវធ្វើឡើងដោយមានវត្តមានផ្ទាល់។ មាត្រា ១៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ទាក់ទងនឹងបុគ្គលណា ដែលធ្វើការបង្ហាញខ្លួនលើកដំបូងនៅចំពោះមុខចៅក្រមស៊ើបសួរ។ វាស្របនឹងវិធាន ៥៧ ដែលចែងត្រង់បទប្បញ្ញត្តិពាក់ព័ន្ធថា៖

> *នៅពេលចូលបង្ហាញខ្លួនលើកដំបូង* ចៅក្រមស៊ើបសួរពិនិត្យអត្តសញ្ញាណជនត្រូវចោទ ប្រាប់ជននេះឱ្យបានដឹងរឿងរ៉ាវដែលចោទប្រកាន់ និង ប្រាប់អំពីឈ្មោះបទល្មើសដែលកំណត់ដោយច្បាប់។ ចៅក្រមស៊ើបសួរប្រាប់ជនត្រូវចោទថា ខ្លួនអាចឆ្លើយ ឬ មិនឆ្លើយបានដោយសេរី។ និទ្ទេសស្ដីពីការប្រាប់នេះ ត្រូវចុះនៅក្នុងកំណត់ហេតុនៅពេលចូលបង្ហាញខ្លួនលើកដំបូង។
>
> បើជនត្រូវចោទចង់ឆ្លើយនោះ ចៅក្រមស៊ើបសួរ *ត្រូវទទួលចម្លើយនោះភ្លាម*[87]។

៥២. អត្ថន័យធម្មតានៃមាត្រា ១៤៣ តម្រូវឱ្យមានការចូលបង្ហាញខ្លួនលើកដំបូងដោយផ្ទាល់ ជាបឋមដើម្បីអនុញ្ញាតឱ្យចៅក្រមស៊ើបសួរទទួលយកចម្លើយរបស់ជនត្រូវចោទភ្លាម ប្រសិនណាចាំបាច់។ មាត្រា ២៤១ ដែលទាក់ទងនឹងការធ្វើកំណត់ហេតុនៅពេលចូលបង្ហាញខ្លួនលើកដំបូង គាំទ្រការបកស្រាយនេះ ចំពោះមាត្រា ១៤៣។ មាត្រា ២៤១ តម្រូវថា ចៅក្រមស៊ើបសួរ ក្រឡាបញ្ជី និង "បុគ្គលដែលពាក់ព័ន្ធ" ចុះហត្ថលេខាលើគ្រប់ទំព័រនៃកំណត់ហេតុស្ដីពីការចូលបង្ហាញខ្លួនលើក

---

[86] ការហាមឃាត់ប្រឆាំងនឹងការប្រៀបធៀបនេះកើតចេញពីគោលការណ៍ *គ្មានបទល្មើស ប្រសិនបើគ្មានច្បាប់ចែង និង គ្មានទោស បើគ្មានច្បាប់ចែង (nullen crimen sine lege, nulla poena sine lege)* ដែលជាផ្នែកមួយនៃគោលការណ៍ច្បាប់ និងគោលការណ៍បកស្រាយច្បាប់ដែលតម្រូវឱ្យច្បាប់ព្រហ្មទណ្ឌត្រូវបាន៖ "ព្រាងឱ្យបានច្បាស់លាស់ (គោលការណ៍នៃភាពជាក់លាក់) បកស្រាយឱ្យបានតឹងរ៉ឹងដោយគ្មានការពន្លាតដោយធៀប ហើយភាពមិនច្បាស់លាស់ត្រូវដោះស្រាយឱ្យបានជាប្រយោជន៍ដល់ជនជាប់ចោទ (គោលការណ៍ នៃការបន្ធូរបន្ថយ ឬ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ (in dubio pro reo)*។ Beth Van Schaack គ្មានបទល្មើស បើគ្មានច្បាប់ចែង៖ *ការធ្វើច្បាប់ដោយតុលាការ នៅឯផ្លូវបំបែកនៃច្បាប់ និង សីលធម៌* (Crimen Sine Lege: Judical Lawmaking at the Intersection of Law and Morals) 119 Georgetown L. J. 121 (ឆ្នាំ២០០៨) *អាចរកបាននៅ* http://georgetownlawjournal.org/files/pdf/97-1/VanSchaack.PDF។

[87] ការគូសបញ្ជាក់បន្ថែម។

ដំបូង។ កំណត់ហេតុត្រូវកត់ត្រាអាសយដ្ឋានរបស់ជនជាប់ចោទ ហើយជនជាប់ចោទត្រូវបានជូនដំណឹងអំពីបទចោទ និង សិទ្ធិក្នុងការផ្តល់ចម្លើយ។ ចម្លើយរបស់ជនជាប់ចោទអំពីបទចោទក៏ត្រូវកត់ត្រាទុកផងដែរ។ នៅពេលអានរួមគ្នាជាមួយនឹងមាត្រា ២៤១ មាត្រា ១៤៣ ចែងរំពឹងទុកដោយប្រាកដប្រជាថា ជនត្រូវចោទចូលបង្ហាញខ្លួនលើកដំបូង *ដោយផ្ទាល់* នៅចំពោះមុខចៅក្រមស៊ើបសួរ។

៩៣. ពុំមានបទប្បញ្ញត្តិណាមួយនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា សម្រាប់បន្តចាត់នីតិវិធីបង្ហាញខ្លួនលើកដំបូង *ដោយកំបាំងមុខ* នោះទេ កាលណាដីកាបង្គាប់ឱ្យចាប់ខ្លួនពុំទាន់ត្រូវបានអនុវត្ត ហើយនគរបាលយុត្តិធម៌ ពុំទាន់បានជូនដំណឹងដល់ចៅក្រមស៊ើបសួរអំពីការលំបាកទាំងនេះក្នុងពេលអនុវត្តបេសកកម្មរបស់ខ្លួន[88]។ អ្នកព្រាងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាត្រូវបានសន្មតថា បានចែងដោយមានចេតនាដូច្នេះ នៅពេលព្រាងក្រមនេះ។ នៅពេលបកស្រាយក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឱ្យបានត្រឹមត្រូវទៅតាមមូលដ្ឋាននៃច្បាប់ស៊ីវិល[89] និង គោលបំណងនៃការបង្ហាញខ្លួនលើកដំបូង សេចក្តីសន្និដ្ឋានសមហេតុផលតែមួយគត់នោះគឺថា ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាពុំអនុញ្ញាតឱ្យធ្វើការបង្ហាញខ្លួនលើកដំបូង *ដោយកំបាំងមុខ* នោះឡើយ។

៩៤. សហចៅក្រមស៊ើបអង្កេត Harmon យោងអត្ថបទសារព័ត៌មានកម្ពុជាមិនពាក់ព័ន្ធមួយចំនួន ទាក់ទងនឹងការជំនុំជម្រះ *ដោយកំបាំងមុខ*[90]។ អត្ថបទសារព័ត៌មានពុំមែនជាប្រភពនៃច្បាប់ ឬ នៃនីតិវិធីរបស់ អ.វ.ត.ក. ឬ របស់កម្ពុជានោះឡើយ[91] ហើយវាប្លែករួចជាស្រេចពីស្ថានភាពរបស់លោក

---

[88] មាត្រា ១៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

[89] *សូមមើល រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៧១) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស. បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់ អៀង សារី តបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ និង សេចក្តីសង្កេតបន្ថែម និង សំណើសុំផ្អាកដំណើរការនីតិវិធី ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ ២០១០ ឯកសារ D390/1/2/4 កថាខណ្ឌ ១៧។ *សូមមើលផងដែរ រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សេចក្តីសម្រេចលើសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខក្នុងរឿងក្តី ០០២/០១ ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ F10/2 កថាខណ្ឌ ១៣។

[90] កថាខណ្ឌ ៤០ នៃដីកាសម្រេចរងការជំទាស់។

[91] សហចៅក្រមស៊ើបអង្កេត Harmon ហាក់ដូចជាទទួលស្គាល់ករណីនេះដោយបានលើកឡើងថា គាត់បានសំអាងលើអត្ថបទសារព័ត៌មានទាំងនេះក្នុងគោលបំណងតែមួយគត់ គឺដើម្បីបញ្ជាក់ថា ការជំនុំជម្រះ *ដោយកំបាំងមុខ* បានធ្វើឡើងនៅក្នុងប្រទេសកម្ពុជា។ *ដូចខាងលើ*។

មាស មុត។ មិនដូចជនជាប់ចោទនៅក្នុងអត្ថបទសារព័ត៌មានទាំងនោះឡើយ លោក មាស មុត ពុំបានរត់គេចខ្លួន ឬ គៀសខ្លួននោះទេ។

៥៥. សហចៅក្រមស៊ើបអង្កេត Harmon បានបកស្រាយខុស និង បានអនុវត្តមិនត្រឹមត្រូវទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ ការអានដោយប្រុងប្រយ័ត្ននិងទូលំទូលាយចង្អុលបង្ហាញថា ការបង្ហាញខ្លួនលើកដំបូង (ដែលធ្វើឡើងដោយមានសុពលភាព) ត្រូវតែធ្វើឡើងដោយផ្ទាល់ ហើយជនសង្ស័យមិនអាចត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* នោះទេ។ សហចៅក្រមស៊ើបអង្កេត Harmon មានកំហុសអង្គច្បាប់ក្នុងការបកស្រាយ និង ការអនុវត្តវិធានកម្ពុជា។

### គ. សហចៅក្រមស៊ើបអង្កេត Harmon បកស្រាយមិនត្រឹមត្រូវនូវវិធាននីតិវិធីព្រហ្មទណ្ឌបារាំងទាក់ទងនឹងការបង្ហាញខ្លួនលើកដំបូង

៥៦. សហចៅក្រមស៊ើបអង្កេត Harmon បានយល់ឃើញថា សេចក្តីសន្និដ្ឋានរបស់គាត់ដែលថា កិច្ចដំណើរការនីតិវិធី *ដោយកំបាំងមុខ* ត្រូវបានអនុញ្ញាតឲ្យធ្វើទៅបាននៅក្នុងប្រទេសកម្ពុជានោះ គឺស៊ីសង្វាក់នឹងច្បាប់បារាំង។ គាត់បានបកស្រាយមាត្រា ១៣៤[92] និង មាត្រា ១៧៦[93] នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ដែលចែងថា ក្រោយពេលនគរបាលធ្វើរបាយការណ៍អំពីការស្រាវជ្រាវដែលគ្មានផលផ្លែផ្ការួចមក ជនសង្ស័យអាចត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ[94]។ ការបកស្រាយរបស់គាត់លើក្រមនីតិវិធីព្រហ្មទណ្ឌបារាំងក្នុងន័យបែបនេះ គឺពុំត្រឹមត្រូវ។

៥៧. សហចៅក្រមស៊ើបអង្កេត Harmon ដកចោលនូវចំណុចខុសគ្នានៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌបារាំងរវាងការបង្ហាញខ្លួនលើកដំបូង និង ការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលជានីតិវិធីពីរដោយឡែកពីគ្នា[95]។ ការបង្ហាញខ្លួនលើកដំបូងអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌបារាំងគឺស្រដៀងគ្នានឹងវិធាន ៥៧ ស្តីពីការបង្ហាញខ្លួនលើកដំបូង។ ផ្ទុយមកវិញ ការដាក់ឲ្យស្ថិតក្រោម

---

[92] មាត្រា ១៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំងចែងថា ក្នុងករណីបុគ្គលម្នាក់ពុំអាចត្រូវបានចាប់ខ្លួនយោងតាមដីកាចាប់ខ្លួននោះទេ "របាយការណ៍ផ្លូវការស្តីពីការស្រាវជ្រាវរកមិនឃើញ ត្រូវបញ្ជូនទៅចៅក្រមដែលចេញដីកានេះ។ បន្ទាប់មក ជនពាក់ព័ន្ធនេះអាចត្រូវពិចារណាដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ អនុលោមតាមគោលបំណងនៃមាត្រា ១៧៦"។

[93] ក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវបានធ្វើបច្ចុប្បន្នភាពនៅត្រឹមខែ មករា ឆ្នាំ ២០០៦ (សំណៅបកប្រែផ្លូវការ) *អាចរកបាននៅ* www.legifrance.gouv.fr/content/download/1958/13719/.../Code_34.pdf។

[94] កថាខណ្ឌ ៤១ កំណត់សម្គាល់លេខ ៤៤ នៃដីកាសម្រេចរងការជំទាស់។

[95] *សូមមើល ឧទាហរណ៍* មាត្រា ១១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំងដោយប្រៀបធៀបជាមួយនឹងមាត្រា ៨០-១ និង មាត្រា ១៧៦ ជាមួយនឹងក្រមនីតិវិធីព្រហ្មទណ្ឌបារាំង។

ការត្រួតពិនិត្យតាមផ្លូវតុលាការ គឺស្រដៀងនឹងការចេញដីកាដំណោះស្រាយអនុលោមតាមវិធាន ៦៧។ នៅពេលជនម្នាក់ត្រូវបានដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរត្រូវពិនិត្យថា តើមានអត្ថិភាពបទចោទដែលចាត់ទុកជាបទល្មើស និង មានលក្ខណៈវិនិច្ឆ័យជាបទល្មើសតាមផ្លូវច្បាប់ដែរឬទេ[96]។ ការបង្ហាញខ្លួនលើកដំបូងត្រូវធ្វើឡើងដោយមានវត្តមានផ្ទាល់ រីឯ បុគ្គលម្នាក់អាចត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យតាមផ្លូវតុលាការ *ដោយកំបាំងមុខ* បាន ក្រោមលក្ខខណ្ឌជាក់លាក់មួយចំនួន។

៥៨. មាត្រា ៨០-១ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ពោលប្រាស្រ័យអំពីនីតិវិធីនៃការដាក់ឱ្យបុគ្គលម្នាក់ស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលចែងត្រង់បទប្បញ្ញត្តិពាក់ព័ន្ធថា៖

> [ចៅក្រមស៊ើបសួរ] អាចដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបាន *តែនៅក្រោយពេល* បានស្តាប់ជាមុននូវការសង្កេតទាំងឡាយរបស់បុគ្គលនោះ ឬ *នៅក្រោយពេល* ផ្តល់ឱកាសឱ្យបុគ្គលនោះបានផ្តល់ចម្លើយដោយមានមេធាវីអម ទៅតាមរបៀបដូចមានចែងនៅក្នុងមាត្រា ១១៦ ស្តីពីការសួរចម្លើយនៅពេលចូលបង្ហាញខ្លួនលើកដំបូង ឬ ក្នុងនាមជាសាក្សីជំនួយ អនុលោមតាមបទប្បញ្ញត្តិនៃមាត្រា ១១៣-១ រហូតដល់ មាត្រា ១១៣-៨[97]។

[ចៅក្រមស៊ើបសួរ] អាចផ្តល់ដំណឹងដល់បុគ្គលណាម្នាក់ជាលាយលក្ខណ៍អក្សរថា បុគ្គលរូបនោះនឹងត្រូវបានកោះឱ្យចូលបង្ហាញខ្លួនជាលើកដំបូង អនុលោមតាមមាត្រា ១១៦។ ការជូនដំណឹងនេះត្រូវ "[បញ្ជាក់]ច្បាស់លាស់ថា ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ *មិនអាចធ្វើឡើងនោះទេ រហូតទាល់តែបុគ្គលរូបនេះបានចូលបង្ហាញខ្លួនលើកដំបូងនៅចំពោះមុខចៅក្រមស៊ើបសួរជាមុនសិន*"[98]។

៥៩. មាត្រា ១១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ឆ្លុះបញ្ចាំងនឹងវិធាន ៥៧ ទាំងចេតនា និង គោលបំណង។ នៅឯការបង្ហាញខ្លួនលើកដំបូង ចៅក្រមស៊ើបសួរបញ្ជាក់អត្តសញ្ញាណបុគ្គល និង ប្រាប់ជននោះឱ្យដឹងអំពីបទចោទនានា ដែលការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការគ្រោង

---

[96] មាត្រា ១៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង។

[97] ការគូសបញ្ជាក់បន្ថែម។ អនុលោមតាមមាត្រា ៨០-១ កថាខណ្ឌ ១ បុគ្គលម្នាក់អាចត្រូវបានដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបាន តែនៅក្នុងករណីដែល "មានភស្តុតាងរឹងមាំ និង ស៊ីសង្វាក់គ្នា ដែលបង្ហាញថា ជននោះអាចទំនងបានចូលរួមក្នុងនាមជាចារី ឬ អ្នកសមគំនិត នៅក្នុងការប្រព្រឹត្តបទល្មើសដែល [ចៅក្រមស៊ើបសួរ] កំពុងស៊ើបសួរ"។

[98] មាត្រា ៨០-២ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង (ការគូសបញ្ជាក់បន្ថែម)។

នឹងធ្វើឡើងអនុលោមតាមបទចោទទាំងនេះ ព្រមទាំងសិទ្ធិមានមេធាវី សិទ្ធិនៅស្ងៀមមិនឆ្លើយតប និង សិទ្ធិផ្តល់ចម្លើយ ឬ ត្រូវបានសួរចម្លើយ[99]។ បន្ទាប់ពីកត់ត្រាចម្លើយរបស់បុគ្គលនេះ ឬ ធ្វើការសួរចម្លើយ និង ស្តាប់មេធាវីរួចហើយនោះ ចៅក្រមស៊ើបសួរផ្តល់ដំណឹងដល់បុគ្គលនោះថា៖ **ក.** គាត់មិនត្រូវបានដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនោះទេ (ដែលនៅក្នុងករណីនេះ បុគ្គលនេះនឹងមានសិទ្ធិក្នុងនាមជាសាក្សីជំនួយ នៅពេលកិច្ចស៊ើបសួរបន្តធ្វើឡើង)[100] ឬ **ខ.** គាត់ត្រូវបានដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ (ដែលក្នុងករណីនេះ បុគ្គលនេះនឹងត្រូវបានប្រាប់ឲ្យដឹងអំពីសិទ្ធិរបស់ខ្លួនទាក់ទងនឹងកិច្ចស៊ើបសួរ)[101]។ ដូចទៅនឹងវិធាន ៥៧ គោលបំណងចម្បងនៃការបង្ហាញខ្លួនលើកដំបូង គឺដើម្បីអនុញ្ញាតឲ្យចៅក្រមស៊ើបសួរស្តាប់ការសង្កេតរបស់ជនសង្ស័យទាក់ទងនឹងបទចោទដែលត្រូវបានស៊ើបសួរលើជននេះ។

៦០. ខណៈដែលបុគ្គលម្នាក់អាចត្រូវបានដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ *ដោយកំបាំងមុខ* (ឲ្យតែនគរបាលបានដាក់របាយការណ៍ស្តីពីការស្រាវជ្រាវគ្មានផលផ្ញើផ្កាជូនដល់ចៅក្រមរួចហើយនោះ) បុគ្គលនេះនៅតែត្រូវបង្ហាញខ្លួនលើកដំបូងនៅចំពោះមុខចៅក្រមស៊ើបសួរ។ សហចៅក្រមស៊ើបអង្កេត Harmon មានកំហុសនៅក្នុងការបកស្រាយក្រមនីតិវិធីព្រហ្មទណ្ឌបារាំង។

### ៣. សហចៅក្រមស៊ើបអង្កេត Harmon បានអនុវត្តដោយភ័ន្តច្រឡំ និង ដោយសម្រាំងនូវយុត្តិសាស្ត្រ និង វិធាននីតិវិធីអន្តរជាតិ

#### ក. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ (“កតិកាសញ្ញា ICCPR”) និង អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (“អនុសញ្ញា ECHR”)

៦១. សហចៅក្រមស៊ើបអង្កេត Harmon ដកស្រង់សេចក្តីអធិប្បាយ និង យុត្តិសាស្ត្រពីគណៈកម្មាធិការ

---

[99] *ដូចខាងលើ* មាត្រា ១១៦ កថាខណ្ឌ ២ កថាខណ្ឌ ៤។

[100] ឋានៈជា *សាក្សីជំនួយ* ពុំមាននៅ អ.វ.ត.ក. ឡើយ។ សាក្សីជំនួយ គឺសំដៅទៅលើបុគ្គលណាម្នាក់ ដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបឋម ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់រដ្ឋអាជ្ញា ឬ នៅក្នុងពាក្យបណ្តឹង និង ជាបុគ្គលដែលពុំស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។ មាត្រា ១១៣-១ មាត្រា ១១៣-២ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង។

[101] *ដូចខាងលើ* មាត្រា ១១៦ កថាខណ្ឌ ៥។

សិទ្ធិមនុស្ស ("HRC")[102] និង តុលាការសិទ្ធិមនុស្សអឺរ៉ុប ("EctHR")[103] ជាសំអាង ដើម្បីយល់ឃើញថា កតិកាសញ្ញា ICCPR[104] និង អនុសញ្ញា ECHR[105] អនុញ្ញាតឲ្យមានការជំនុំជម្រះ *ដោយកំបាំងមុខ* នៅក្នុងកាលៈទេសៈមួយចំនួន។ សេចក្តីអធិប្បាយ និង យុត្តិសាស្ត្រនេះ គឺមិនជាប់ពាក់ព័ន្ធ។ សេចក្តីអធិប្បាយ និង យុត្តិសាស្ត្រនេះ ជាប់ពាក់ព័ន្ធតែទៅនឹងកិច្ចដំណើរការនីតិវិធីក្នុងដំណាក់កាលជំនុំជម្រះប៉ុណ្ណោះ ហើយគ្មានគុណតម្លៃនៅក្នុងការកំណត់នីតិវិធីសម្រាប់ការបង្ហាញខ្លួនលើកដំបូង នៅក្នុងដំណាក់កាលមុនជំនុំជម្រះនៅ អ.វ.ត.ក. ឡើយ។

៦២. សហចៅក្រមស៊ើបអង្កេត Harmon ដកស្រង់មតិយោបល់ទូទៅលេខ ១៣ របស់គណៈកម្មាធិការ HRC ដែលបានជំនួសដោយមតិយោបល់ទូទៅលេខ ៣២ នៅឆ្នាំ ២០០៧[106] ដើម្បីថ្លែងថា "នៅពេលដែលមានករណីពិសេសមានហេតុផលសមស្រប ការជំនុំជម្រះ *ដោយកំបាំងមុខ* ត្រូវបានធ្វើឡើង នោះការប្រតិបត្តិតឹងរ៉ឹងនៃសិទ្ធិការពារក្តី គឺជាអ្វីដែលចាំបាច់បំផុត"[107]។ សម្រង់នេះជាប់ពាក់ព័ន្ធនឹងសារៈសំខាន់នៃសិទ្ធិរបស់ជនជាប់ចោទក្នុងការការពារក្តីរបស់ខ្លួន នៅឯការជំនុំជម្រះតាម

---

[102] កថាខណ្ឌ ៤៣-៤៤ នៃដីកាសម្រេចរងការជំទាស់ ដែលដកស្រង់រឿងក្តី *Mbenge* តទល់នឹង *Zaire* ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៨៣ ("សេចក្តីសម្រេច *Mbenge*") ឯកសារ អ.ស.ប. លេខ CCPR/C/18/D/16/1977 កថាខណ្ឌ ១៤.១ និង គណៈកម្មាធិការសិទ្ធិមនុស្ស មតិយោបល់ទូទៅ ១៣ មាត្រា ១៤ (សម័យប្រជុំលើកទី ២១ ឆ្នាំ ១៩៨៤) កម្រងមតិយោបល់ទូទៅ និង អនុសាសន៍ទូទៅ អនុម័តដោយអង្គភាពសន្ធិសញ្ញាសិទ្ធិមនុស្ស HRI/GEN/1/Rev.1 at 14 (ឆ្នាំ ១៩៩៤) កថាខណ្ឌ ១១។

[103] កថាខណ្ឌ ៤៥ នៃដីកាសម្រេចរងការជំទាស់ ដកស្រង់រឿងក្តី *Lala* តទល់នឹង *ហូឡង់* តុលាការសិទ្ធិមនុស្សអឺរ៉ុប Eur. Ct. H.R. 14681/89 ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៩៤ ("រឿងក្តី *Lala* តទល់នឹង *ហូឡង់*") កថាខណ្ឌ ៣៣ រឿងក្តី *Krombach* តទល់នឹង *បារាំង* តុលាការសិទ្ធិមនុស្សអឺរ៉ុប Eur. Ct. H.R. 29731/96 ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០១ ("រឿងក្តី *Krombach* តទល់នឹង *បារាំង*") កថាខណ្ឌ ៨៤ និង រឿងក្តី *Sejdovic* តទល់នឹង *អ៊ីតាលី* តុលាការសិទ្ធិមនុស្សអឺរ៉ុប Eur. Ct. H.R. 56581/00 ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០០៦ ("រឿងក្តី *Sejdovic* តទល់នឹង *អ៊ីតាលី*") កថាខណ្ឌ ៦៩។

[104] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ អនុម័ត និង បើកឲ្យចុះហត្ថលេខា ផ្តល់សច្ចាប័ន និង ចូលជាសមាជិក ដោយសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ ២000 A (XXI) ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៦៦ ចូលជាធរមាន នៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៧៦ យោងទៅតាមមាត្រា ៤៩។

[105] អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ចូលជាធរមាននៅថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ១៩៧០ ធ្វើវិសោធនកម្មដោយពិធីសារលេខ ១១ និង ១៤ បំពេញបន្ថែមដោយពិធីសារលេខ ១,៤, ៦,៧, ១២ និង ១៣។

[106] *សូមមើល* គណៈកម្មាធិការសិទ្ធិមនុស្ស មតិយោបល់ទូទៅលេខ ៣២ មាត្រា ១៤៖ សិទ្ធិស្មើគ្នានៅចំពោះមុខតុលាការ និងសាលាជម្រះក្តី និង សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ឯកសារ អ.ប.ស. លេខ CCPR/C/GC/32 ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៧ កថាខណ្ឌ ១៖ "មតិយោបល់ទូទៅនេះជំនួសមតិយោបល់ទូទៅលេខ ១៣ (សម័យប្រជុំលើកទី ២១)"។

[107] កថាខណ្ឌ ៤៤ នៃដីកាសម្រេចរងការជំទាស់។

វយ:មេធាវីការពារក្ដី។ នេះមិនមែនជាការណែនាំថា តើជនម្នាក់អាច ឬ មិនអាចត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យ ដោយគ្មានវត្តមានរបស់គាត់ ដោយមិនគិតថា តើមេធាវីការពារក្ដីមាន ឬ មិនមានវត្តមាននោះ។

៦៣. គ្មានរឿងក្ដីណាមួយក្នុងចំណោមរឿងក្ដីទាំងឡាយ ដែលដកស្រង់ដោយសហចៅក្រមស៊ើបអង្កេត Harmon ជាសំអាង ពោលប្រាស្រ័យពីបញ្ហាចោទថា តើការបង្ហាញខ្លួនលើកដំបូង អាច ឬ មិនអាចត្រូវបានធ្វើឡើងដោយគ្មានវត្តមានរបស់ជនសង្ស័យឡើយ។ រឿងក្ដី *Mbenge* តទល់នឹង *Zaire* ពោលប្រាស្រ័យថា តើរដ្ឋបាន ឬ ក៏មិនបានចាត់វិធានការគ្រប់គ្រាន់ ដើម្បីជូនដំណឹងដល់ម្ចាស់បណ្ដឹងអំពីការជំនុំជម្រះចំនួនពីរ មុនពេលជំនុំជម្រះ *ដោយកំបាំងមុខ* មុនផ្ដន្ទាទោសគាត់ និង ដាក់ទោសប្រហារជីវិតគាត់ចំនួនពីរដង[108]។ រឿងក្ដី *Lala* តទល់នឹង *ហូឡង់* និង រឿងក្ដី *Krombach* តទល់នឹង *បារាំង* ពោលប្រស្រ័យថា តើជនជាប់ចោទមាន ឬ មិនមានសិទ្ធិទទួលការតំណាងក្ដីដោយមេធាវី នៅក្នុងការជំនុំជម្រះ ឬ សវនាការកំបាំងមុខគាត់ (ដោយស្ម័គ្រចិត្ត)[109]។ រឿងក្ដី *Sejdovic* តទល់នឹង *អ៊ីតាលី* ពោលប្រស្រ័យថា កាលណាជនជាប់ចោទមិនត្រូវបានជូនដំណឹងជាផ្លូវការនោះ តើជនជាប់ចោទអាច ឬ មិនអាចត្រូវបានចាត់ទុកថា បានដឹងឮគ្រប់គ្រាន់អំពីការចោទប្រកាន់ទោស និង ការជំនុំជម្រះក្ដី ដើម្បីសម្រេចថា ត្រូវលះបង់សិទ្ធិចូលបង្ហាញខ្លួននៅតុលាការ ឬ គេចវេសពីតុលាការ[110]។

## ខ. សាលាក្ដី *ចំពោះកិច្ច* (ad hoc) និង តុលាការ ICC

### i. តុលាការពិសេសសម្រាប់ប្រទេសលីបង់ (“តុលាការ STL”)

៦៤. សហចៅក្រមស៊ើបអង្កេត Harmon ដកស្រង់ជាសំអាងនូវនីតិវិធី និង យុត្តិសាស្ត្ររបស់តុលាការ STL ដែលអនុញ្ញាតឱ្យមានការជំនុំជម្រះ *ដោយកំបាំងមុខ* តាមលក្ខខណ្ឌមួយចំនួន[111]។ គាត់ខកខានមិនបានពិចារណាលើបរិបទដែលមានតែមួយគត់របស់តុលាការ STL ហើយដកស្រង់ជាសំអាងនូវវិធាននីតិវិធីមិនពាក់ព័ន្ធថាតើការបង្ហាញខ្លួនលើកដំបូងអាចឬមិនអាចធ្វើបាន *ដោយកំបាំងមុខ*។

---

[108] សេចក្ដីសម្រេច *Mbenge* កថាខណ្ឌ ១៤.១-១៤.២។

[109] រឿងក្ដី *Lala* តទល់នឹង *ហូឡង់* កថាខណ្ឌ ២៥-២៦ និង រឿងក្ដី *Krombach* តទល់នឹង *បារាំង* កថាខណ្ឌ ៦៩។

[110] រឿងក្ដី *Sejdovic* តទល់នឹង *អ៊ីតាលី* កថាខណ្ឌ ៩៨។

[111] កថាខណ្ឌ ៤៦-៥០ នៃដីកាសម្រេចរងការជំទាស់ ដែលដកស្រង់មាត្រា ២២ នៃលក្ខន្តិកៈតុលាការ STL និង វិធាន ១០៦ នៃវិធានស្ដីពីនីតិវិធី និង ភស្តុតាងរបស់តុលាការ STL។

៦៥. តុលាការ STL ត្រូវបានបង្កើតឡើង ដើម្បីស៊ើបអង្កេត និង កាត់ទោសឧក្រិដ្ឋជនដែលត្រូវបានចោទប្រកាន់ថាបានធ្វើការវាយប្រហារគ្រាប់បែកនៅថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ ២០០៥ ដែលបានសម្លាប់លោក Rafik Hariri អតីតនាយករដ្ឋមន្ត្រីលីបង់[112]។ ចាប់តាំងពីពេលដំបូង អង្គការសហប្រជាជាតិ ("អ.ស.ប.") និង នាយករដ្ឋមន្ត្រីលីបង់នៅពេលនោះ បានប្រឈមមុខនឹងឧបសគ្គធំៗពីខាងក្នុងប្រទេសលីបង់ និង ពីប្រទេសស៊ីរី[113]។ ក្រុមប្រឹក្សាសន្តិសុខនៃ អ.ស.ប. ត្រូវតែបង្កើតតុលាការ STL ជាឯកតោភាគី[114]។ ថ្នាក់ដឹកនាំរបស់ Hezbollah បានថ្កោលទោសតុលាការ STL ជាសាធារណៈ ដោយបដិសេធមិនអនុញ្ញាតឲ្យសមាជិករបស់ខ្លួនចូលបង្ហាញខ្លួននៅចំពោះមុខតុលាការនេះទេ[115]។ លក្ខន្តិកៈតុលាការ STL និង វិធានស្តីពីនីតិវិធី និង ភស្តុតាងត្រូវបានព្រាងនៅក្នុង

---

[112] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខនៃ អ.ស.ប. លេខ ១៧៥៧ (ឆ្នាំ ២០០៧) ឯកសារ អ.ស.ប. លេខ S/RES/1757 (ថ្ងៃទី ៣០ ខែឧសភា ឆ្នាំ ២០០៧)។ ចុងក្រោយបំផុត អាណត្តិនេះត្រូវបានពង្រីកដើម្បីបញ្ចូលអំពើភេរវកម្មចំនួន ១៧ ផ្សេងទៀតដែលបានកើតឡើងមុន និង ក្រោយការវាយប្រហារគ្រាប់បែកថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ ២០០៥។ អគ្គលេខាធិការនៃ អ.ស.ប. លិខិតចុះថ្ងៃទី ១២ ខែកក្កដា ឆ្នាំ ២០០៧ ពីអគ្គលេខាធិការ ផ្ញើជូនប្រធានក្រុមប្រឹក្សាសន្តិសុខ ឯកសារ អ.ស.ប. លេខ S/2007/424 (ថ្ងៃទី ១២ ខែកក្កដា ឆ្នាំ ២០០៧)។

[113] ប្រទេសស៊ីរីបានគាបសង្កត់ដោយឥទ្ធិពលនយោបាយយ៉ាងសម្បើម និង មានទម្ងន់ខ្លាំងទៅលើរដ្ឋាភិបាលលីបង់ "ដោយហួសពីការអនុវត្តកិច្ចសហការណ៍សមស្រប ឬ ទំនាក់ទំនងប្រទេសជិតខាង"។ របាយការណ៍បេសកកម្មស្វែងរកការពិតនៅប្រទេសលីបង់ ដែលស៊ើបអង្កេតអំពីដើមហេតុ កាលៈទេសៈ និង ផលលំបាកទាក់ទងនឹងការធ្វើឃាតអតីតនាយករដ្ឋមន្ត្រី Rafik Hariri ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៥ ទំព័រ ២។ ប្រធានាធិបតីស៊ីរី លោក Bashar Al-Assad បានព្រមានអគ្គលេខាធិការនៃ អ.ស.ប. ថា ការបង្កើតតុលាការ STL នឹងបង្កឲ្យមាន "ផលលំបាកធ្ងន់ធ្ងរដែលមិនអាចគ្រប់គ្រងបាននៅក្នុងប្រទេសលីបង់"។ William Harris *ថ្ងៃចូលសវនាការរបស់លីបង់ (Lebanon's Day in Court)* កិច្ចការបរទេស ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០១១។

[114] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខនៃ អ.ស.ប. ១៧៥៧ (ឆ្នាំ ២០០៧) ឯកសារ អ.ស.ប. លេខ S/RES/1757 (ថ្ងៃទី ៣០ ខែឧសភា ឆ្នាំ ២០០៧)។

[115] *សូមមើលឧទាហរណ៍* Erich Follath *ភស្តុតាងថ្មីចង្អុលទៅ Hezbollah នៅក្នុងការធ្វើឃាត Hariri*, DER SPIEGEL ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ ៤៖ "មេដឹកនាំ [Hezbollah] បើទោះជាទទួលស្គាល់ជាផ្លូវនូវវិធានប្រជាធិបតេយ្យនៃល្បែងក៏ដោយ ក៏នៅតែស្ថិតនៅក្នុងបញ្ជីអង្គការចាត់តាំងភេរវកម្មរបស់សហរដ្ឋអាមេរិក ហើយប្រហែលជារំពឹងទុកថានឹងមានបញ្ហាខាងមុខជាមួយនឹងសាលាជម្រះក្តី អ.ប.ស. នេះ។ នៅក្នុងសន្ទរកថាមួយនៅទីក្រុង Beirut Nasrallah បាននិយាយអំពី "គោលបំណងរួមគំនិតក្បត់" របស់សាលាក្តីនេះ។ Nicholas Blanford *សាលាក្តីលីបង់ ព្យាយាមប្រកបដោយគ្រោះថ្នាក់ដើម្បីជំនុំជម្រះ Hezbollah ចំពោះការសម្លាប់ Hariri* CHRISTIAN SCIENCE MONITOR ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៤៖ "Hezbollah បានរិះគន់សាលាក្តីថាជាកល្បិចមួយរបស់លោកខាងលិច និង អ៊ីស្រាអែល ដើម្បី 'បង្អាប់មុខមាត់' របស់ភាគី ដោយសារមានសារតាំងប្រឆាំងនឹងអ៊ីស្រាអែល។ Hezbollah បានបដិសេធមិនប្រគល់ខ្លួនបុរស Hezbollah ទាំងប្រាំនាក់នោះទេគឺ៖ Mustapha Badreddine, Salim Ayyash, Hussein Oneissi, Assad Sabra និង Hassan Merhi"។

បរិបទនេះ និង ដោយសារឧបសគ្គដែលកើតមានស្រាប់ទាំងនេះ រួមបញ្ចូលទាំងបទប្បញ្ញត្តិច្បាស់លាស់សម្រាប់ការជំនុំជម្រះ *ដោយកំបាំងមុខ*[116]។

៦៦. ផ្ទុយពីសាលាក្តីកូនកាត់ និង សាលាក្តីអន្តរជាតូបនីយកម្មដទៃៗទៀត តុលាការ STL មានបទប្បញ្ញត្តិពិសេសមួយ ដែលទាក់ទងនឹងអវត្តមានរបស់ជនជាប់ចោទ ដោយសារអាជ្ញាធររដ្ឋខកខានមិនបានបញ្ជូនជនជាប់ចោទទៅតុលាការ STL[117]។ តុលាការ STL ក៏មិនតម្រូវឱ្យជនជាប់ចោទទទួលបានដោយផ្ទាល់នូវសេចក្តីជូនដំណឹងអំពីដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ ប៉ុន្តែ អនុញ្ញាតប្រគល់ឱ្យតាមរយៈការចុះផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយក្នុងប្រទេស ឬ តាមការបញ្ជូនដំណឹងទៅរដ្ឋដែលជនជាប់ចោទស្នាក់នៅ ឬ មានសញ្ជាតិ[118]។

៦៧. នីតិវិធីចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់តុលាការ STL ប្រឆាំងនឹងយុត្តិសាស្ត្ររបស់គណៈកម្មាធិការ HRC និង តុលាការ ECtHR។ នៅក្នុងរឿងក្តី *Maleki* តទល់នឹង *អ៊ីតាលី* ការសន្មតរបស់រដ្ឋដែលថា មេធាវីរបស់ម្ចាស់បណ្តឹង (បុគ្គលតែម្នាក់គត់ដែលរដ្ឋបានជូនដំណឹង) បានជូនដំណឹងម្ចាស់បណ្តឹងអំពីការជំនុំជម្រះដែលជិតកើតមាននាពេលខាងមុខ គឺត្រូវបានរកឃើញថាមិនគ្រប់គ្រាន់។ គណៈកម្មាធិការ HRC បានយល់ឃើញថា "តុលាការមានភារកិច្ច ... ត្រូវផ្ទៀងផ្ទាត់ថា ម្ចាស់បណ្តឹងត្រូវបានជូនដំណឹងរួចហើយអំពីរឿងក្តីដែលនឹងកើតឡើង នៅមុនពេលដំណើរការជំនុំជម្រះក្តី *ដោយកំបាំងមុខ*"[119]។ នៅក្នុងរឿងក្តី *Mbenge* តទល់នឹង *Zaire* ខណៈដែលទទួលស្គាល់ថា មានដែនកំណត់ទៅលើកិច្ចខិតខំប្រឹងប្រែង ដែលតម្រូវឱ្យអាជ្ញាធររដ្ឋ ធ្វើការទាក់ទងទៅជនជាប់ចោទណាម្នាក់ គណៈកម្មាធិការ HRC បានយល់ឃើញថា វាជាការរំលោភបំពានលើកតិកាសញ្ញា ICCPR កាលណាដីកាកោះត្រូវបានចេញក្នុងរយៈពេលបីថ្ងៃមុនការជំនុំជម្រះ ដោយមិនបានព្យាយាមផ្ញើដីកាកោះនោះទៅអាសយដ្ឋានរបស់ជនជាប់ចោទដែលគេស្គាល់ ហើយរដ្ឋក៏មិន

---

[116] *សូមមើល* មាត្រា ២២(១) នៃ*លក្ខន្តិកៈតុលាការ* STL។ វិធាន ១០៦ នៃវិធានស្តីពីនីតិវិធី និង ភស្តុតាងរបស់តុលាការ STL។

[117] ក្នុងករណីបែបនេះ មុនពេលធ្វើការជំនុំជម្រះ *ដោយកំបាំងមុខ* អង្គជំនុំជម្រះសាលាដំបូង ត្រូវតែ៖ **ក.** ប្រឹក្សាជាមួយប្រធាន និង ធានាថាវិធានការចាំបាច់ទាំងអស់ត្រូវបានអនុវត្តរួចហើយ ដើម្បីធានាឱ្យមានការចូលរួមរបស់ជនជាប់ចោទនៅក្នុងកិច្ចដំណើរការនីតិវិធី និង **ខ.** ធានាថា លក្ខខណ្ឌតម្រូវតាមមាត្រា ២២(២) នៃលក្ខន្តិកៈតុលាការ STL ត្រូវបានបំពេញរួចហើយ។
វិធាន ១០៦(ខ) នៃវិធានស្តីពីនីតិវិធី និង ភស្តុតាងរបស់តុលាការ STL។

[118] មាត្រា ២២(២)(ក) នៃលក្ខន្តិកៈតុលាការ STL។ វិធាន ៧៦ស្ទួន នៃវិធានស្តីពីនីតិវិធី និង ភស្តុតាងរបស់តុលាការ STL។

[119] រឿងក្តី *Maleki* តទល់នឹង *អ៊ីតាលី* ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ ឯកសារ អ.ស.ប. លេខ CCPR/C/66/D/669/1996 កថាខណ្ឌ ៩.៤។

បានជំទាស់ទៅនឹងសេចក្តីអះអាងរបស់ម្ចាស់បណ្តឹងដែលថា គាត់បានដឹងអំពីការជំនុំជម្រះនេះ តែតាមរយៈរបាយការណ៍សារព័ត៌មានក្រោយការជំនុំជម្រះប៉ុណ្ណោះ[120]។ "ការប្រគល់ឱ្យ" ជនជាប់ចោទនូវដីកាបញ្ជូនរឿងទៅជំនុំជម្រះ តាមរយៈការចុះផ្សាយនៅក្នុងប្រព័ន្ធផ្សព្វផ្សាយក្នុងប្រទេស ឬ ផ្ញើទៅរដ្ឋដែលគាត់មានទីលំនៅ គឺមិនគ្រប់គ្រាន់ឡើយ ដោយគ្មានភស្តុតាងបញ្ជាក់ថា ជនជាប់ចោទបានដឹងអំពីការជំនុំជម្រះដែលនឹងត្រូវធ្វើឡើង និង ដឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការលះបង់វត្តមានរបស់គាត់។

៦៨. នៅតុលាការ STL ជនជាប់ចោទម្នាក់មិនចាំបាច់មានមេធាវីដែលត្រូវបានតែងតាំងដើម្បីតំណាងក្តីឱ្យខ្លួន នៅមុនពេលដែលការជំនុំជម្រះប្រព្រឹត្តទៅ *ដោយកំបាំងមុខ* ទេ[121]។ ប្រសិនបើជនជាប់ចោទត្រូវបានចាត់ទុកថា បានបដិសេធ ឬ បានខកខានមិនបានតែងតាំងមេធាវីការពារក្តី នោះការិយាល័យការពារក្តីរបស់តុលាការ STL អាចតែងតាំងមេធាវីម្នាក់ (ដោយមិនគិតថា តើមេធាវីរូបនោះបាននិយាយ ឬ បានជួបជាមួយជនជាប់ចោទ ឬក៏អត់ឡើយ)[122]។

៦៩. ជនចាប់ចោទនៅចំពោះមុខតុលាការ STL នឹងត្រូវបានជំនុំជម្រះ ដោយមិនចាំបាច់ធ្លាប់បានចូលបង្ហាញខ្លួននៅតុលាការ ដូចគ្នានេះដែរ ដោយមិនចាំបាច់តែងតាំង ឬ ជួបជាមួយមេធាវីការពារក្តីរបស់ខ្លួនក៏បាន ឱ្យតែមានការជូនដំណឹងអំពីការជំនុំជម្រះត្រូវបានចាត់ទុកថាបានធ្វើឡើងប៉ុណ្ណឹងក៏បាន ដោយសារដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានចុះផ្សាយនៅក្នុងសារព័ត៌មានក្នុងប្រទេសរួចទៅហើយ[123]។ នីតិវិធីរបស់តុលាការ STL មានលក្ខណៈពិសេសតែមួយគត់ និង ត្រូវតែមានដែនកំណត់ត្រឹមបរិបទប្រទេសលីបង់ប៉ុណ្ណោះ។

៧០. តុលាការ STL គឺជាឧទាហរណ៍តែមួយគត់អំពីសាលាក្តីកូនកាត់ ឬ សាលាក្តីអន្តរជាតូបនីយកម្ម ឬ តុលាការអន្តរជាតិ ដែលក្នុងនោះជនចាប់ចោទអាចត្រូវជំនុំជម្រះ និង ផ្តន្ទាទោសដោយឥតមានការ

---

[120] កថាខណ្ឌ ១៤.២ នៃសេចក្តីសម្រេច *Mbenge*។ *សូមមើលផងដែរ* រឿងក្តី *Maleki* តទល់នឹង *អ៊ីតាលី កថាខណ្ឌ ៨៩, ៩៩-១០១*។

[121] មាត្រា ២២(២)(ក) នៃលក្ខន្តិកៈតុលាការ STL។

[122] *ដូចខាងលើ* មាត្រា ២២(២)(គ)។

[123] *សូមមើល* Chris Jenks *ការជូនដំណឹងដែលបានប្រគល់ឱ្យ៖ តើការជំនុំជម្រះដោយកំបាំងមុខនៅតុលាការពិសេសសម្រាប់ប្រទេសលីបង់ នឹងរំលោភបំពានសិទ្ធិមនុស្សដែរឬទេ?* 33 FORDHAM L. J. 57, 66-67 (ឆ្នាំ ២០០៩)។

បង្ហាញខ្លួននៅតុលាការ[124]។ តុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC") និង តុលាការ ICTY ហាម មិនឱ្យមានការជំនុំជម្រះក្តី *ដោយកំបាំងមុខ*[125]។ តុលាការ ICTR និង តុលាការពិសេសសម្រាប់ សៀរ៉ាឡេអូន ("តុលាការ SCSL") ក៏ដូចជា អ.វ.ត.ក. ដែរ អនុញ្ញាតឱ្យមានការជំនុំជម្រះ *ដោយកំបាំងមុខ* ក្រោមលក្ខខណ្ឌមួយចំនួន *ឱ្យតែជនជាប់ចោទបានបង្ហាញខ្លួនលើកដំបូងរួចហើយនៅចំពោះមុខចៅក្រម*[126]។ នីតិវិធី *ដោយកំបាំងមុខ* របស់តុលាការ STL គឺជាគំរូមួយដែលអន់ខ្សោយ ហើយមិនអាច និង មិនគួរយកមកអនុវត្តនៅ អ.វ.ត.ក. ឡើយ។

៧១. សហចៅក្រមស៊ើបអង្កេត Harmon ដកស្រង់ជាសំអាងនូវសេចក្តីសម្រេចចំនួនបីពីអង្គជំនុំជម្រះសាលាដំបូង និង អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការ STL ដែលអនុញ្ញាតឱ្យមានការជំនុំជម្រះ *ដោយកំបាំងមុខ*[127]។ សេចក្តីសម្រេចទាំងនេះមិនជាប់ពាក់ព័ន្ធនឹងលោក មាស មុត ឡើយ។ សេចក្តីសម្រេចទាំងនេះជាប់ពាក់ព័ន្ធនឹងដំណាក់កាលជំនុំជម្រះ មិនមែនដំណាក់កាលមុនជំនុំជម្រះទេ ហើយវាខុសប្លែកស្រឡះពីស្ថានភាពរបស់លោក មាស មុត ។ នៅក្នុងរឿងក្តី *រដ្ឋអាជ្ញា* តទល់នឹង *Ayyash និង អ្នកផ្សេងទៀត* និង រឿងក្តី *រដ្ឋអាជ្ញា* តទល់នឹង *Merhi* អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ការជំនុំជម្រះអាចប្រព្រឹត្ត *ដោយកំបាំងមុខ* ពីព្រោះថា ជនជាប់ចោទបានគេចខ្លួន ហើយវិធានការសមស្របទាំងអស់ត្រូវបានអនុវត្តរួចហើយ ដើម្បីជូនដំណឹងដល់ជនទាំងនោះអំពីកិច្ចដំណើរការនីតិវិធី និង សម្រាប់ធានាឱ្យមានការបង្ហាញខ្លួននៅតុលាការ[128]។

---

[124] មាត្រា ១២ នៃធម្មនុញ្ញរបស់សាលាក្តីយោធាអន្តរជាតិនៅ Nürnberg ឆ្នាំ ១៩៤៥ បានអនុញ្ញាតឱ្យមានកិច្ចដំណើរការនីតិវិធីធ្វើឡើងដោយកំបាំងមុខជនណាម្នាក់ "ប្រសិនបើ [ជននោះ] មិនត្រូវបានរកឃើញ ឬ ដោយមូលហេតុណាក៏ដោយ ប្រសិនបើតុលាការយល់ឃើញថា ចាំបាច់ត្រូវរៀបចំសវនាការដោយគ្មានវត្តមានរបស់ជននោះ ដើម្បីជាប្រយោជន៍យុត្តិធម៌"។

[125] មាត្រា ៦៣(១) នៃលក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ២០ មាត្រា ២១(៤)(ឃ)នៃលក្ខន្តិកៈបច្ចុប្បន្នស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវី ("លក្ខន្តិកៈតុលាការ ICTY") វិធាន ៨០(ខ)នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICTY។

[126] វិធាន ៨២ផ្ទួន នៃវិធានស្តីពីនីតិវិធី និង ភស្តុតាងរបស់តុលាការ ICTR វិធាន ៦០-៦១ នៃវិធានស្តីពីនីតិវិធី និង ភស្តុតាងរបស់តុលាការ SCSL។

[127] កថាខណ្ឌ ៥០ កំណត់សម្គាល់លេខ ៥៤-៥៥ នៃដីកាសម្រេចរងការជំទាស់។

[128] រឿងក្តី *រដ្ឋអាជ្ញា* តទល់នឹង *Ayyash និង អ្នកផ្សេងទៀត* សំណុំរឿងលេខ STL-11-01/I/TC សេចក្តីសម្រេចបើកការជំនុំជម្រះ *ដោយកំបាំងមុខ* ចុះថ្ងៃទី ១ ខែកុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ២៥, ៦៨-៧០, ១០៧-១១១។ រឿងក្តី *រដ្ឋអាជ្ញា* តទល់នឹង *Ayyash និង អ្នកផ្សេងទៀត* សំណុំរឿងលេខ STL-11-01/PT/AC/ARI26.1 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី ជំទាស់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការពិចារណាឡើងវិញលើការជំនុំជម្រះ *ដោយកំបាំងមុខ* ចុះថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ២០១២ កថាខណ្ឌ ៤៦ និង ៥១។ រឿងក្តី *រដ្ឋអាជ្ញា* តទល់នឹង *Mehri* សំណុំរឿងលេខ STL-13-04/I/TC សេចក្តីសម្រេចបើកការជំនុំជម្រះ *ដោយកំបាំងមុខ* ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ២០១៣ កថាខណ្ឌ ៨៥, ១១១។

៧២. លោក មាស មុត មិនបានគេចខ្លួនទេ។ សហចៅក្រមស៊ើបអង្កេត Harmon បានបញ្ជាក់យ៉ាងច្រើនក្នុងការយល់ឃើញថា គាត់ "ជឿជាក់ថា [លោក មាស] មុត មិនលាក់ខ្លួនទេ"[129]។ សហចៅក្រមស៊ើបអង្កេត Harmon និង នគរបាលយុត្តិធម៌បានស្គាល់កន្លែងស្នាក់នៅរបស់លោក មាស មុត[130]។ វិធានការទាំងឡាយដែលបានអនុវត្តដោយសហចៅក្រមស៊ើបអង្កេត Harmon ដើម្បីធានាឱ្យមានការបង្ហាញខ្លួនរបស់លោក មាស មុត នៅចំពោះមុខគាត់ គឺមិនឈានដល់វិសាលភាព ឬ ចំនួនវិធានការដែលអនុវត្តដោយតុលាការ STL និង អាជ្ញាធរលីបង់ផងឡើយ[131]។ សហចៅក្រមស៊ើបអង្កេត Harmon មានកំហុសអង្គច្បាប់នៅក្នុងការបកស្រាយ និង អនុវត្តវិធាននីតិវិធី និង យុត្តិសាស្ត្ររបស់តុលាការ STL។

### ii. តុលាការ ICTY និង តុលាការ ICTR

៧៣. សហចៅក្រមស៊ើបអង្កេត Harmon ដកស្រង់វិធាន ៦១ នៃតុលាការ ICTY និង វិធានស្តីពីនីតិវិធី និង ភស្តុតាងរបស់តុលាការ ICTR ជាសំអាង ដើម្បីធ្វើសេចក្តីសន្និដ្ឋានថា កិច្ចដំណើរការនីតិវិធី *ដោយកំបាំងមុខ* អាចអនុវត្តទៅបាននៅក្នុងតុលាការទាំងនេះ[132]។ អនុលោមតាមវិធាន ៦១ អង្គជំនុំជម្រះសាលាដំបូង ពិនិត្យមើលឡើងវិញ និង បញ្ជាក់បន្ថែមលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ (*បន្ទាប់ពី* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវបានបញ្ជាក់បន្ថែមដោយចៅក្រមមួយរូប អនុលោមតាមវិធាន ៤៧) នៅពេលដែលដីកាបង្គាប់ឱ្យនាំខ្លួនត្រូវបានចេញសម្រាប់ជនជាប់ចោទ ប៉ុន្តែមិនទាន់ត្រូវបានអនុវត្តនៅឡើយ។ វិធាន ៦១ គឺមិនពាក់ព័ន្ធទៅនឹងការបង្ហាញខ្លួនលើកដំបូងនៅឯ អ.វ.ត.ក. ទេ។

៧៤. សវនាការស្របតាមវិធាន ៦១ *មិនមែន* ជាវត្ថុដែលមានតម្លៃស្មើគ្នាទៅនឹងការបង្ហាញខ្លួនលើកដំបូងឡើយ។ សវនាការនេះ ដូចគ្នាជាងទៅនឹងសវនាការនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងរបស់ អ.វ.ត.ក. ដើម្បីបញ្ជាក់បន្ថែមអំពីដីកាដំណោះស្រាយ[133]។ នៅមុនពេលដែលសវនាការស្របតាម

---

[129] កថាខណ្ឌ ៦៦ នៃដីកាសម្រេចរងការជំទាស់។

[130] *សូមមើលដូចខាងលើ* កថាខណ្ឌ ៦២ និង ៦៦។

[131] *សូមមើល* ផ្នែក V(ខ)៥ ទាក់ទងនឹងការពិភាក្សាលម្អិតថែមទៀតអំពីកិច្ចខិតខំប្រឹងប្រែងរបស់សហចៅក្រមស៊ើបអង្កេត Harmon ដើម្បីធានាឱ្យមានការបង្ហាញខ្លួនរបស់លោក មាស មុត នៅចំពោះមុខខ្លួន។

[132] កថាខណ្ឌ ៥១ នៃដីកាសម្រេចរងការជំទាស់។

[133] វិធានផ្ទៃក្នុងមិនបានចែងអំពីសវនាការបែបនេះនៅ អ.វ.ត.ក. ឡើយ ដែលចង្អុលបង្ហាញបន្ថែមទៀតអំពីភាពខុសគ្នារវាង (និង នាំឱ្យមានភាពមិនពាក់ព័ន្ធនៃ) នីតិវិធីរបស់តុលាការ ICTY និង តុលាការ ICTR ធៀបទៅនឹងនីតិវិធីរបស់ អ.វ.ត.ក.។

វិធាន ៦១ អាចត្រូវបានធ្វើឡើង វិធានការសមស្របទាំងអស់ត្រូវតែបានចាត់ចែងរួចហើយ សម្រាប់អនុវត្តដីកាបង្គាប់ឲ្យនាំខ្លួន[134] និង ដើម្បីស្វែងរកទីសំចតរបស់ជនជាប់ចោទ ប្រសិនបើមិនស្គាល់ទីកន្លែងនោះ[135]។ នៅក្នុងសវនាការស្របតាមវិធាន ៦១ រដ្ឋអាជ្ញាដាក់ស្នើដីកាបញ្ជូនរឿងទៅជំនុំជម្រះជូនទៅអង្គជំនុំជម្រះសាលាដំបូង រួមជាមួយនឹងភស្តុតាងទាំងអស់ ដែលបានដាក់បង្ហាញទៅចៅក្រម ដែលជាអ្នកបានបញ្ជាក់ពីដំបូងទៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះ[136]។ សាក្សីអាចត្រូវបានកោះហៅឲ្យមកបង្ហាញខ្លួន និង ផ្តល់សក្ខីកម្ម[137]។ ប្រសិនបើដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានបញ្ជាក់ហើយ រឿងក្តីនោះបន្តដំណើរការទៅជំនុំជម្រះ។ ឧទាហរណ៍ នៅក្នុងរឿងក្តី *Nikolić* សវនាការស្របតាមវិធាន ៦១ បានប្រព្រឹត្តទៅអស់រយៈពេលប្រាំថ្ងៃ ដែលក្នុងអំឡុងពេលនោះ សាក្សីចំនួន ១៥ នាក់ ត្រូវបានកោះហៅឲ្យមកផ្តល់សក្ខីកម្ម[138]។ នៅក្នុងសវនាការស្របតាមវិធាន ៦១ ក្នុងរឿងក្តី *Karadžić និង Mladić* អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់បន្ថែមអំពីដីកាបញ្ជូនរឿងទៅជំនុំជម្រះ បន្ទាប់ពី "ពិនិត្យឡើងវិញទៅលើភស្តុតាងទាំងអស់ដែលបានដាក់ជូនទៅចៅក្រមដែលបានធ្វើការបញ្ជាក់ ព្រមទាំងឯកសារបន្ថែមដែលផ្តល់ជូនក្នុងអំឡុងពេលសវនាការ" និង "សាក្សីទាំងឡាយដែលត្រូវបានកោះហៅ និង ស្តាប់ចម្លើយដោយរដ្ឋអាជ្ញា និង អ្នកជំនាញអមតុលាការចំនួនពីរនាក់"[139]។

---

[134] វិធាន ៦១(ក)(i) នៃវិធានស្តីពីនីតិវិធី និង ភស្តុតាងរបស់តុលាការ ICTY។ វិធាន ៦១(ក)(i) នៃវិធានស្តីពីនីតិវិធី និង ភស្តុតាងរបស់តុលាការ ICTR។

[135] វិធាន ៦១(ក)(ii) នៃវិធានស្តីពីនីតិវិធី និង ភស្តុតាងរបស់តុលាការ ICTY។ វិធាន ៦១(ក)(ii) នៃវិធានស្តីពីនីតិវិធី និង ភស្តុតាងរបស់តុលាការ ICTR។

[136] វិធាន ៦១(ខ) នៃវិធានស្តីពីនីតិវិធី និង ភស្តុតាងរបស់តុលាការ ICTY។ វិធាន ៦១(ខ) នៃវិធានស្តីពីនីតិវិធី និង ភស្តុតាងរបស់តុលាការ ICTR។

[137] វិធាន ៦១(ខ) នៃវិធានស្តីពីនីតិវិធី និង ភស្តុតាងរបស់តុលាការ ICTY។ វិធាន ៦១(ខ) នៃវិធានស្តីពីនីតិវិធី និង ភស្តុតាងរបស់តុលាការ ICTR។

[138] មហាសន្និបាតអង្គការសហប្រជាជាតិ *របាយការណ៍របស់ [តុលាការ ICTY]* ឯកសារ អ.ស.ប. លេខ A/51/292, S/1996/665 សម័យប្រជុំលើកទី ៥១ ថ្ងៃទី ១៦ ខែសីហា ឆ្នាំ ១៩៩៦ កថាខណ្ឌ ៥១ *អាចរកមើលបាននៅគេហទំព័រ* http://www.icty.org/x/file/About/Reports%20and%20Publications/AnnualReports/annual_report_1996_en.pdf.។

[139] រឿងក្តី *រដ្ឋអាជ្ញា* តទល់នឹង *Karadžić* នឹង *Mladić* សំណុំរឿងលេខ IT-95-5-R61 និង IT-95-18-R61 ការពិនិត្យមើលឡើងវិញទៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ អនុលោមតាមវិធាន ៦១ នៃវិធានស្តីពីនីតិវិធី និង ភស្តុតាង ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ ១៩៩៦ កថាខណ្ឌ ២។ *សូមមើលផងដែរ* រឿងក្តី *រដ្ឋអាជ្ញា* តទល់នឹង *Karadžić* និង *Mladić* សំណុំរឿងលេខ IT-95-5-R61 និង

៧៥. នៅ អ.វ.ត.ក. ពុំមានសវនាការស្រដៀងគ្នានេះ សម្រាប់ការបង្ហាញខ្លួនលើកដំបូង ស្របតាមវិធាន ៥៧ ឡើយ។ ពុំមានការកោះហៅសាក្សីឱ្យមកផ្តល់សក្ខីកម្មឡើយ។ ការិយាល័យសហព្រះរាជអាជ្ញា ពុំមានបង្ហាញភស្តុតាងអ្វីឡើយ។ សហចៅក្រមស៊ើបអង្កេត ក៏មិនបានពិនិត្យទៅលើភស្តុតាងទាំងអស់ឡើយ។ បុគ្គលតែម្នាក់គត់ដែលផ្តល់ចម្លើយ គឺជនត្រូវចោទ ប្រសិនបើគាត់យល់ព្រមធ្វើដូច្នេះ។ បន្ទាប់ពីការបង្ហាញខ្លួនលើកដំបូង កិច្ចស៊ើបសួរនៅតែបន្តដំណើរការ។ រឿងក្តីមិនត្រូវបន្តបញ្ជូនទៅជំនុំជម្រះដោយស្វ័យប្រវត្តិនោះទេ។

៧៦. សវនាការសម្រាប់បញ្ជាក់បន្ថែមលើដីកាបញ្ជូនរឿងទៅជំនុំជម្រះស្របតាមវិធាន៦១ មិនអាចយកមកប្រៀបប្រដូចជាមួយនឹងការបង្ហាញខ្លួនលើកដំបូងស្របតាមវិធាន ៥៧ ហើយវាមិនគាំទ្រដល់ការដាក់ជនសង្ស័យឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ឡើយ។ ជាថ្មីម្តងទៀត សហចៅក្រមស៊ើបអង្កេត Harmon នៅតែអនុវត្តមិនត្រឹមត្រូវនូវវិធាននីតិវិធីអន្តរជាតិ និង មានកំហុសផ្នែកអង្គច្បាប់។

**iii. តុលាការ ICC**

៧៧. សហចៅក្រមស៊ើបអង្កេត Harmon ដកស្រង់នីតិវិធីនានាទាក់ទិននឹងសវនាការបញ្ជាក់បន្ថែមពីបទចោទប្រកាន់នៅឯតុលាការ ICC ជាសំអាងដើម្បីគាំទ្រការដាក់បុគ្គលឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* នៅ អ.វ.ត.ក.[140]។ សហចៅក្រមស៊ើបអង្កេត Harmon បកស្រាយខុស និង អនុវត្តមិន

---

សំណុំរឿងលេខ IT-95-18-R61 ប្រតិចារឹក ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ ១៩៩៦ ទំព័រ ៩១៩។ ដូចដែលសហចៅក្រមស៊ើបអង្កេត Harmon ខ្លួនគាត់ផ្ទាល់បានកត់សម្គាល់ ទាក់ទិននឹងសវនាការស្របតាមវិធាន ៦១ ក្នុងរឿងក្តី *Karadžić* និង *Mladić* ៖ "សវនាការស្របតាមវិធាន ៦១ មិនមែនបម្រុងជាសវនាការកំបាំងមុខទេ។ វាជាសវនាការមួយ ដើម្បីធ្វើឱ្យអង្គជំនុំជម្រះជឿជាក់ថា មានមូលដ្ឋានសមស្របក្នុងការជឿជាក់ថា ជនជាប់ចោទទាំងពីរនាក់បានប្រព្រឹត្តឧក្រិដ្ឋកម្មណាមួយ ឬ ឧក្រិដ្ឋកម្មទាំងអស់ដូចដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនីមួយៗ ហើយប្រសិនបើមានការជឿជាក់នោះ ត្រូវចាត់វិធានការចាំបាច់នានា ដើម្បីធានាឱ្យមានការបង្ហាញខ្លួនជាយថាហេតុរបស់ [ជនជាប់ចោទ]"។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* *Karadžić* និង *Mladić* សំណុំរឿងលេខ IT-95-5-R61 និង សំណុំរឿងលេខ IT-95-18-R61 ប្រតិចារឹក ចុះថ្ងៃទី ៨ ខែកក្កដា ឆ្នាំ ១៩៩៦ ទំព័រ ៨៩៣។

[140] កថាខណ្ឌ ៥២ នៃដីកាសម្រេចរងការជំទាស់។ *សូមមើល* មាត្រា ៦១ នៃលក្ខន្តិកៈទីក្រុងរ៉ូម។ វិធាន ១២៤-២៥ នៃវិធានស្តីពីនីតិវិធី និង ភស្តុតាងរបស់តុលាការ ICC។

ត្រឹមត្រូវនូវលក្ខន្តិកៈទីក្រុងរ៉ូមនិងវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់តុលាការ ICC[141]។

៧៨. សហចៅក្រមស៊ើបអង្កេត Harmon មិនអើពើទាល់តែសោះនឹងមាត្រា ៦០ នៃលក្ខន្តិកៈទីក្រុងរ៉ូម ដែលយោងដំដៅដល់ *កិច្ចដំណើរការនីតិវិធីបឋម* នៅចំពោះមុខតុលាការ និង ដូចគ្នាទៅនឹងការបង្ហាញខ្លួនលើកដំបូងស្របតាមវិធាន ៥៧ នៅ អ.វ.ត.ក.។ អនុលោមតាមមាត្រា ៦០ បុគ្គលម្នាក់ធ្វើការបង្ហាញខ្លួនលើកដំបូងរបស់ខ្លួននៅចំពោះមុខអង្គបុរេជំនុំជម្រះ តាមការស្ម័គ្រចិត្ត ឬ តាមដីកាកោះ ឬ តាមការអនុវត្តដីកាបង្គាប់ឲ្យចាប់ខ្លួន[142]។ អង្គបុរេជំនុំជម្រះជឿជាក់ថា បុគ្គលនោះត្រូវបានគេជូនដំណឹងរួចហើយអំពីបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ និង សិទ្ធិរបស់ខ្លួន[143] ហើយក៏កំណត់កាលបរិច្ឆេទសម្រាប់សវនាការបញ្ជាក់បន្ថែមពីបទចោទប្រកាន់[144]។

៧៩. ដូចដែលចៅក្រមអង្គបុរេជំនុំជម្រះ Fernández de Gurmendi បានកត់សម្គាល់៖ "[ការបង្ហាញខ្លួនលើកដំបូង] គឺមិនមែនជាការជំនុំជម្រះទេ ហើយក៏មិនមែនជាសវនាការសម្រាប់បញ្ជាក់អ្វីឡើយ។ គ្មានការទទួលយកភស្តុតាង ហើយក៏គ្មានការបង្ហាញភស្តុតាងអ្វីនោះទេ។ បញ្ហាអំពីភាពមានពិរុទ្ធ ឬ

---

[141] ក្របខ័ណ្ឌគតិយុត្តរបស់តុលាការ ICC មិនអាចយកមកដាក់បញ្ចូលទាំងស្រុងនៅក្នុងបរិបទ អ.វ.ត.ក. ឡើយ។ ដូចគ្នានឹងតុលាការ STL តុលាការ ICTY និង តុលាការ ICTR ដែរ តុលាការ ICC ឆ្លុះបញ្ចាំងនូវគោលការណ៍ច្បាប់ខំមិនឡូ។ ឧទាហរណ៍ រដ្ឋអាជ្ញាដឹកនាំការស៊ើបអង្កេត និង អាចស្តាប់ចម្លើយជនសង្ស័យ។ មាត្រា ៤២(១) មាត្រា ៥៤(៣)(ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូម។

[142] មាត្រា ៦០(១) នៃលក្ខន្តិកៈទីក្រុងរ៉ូម។ ដូចដែរវិធាន ១២១(១) នៃវិធានស្តីពីនីតិវិធី និង ភស្តុតាងរបស់តុលាការ ICC ចែងថា៖ "ជនដែលជាកម្មវត្ថុនៃដីកាបង្គាប់ឲ្យចាប់ខ្លួន ឬ ដីកាកោះឲ្យចូលបង្ហាញខ្លួន អនុលោមតាមមាត្រា ៥៨ *ត្រូវបង្ហាញខ្លួននៅចំពោះមុខ* អង្គបុរេជំនុំជម្រះ ភ្លាមនៅពេលទៅដល់តុលាការ ដោយមានវត្តមានរដ្ឋអាជ្ញា"។

[143] មាត្រា ៦០(១) នៃលក្ខន្តិកៈទីក្រុងរ៉ូម។ *សូមមើលផងដែរ* រឿងក្តី *រដ្ឋអាជ្ញា* តទល់នឹង *Ruto និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ICC-01/09-01/11 សេចក្តីសម្រេចលើញត្តិរបស់អ្នកតំណាងរបស់អ្នកដាក់ពាក្យសុំជាជនរងគ្រោះ ដើម្បីចូលរួមក្នុងកិច្ចដំណើរការនីតិវិធីបង្ហាញខ្លួនលើកដំបូង អង្គបុរេជំនុំជម្រះ II ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ ២០១១ កថាខណ្ឌ ៦។ រឿងក្តី *រដ្ឋអាជ្ញា* តទល់នឹង *Ntaganda* សំណុំរឿងលេខ ICC-01/04-02/06 សេចក្តីសម្រេចលើការកំណត់កាលបរិច្ឆេទសម្រាប់ការចូលបង្ហាញខ្លួនលើកដំបូង និង បញ្ហាពាក់ព័ន្ធនានា អង្គបុរេជំនុំជម្រះ II ចុះថ្ងៃទី ២២ ខែមីនា ឆ្នាំ ២០១៣ កថាខណ្ឌ ៩។ រឿងក្តី *រដ្ឋអាជ្ញា* តទល់នឹង *Kony និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ICC-02/04-01/05 សេចក្តីសម្រេចលើការកំណត់កាលបរិច្ឆេទសម្រាប់ការចូលបង្ហាញខ្លួនលើកដំបូងរបស់ Dominic Ongwen និង កាលបរិច្ឆេទសម្រាប់កិច្ចប្រជុំរៀបចំសវនាការ អង្គបុរេជំនុំជម្រះ II ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ ២០១៥ កថាខណ្ឌ ៦។

[144] វិធាន ១២១(១) នៃវិធានស្តីពីនីតិវិធី និង ភស្តុតាងរបស់តុលាការ ICC។

ក៏ភាពគ្មានទោសក៏នឹងមិនមានដែរ"[145]។ *បន្ទាប់ពីការចូលបង្ហាញខ្លួនលើកដំបូងដោយផ្ទាល់រួចមក* រឿងក្តីត្រូវបន្តដំណើរការនីតិវិធីទៅតាមមាត្រា ៦១ ដែលចែងអំពីសវនាការបញ្ជាក់បទចោទប្រកាន់ ដែលតាមពិត អាចត្រូវបានធ្វើឡើង *ដោយកំបាំងមុខ* អាស្រ័យនឹងកាលៈទេសៈជាក់លាក់មួយចំនួន[146]។

៨០. សហចៅក្រមស៊ើបអង្កេត Harmon មិនគោរពតាមបទប្បញ្ញត្តិពាក់ព័ន្ធទាំងឡាយនៃលក្ខន្តិកៈទីក្រុងរ៉ូម និង វិធានស្តីពីនីតិវិធី និង ភស្តុតាងរបស់តុលាការ ICC។ ទាំងលក្ខន្តិកៈទីក្រុងរ៉ូម និង វិធានស្តីពីនីតិវិធី និង ភស្តុតាងរបស់តុលាការ ICC មិនអនុញ្ញាតឲ្យការបង្ហាញខ្លួនលើកដំបូង ត្រូវបានធ្វើឡើង *ដោយកំបាំងមុខ* នោះឡើយ។ ក្នុងការយកវិធាននីតិវិធីរបស់តុលាការ ICC ដែលមិនពាក់ព័ន្ធមកអនុវត្តនៅ អ.វ.ត.ក. បែបនេះ សហចៅក្រមស៊ើបអង្កេត Harmon បានប្រព្រឹត្តកំហុសផ្នែកអង្គច្បាប់។

### ៤. ដើម្បីជា *ទឡ្ហីករណ៍* សន្មតថា ក្របខ័ណ្ឌគតិយុត្តរបស់ អ.វ.ត.ក. អនុញ្ញាតឲ្យមានការដាក់ក្រោមការពិនិត្យ *ដោយកំបាំងមុខ* លោក មាស មុត មិនបានលះបង់សិទ្ធិរបស់ខ្លួនក្នុងការមានវត្តមាននៅក្នុងការបង្ហាញខ្លួនលើកដំបូងដែលមានសុពលភាពនោះឡើយ

៨១. សហចៅក្រមស៊ើបអង្កេត Harmon បានសន្និដ្ឋានថា លោក មាស មុត ត្រូវបាន "ជូនដំណឹងអំពីគម្រោងពេលសម្រាប់ការបង្ហាញខ្លួនលើកដំបូងរបស់គាត់ ... ប៉ុន្តែមានចេតនា និង មានបំណងមិនចូលបង្ហាញខ្លួន ដូច្នេះហើយ បានន័យថាគាត់លះបង់សិទ្ធិមានវត្តមានរបស់ខ្លួន"[147]។ សហចៅក្រមស៊ើបអង្កេត Harmon បានបកស្រាយមិនត្រឹមត្រូវនូវសេចក្តីជូនដំណឹងស្តីអំពីការមិនទទួលស្គាល់ដីកាកោះ[148] ថាជាការលះបង់សិទ្ធិក្នុងការមានវត្តមាន។

៨២. លោក មាស មុត មិនបានលះបង់សិទ្ធិរបស់ខ្លួនក្នុងការមានវត្តមាននៅឯការបង្ហាញខ្លួនលើកដំបូង (ដែលធ្វើឡើងដោយមានសុពលភាព) តាមរយៈសេចក្តីជូនដំណឹងអំពីការមិនទទួលស្គាល់ដីកាកោះ

---

[145] *រឿងក្តីរដ្ឋអាជ្ញា* តទល់នឹង *Blé Goudé* សំណុំរឿងលេខ ICC-02/11-02/11 ប្រតិចារឹកនៃការចូលបង្ហាញខ្លួនលើកដំបូង អង្គបុរេជំនុំជម្រះ I ចុះថ្ងៃទី ២៧ ខែមីនា ឆ្នាំ ២០១៤ ទំព័រ ៤-៥។

[146] មាត្រា ៦១(២) នៃលក្ខន្តិកៈទីក្រុងរ៉ូម។

[147] កថាខណ្ឌ ៥៩ នៃដីកាសម្រេចរងការជំទាស់។

[148] សេចក្តីសម្រេចចិត្តរបស់ មាស មុត ទាក់ទងនឹងដីកាកោះ។ សេចក្តីជូនដំណឹងរបស់ មាស មុត។

ឡើយ។ ការជូនដំណឹងអំពីការមិនទទួលស្គាល់ដីកាកោះ កត់ត្រាទុកនូវការជំទាស់របស់លោក មាស មុត ទៅនឹងសុពលភាពនៃដីកាកោះ[149]។ គោលបំណងចម្បងនៃការធ្វើកំណត់ត្រា គឺដើម្បីរក្សាទុកនូវកំហុសនានាសម្រាប់បណ្តឹងឧទ្ធរណ៍ ពីព្រោះថា "ប្រសិនបើវាមិនមាននៅក្នុងកំណត់ត្រាទេ នោះគឺមានន័យថាគ្មានអ្វីបានកើតឡើងឡើយ"[150]។ ការអនុវត្តសិទ្ធិរបស់លោក មាស មុត ក្នុងការធ្វើកំណត់ត្រា មិនអាចត្រូវបានបកស្រាយថា ជាការលះបង់សិទ្ធិជាមូលដ្ឋានគ្រឹះរបស់គាត់ក្នុងការមានវត្តមាននៅក្នុងការបង្ហាញខ្លួនលើកដំបូង ដែលធ្វើឡើងដោយមានសុពលភាពនោះឡើយ ពោលគឺធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត *ទាំងពីររូប*។

៨៣. សិទ្ធិមានវត្តមាននៅឯការបង្ហាញខ្លួនលើកដំបូង គឺជាកម្មសិទ្ធិរបស់លោក មាស មុត តែម្នាក់គត់ ហើយមានតែគាត់ម្នាក់គត់ដែលអាចលះបង់សិទ្ធិនេះបាន។ ការលះបង់សិទ្ធិណាមួយ អាចធ្វើឡើងដោយយថាភូត ឬ ដោយវាទរហិត ប៉ុន្តែត្រូវតែមានលក្ខណៈច្បាស់លាស់ និង គ្មានមន្ទិលសង្ស័យ[151]។ គ្មានការលះបង់សិទ្ធិបែបនេះ នៅក្នុងសេចក្តីជូនដំណឹងស្តីពីការមិនទទួលស្គាល់ដីកាកោះឡើយ។ កាលណាការលះបង់សិទ្ធិមានសណ្ឋានជាវាទរហិត លោក មាស មុត ត្រូវអាចប្រមើលដឹងជាមុនដោយសមហេតុផលនូវផលវិបាកនៃការខកខានមិនបានចូលបង្ហាញខ្លួននោះ[152]។ ក្នុងការធ្វើកំណត់ត្រានៃការជំទាស់របស់គាត់ទៅនឹងដីកាកោះដែលគ្មានសុពលភាពនោះ លោក មាស មុត មិនអាច

---

[149] *សូមមើលឧទាហរណ៍* សេចក្តីជូនដំណឹងរបស់ មាស មុត។

[150] *Protect Our Water និង អ្នកផ្សេងទៀត* តទល់នឹង *County of Merce,* 110 Cal. App. 4th 362, 364 (ឆ្នាំ ២០០៣)។ *សូមមើលផងដែរ* គោលការណ៍ទីក្រុង Siracusa ស្តីពីបទប្បញ្ញត្តិកំណត់ព្រំដែន និង បដិប្បញ្ញត្តិនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ គណៈកម្មាធិការសិទ្ធិមនុស្ស *សេចក្តីជូនដំណឹងដោយផ្ទាល់មាត់ ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ១៩៨៤ ពីតំណាងអចិន្ត្រៃយ៍នៃប្រទេសហូឡង់ ផ្ញើជូនការិយាល័យអង្គការសហប្រជាជាតិក្នុងទីក្រុងហ្សឺណែវ ដោយចំណារធ្វើជូនអគ្គលេខាធិការ* ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ១៩៨៤ ឯកសារ អ.ស.ប. លេខ E/CN.4/1985/4 កថាខណ្ឌ ៧០ ដែលចែងថា "កំណត់ហេតុគ្រប់ជ្រុងជ្រោយមួយនៃកិច្ចដំណើរការនីតិវិធី ត្រូវតែរក្សាទុកនៅក្នុងគ្រប់ករណីទាំងអស់"។

[151] រឿងក្តី *Poitrimol* តទល់នឹង *ប្រទេសបារាំង តុលាការសិទ្ធិមនុស្សអឺរ៉ុប* សំណុំរឿងលេខ 14032/88 ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ កថាខណ្ឌ ៣១។ *សូមមើលផងដែរ* រឿងក្តី*រដ្ឋអាជ្ញា* តទល់នឹង *Nahimana និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ICTR-99-59-A សាលក្រម ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០០៧ កថាខណ្ឌ ១០៩។ កថាខណ្ឌ ១៤.១ នៃសេចក្តីសម្រេចលើរឿងក្តី *Mbenge*។

[152] រឿងក្តី *Sejdovic* តទល់នឹង *ប្រទេសអ៊ីតាលី* កថាខណ្ឌ ៨៧ (សេចក្តីយោងខាងក្នុងត្រូវបានលុបចេញ)៖ "មុនពេលជនចាប់ចោទតាមរយៈអំពើរបស់គាត់ អាចត្រូវបានបកស្រាយថា បានលះបង់សិទ្ធិដ៏សំខាន់ អនុលោមតាមមាត្រា ៦ នៃអនុសញ្ញា [ECHR] ត្រូវបង្ហាញថា គាត់អាចប្រមើលដឹងជាមុនយ៉ាងសមហេតុផលថា តើអ្វីជាផលវិបាកនៃអំពើរបស់ខ្លួន"។

បានប្រមើលដឹងជាមុនដោយសមហេតុផលថា គាត់នឹងត្រូវបានចាត់ទុកថាបាន លះបង់សិទ្ធិរបស់ខ្លួន ក្នុងការចូលបង្ហាញខ្លួននៅឯការបង្ហាញខ្លួនលើកដំបូងដែលមានសុពលភាព ហើយនឹងត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* បែបនេះឡើយ។ សហចៅក្រមស៊ើបអង្កេត Harmon បានបកស្រាយខុសទៅលើការជូនដំណឹងអំពីការមិនទទួលស្គាល់ដីកាកោះ។ គាត់បានឈានទៅរកការសន្និដ្ឋានមិនត្រឹមត្រូវយ៉ាងច្បាស់ក្រឡែត ដែលជាកំហុសផ្នែកអង្គហេតុ។

**៥. ដើម្បីជា*ទឡ្ហីករណ៍* សន្មតថា អ.វ.ត.ក. អនុញ្ញាតឱ្យមានការដាក់ក្រោមការពិនិត្យ *ដោយកំបាំងមុខ* សហចៅក្រមស៊ើបអង្កេត Harmon មិនបានចាត់គ្រប់វិធានការសមស្របទាំងអស់ ដើម្បីធានាឱ្យមានការបង្ហាញខ្លួនរបស់លោក មាស មុត ឡើយ**

៨៤. សហចៅក្រមស៊ើបអង្កេត Harmon បានសន្និដ្ឋានថា គាត់បានចាត់គ្រប់វិធានការសមស្របទាំងអស់ដើម្បីធានាឱ្យមានការបង្ហាញខ្លួនលើកដំបូងដោយផ្ទាល់របស់លោក មាស មុត[153]។ ការពិនិត្យឡើងវិញទៅលើស្ថានភាពរបស់លោក មាស មុត និង ដីកាសម្រេចរងការជំទាស់បង្ហាញឱ្យឃើញនូវភាពមិនសមទំនងនៃសេចក្ដីសន្និដ្ឋាននេះ។

៨៥. កាលណាកិច្ចដំណើរការនីតិវិធីត្រូវបានអនុញ្ញាតឱ្យធ្វើឡើង *ដោយកំបាំងមុខ* នោះគ្រប់វិធានការសមស្របទាំងអស់ត្រូវតែអនុវត្ត ដើម្បីធានាឱ្យមានការបង្ហាញខ្លួនរបស់ជនជាប់ចោទ *កាលណាជនជាប់ចោទបានរត់គេចខ្លួន ឬ រកមិនឃើញ*[154]។ នៅទីនេះ សហចៅក្រមស៊ើបអង្កេត Harmon ដឹងកន្លែងដែលលោក មាស មុត ស្នាក់នៅ[155] និង មិនចាត់ទុកថា លោក មាស មុត លាក់ខ្លួនទេ[156]។ លោក មាស មុត មិនបានរត់គេចខ្លួន ហើយអាចត្រូវបានរកឃើញនោះ។ គាត់មិនអាចត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ឡើយ។

៨៦. មេធាវីការពារក្ដីពិចារណាទៅលើវិធានការដែលសហចៅក្រមស៊ើបអង្កេត Harmon យកមកធ្វើជាសំអាងថា៖

---

[153] កថាខណ្ឌ ៦៦ នៃដីកាសម្រេចរងការជំទាស់។

[154] *សូមមើលឧទាហរណ៍* មាត្រា ៦១(២) នៃលក្ខន្តិកៈទីក្រុងរ៉ូម។

[155] កថាខណ្ឌ ១២ នៃដីកាសម្រេចរងការជំទាស់។

[156] *ដូចខាងលើ* កថាខណ្ឌ ៦៦។

ក. រវាងថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០១៤ និង កាលបរិច្ឆេទនៃដីកាសម្រេចរងការជំទាស់ (នៅថ្ងៃទី ០៣ ខែមីនា ឆ្នាំ ២០១៥) គាត់បានទាក់ទងនឹងនគរបាលយុត្តិធម៌ ដោយស្នើសុំការធ្វើបច្ចុប្បន្នភាពទៅលើការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន *ជនត្រូវចោទម្នាក់ទៀត*[157]។

ខ. រវាងថ្ងៃទី ១១ និង ថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ ២០១៤ *នៅមុនពេលប្រគល់ដីកាកោះឱ្យលោក មាស មុត ដើម្បីបង្ហាញខ្លួនលើកដំបូង*[158] *និង ដីកាបង្គាប់ឱ្យនាំខ្លួនត្រូវបានចេញ*[159] សហចៅក្រមស៊ើបអង្កេត Harmon និង បុគ្គលិករបស់គាត់ បានបើកកម្មវិធីផ្សព្វផ្សាយចំនួនប្រាំបួន នៅក្នុងតំបន់នានាតាមការណែនាំរបស់នគរបាលយុត្តិធម៌ រាប់បញ្ចូលទាំងស្រុកដែលលោក មាស មុត រស់នៅផងដែរ[160]។

គ. ក្នុងការឆ្លើយតបទៅនឹងសេចក្តីបញ្ជាក់របស់នគរបាលយុត្តិធម៌ដែលថា សេចក្តីសម្រេចស្តីអំពីការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន គឺស្ថិតនៅលើគណៈកម្មការសន្តិសុខប្រចាំ អ.វ.ត.ក. នៅថ្ងៃទី ៣០ ខែមករា ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេត Harmon បានសរសេរលិខិតទៅកាន់ប្រធានគណៈកម្មការថា លោក មាស មុត នឹងត្រូវដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ *ដោយកំបាំងមុខ* ប្រសិនបើគាត់មិនបានចូលមកបង្ហាញខ្លួន ឬក៏ ដីកាបង្គាប់ឱ្យនាំខ្លួនមិនត្រូវបានអនុវត្ត នៅត្រឹមថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ២០១៥ ទេនោះ[161]។

ឃ. នៅថ្ងៃទី ០៣ ខែមីនា ឆ្នាំ ២០១៥ ដោយមិនទទួលបានចម្លើយតបទៅនឹងលិខិតរបស់គាត់ ហើយដីកាបង្គាប់ឱ្យនាំខ្លួនក៏មិនត្រូវបានអនុវត្ត សហចៅក្រមស៊ើបអង្កេត Harmon ក៏បានចេញដីកាសម្រេចរងការជំទាស់នេះតែម្តង។

៨៧. សហចៅក្រមស៊ើបអង្កេត Harmon បានចាត់វិធានការតែមួយគត់ នៃវិធានការទាំងឡាយ (គឺការសរសេរលិខិតជូនទៅគណៈកម្មការសន្តិសុខប្រចាំ អ.វ.ត.ក.) *បន្ទាប់ពី* ពេលដែលប្រគល់ដីកាកោះ

---

[157] *ដូចខាងលើ* កថាខណ្ឌ ៦១។

[158] ដីកាកោះចេញនៅថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០១៤ និង បានប្រគល់ជូនលោក មាស មុត នៅថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤ នៅទីលំនៅរបស់គាត់។ *សូមមើល* ដីកាកោះឱ្យបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ A66។ កំណត់ហេតុនៃការប្រគល់ដីកាកោះ ចុះថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ A66/1។

[159] ដីកាបង្គាប់ឱ្យនាំខ្លួន ចេញនៅថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ២០១៤។ ដីកាបង្គាប់ឱ្យនាំខ្លួន ចុះថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ C1។

[160] កថាខណ្ឌ ៦២ នៃដីកាសម្រេចរងការជំទាស់។

[161] *ដូចខាងលើ* កថាខណ្ឌ ៦៣-៦៥។ *សូមមើលផងដែរ* លិខិតរបស់ ស.ច.ស.អ. ផ្ញើជូនឯកឧត្តម ឯម សំអាន ចុះថ្ងៃទី ៣០ ខែមករា ឆ្នាំ ២០១៥ ឯកសារ D127។

ជូនលោក មាស មុត ហើយដីកាបង្គាប់ឲ្យនាំខ្លួនត្រូវបានចេញ។ សហចៅក្រមស៊ើបអង្កេត Harmon បានពឹងផ្អែកដោយមិនត្រឹមត្រូវទៅលើកិច្ចនានា ដែលត្រូវបានអនុវត្តនៅក្នុងរឿងក្តីមួយផ្សេងទៀត ដើម្បីធ្វើឲ្យឃើញថាត្រូវនឹងរឿងក្តីរបស់លោក មាស មុត។ វាជាការមិនត្រឹមត្រូវទាល់តែសោះក្នុងការប្រើប្រាស់ដំណើរការនៅក្នុងរឿងក្តីមួយ ដើម្បីសន្និដ្ឋានអង្គហេតុ និង លទ្ធផលនៅក្នុងរឿងក្តីមួយផ្សេងទៀតនោះ។

៨៨. វិធានការតែមួយគត់ដែលសហចៅក្រមស៊ើបអង្កេត Harmon បានអនុវត្តទាក់ទិនដោយផ្ទាល់ទៅនឹង លោក មាស មុត នោះ គឺការសរសេរលិខិតទៅគណៈកម្មការសន្តិសុខប្រចាំ អ.វ.ត.ក. ស្តីពីការខកខានរបស់នគរបាលយុត្តិធម៌មិនអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួន[162]។ គ្មានការចង្អុលបង្ហាញនៅក្នុងវិធានផ្ទៃក្នុងថា ការធ្វើលិខិតនេះគឺជាពឹងអាស្រ័យតែមួយគត់របស់សហចៅក្រមស៊ើបអង្កេត Harmon ឡើយ។

៨៩. សហចៅក្រមស៊ើបអង្កេតអាចធ្វើដំណើរទៅស្រុកដែលលោក មាស មុត រស់នៅ ដើម្បីចាត់ចែងការបង្ហាញខ្លួនលើកដំបូងដោយផ្ទាល់តែម្តង។ សហចៅក្រមស៊ើបអង្កេត Harmon ធ្លាប់បានធ្វើដំណើរទៅស្រុកដែលលោក មាស មុត រស់នៅ ដើម្បីធ្វើកម្មវិធីផ្សព្វផ្សាយ[163]។ ដូច្នេះ គ្មានហេតុផលដែលថាសហចៅក្រមស៊ើបអង្កេតទាំងពីរនាក់មិនអាចវិលត្រឡប់ទៅកន្លែងនោះវិញ ដើម្បីអនុវត្តការបង្ហាញខ្លួនលើកដំបូងឡើយ[164]។

៩០. សហចៅក្រមស៊ើបអង្កេត អាចធ្វើបណ្តឹងទៅកាន់អគ្គព្រះរាជអាជ្ញានៃសាលាឧទ្ធរណ៍អំពីនគរបាលយុត្តិធម៌។ នគរបាលយុត្តិធម៌គឺជាមន្ត្រីជំនួយរបស់ អ.វ.ត.ក.៖ សមាជិកនៃនគរបាលយុត្តិធម៌ ឬ កងរាជអាវុធហត្ថកម្ពុជា ដែលត្រូវបានចាត់តាំងឲ្យបំពេញការងារនៅ អ.វ.ត.ក.[165]។ នគរបាល

---

[162] គណៈកម្មការសន្តិសុខប្រចាំ អ.វ.ត.ក. គឺជាគណៈកម្មការទំនាក់ទំនងរវាង អ.វ.ត.ក. និង នគរបាលជាតិកម្ពុជា។ *សូមមើល ឧទាហរណ៍* វិធានសម្រាប់គ្រប់គ្រងការឃុំខ្លួនជនដែលរង់ចាំការជំនុំជម្រះ ឬ ប្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធាន ១២(៧) នៅក្នុងផ្នែកពាក់ព័ន្ធ៖ "ក្នុងករណីបន្ទាន់ ប្រធានមន្ទីរឃុំឃាំង អាចស្នើសុំជំនួយពីនគរបាលជាតិតាមរយៈគណៈកម្មការសន្តិសុខប្រចាំ អ.វ.ត.ក."។

[163] កថាខណ្ឌ ១២ នៃដីកាសម្រេចរងការជំទាស់។

[164] វិធាន ៥៥ នៃវិធានផ្ទៃក្នុង អនុញ្ញាតឲ្យសហចៅក្រមស៊ើបអង្កេតចុះដល់ទីកន្លែងដើម្បីបំពេញកិច្ចស៊ើបសួរដល់ទីកន្លែង។ ការស្តាប់យកចម្លើយជនសង្ស័យ ឬ ជនត្រូវចោទ មិនត្រូវបានដកចេញដោយច្បាស់លាស់ និង ដោយតុណ្ហីភាពពីវិសាលភាពនៃកិច្ចស៊ើបអង្កេតទាំងនេះឡើយ។

[165] វិធាន ១៥(១) នៃវិធានផ្ទៃក្នុង។ សន្ទានុក្រមនៃវិធានផ្ទៃក្នុង និយមន័យនៃពាក្យ *"នគរបាលយុត្តិធម៌"* ទំព័រ ៨៤។

យុត្តិធម៌កម្ពុជាស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍[166]។ អនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា រាល់កំហុសទាំងឡាយដែលប្រព្រឹត្តដោយនគរបាលយុត្តិធម៌ ត្រូវតែរាយការណ៍ដោយព្រះរាជអាជ្ញា ឬ ដោយចៅក្រមស៊ើបសួរ ដល់អគ្គព្រះរាជអាជ្ញាដើម្បីចាត់វិធានការ[167]។

៩១. ប្រសិនណាដីកាបង្គាប់ឱ្យនាំខ្លួន ត្រូវបានប្រគល់ទៅឱ្យនគរបាលយុត្តិធម៌រួចហើយ ដើម្បីយកទៅអនុវត្ត នោះនគរបាលយុត្តិធម៌ត្រូវតែអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួននេះ ឬ "ផ្តល់ព័ត៌មានដល់សហចៅក្រមស៊ើបអង្កេត អំពីបញ្ហាលំបាកដែលខ្លួនជួបប្រទះក្នុងការបំពេញបេសកកម្មរបស់ខ្លួន"[168]។ គ្មានការចង្អុលបង្ហាញថា សហចៅក្រមស៊ើបអង្កេត Harmon បានទទួលរបាយការណ៍ពីនគរបាលយុត្តិធម៌អំពីបញ្ហាលំបាកបែបណាឡើយ។ សេចក្តីបញ្ជាក់ពីអ្នកតំណាងនគរបាលយុត្តិធម៌ដែលថា គណៈកម្មការសន្តិសុខប្រចាំ អ.វ.ត.ក. ជាអ្នកធ្វើសេចក្តីសម្រេចចុងក្រោយ ទាក់ទិននឹងការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួននោះ[169] គឺមិនមែនជារបាយការណ៍ផ្លូវការទេ។ គ្មានការចង្អុលបង្ហាញថា មានសហចៅក្រមស៊ើបអង្កេតណាម្នាក់ បានដាក់បណ្តឹងផ្លូវការទៅអគ្គព្រះរាជអាជ្ញានៃសាលាឧទ្ធរណ៍ឡើយ។

៩២. គ្រប់វិធានការសមស្រប *ទាំងអស់* ត្រូវតែបានយកមកអនុវត្ត នៅមុនពេលចៅក្រមអាចធ្វើដំណើរការនីតិវិធី *ដោយកំបាំងមុខ*។ ការខកខានមិនបានចាត់វិធានការសមស្របទាំងអស់ ដើម្បីធានាឱ្យមានការបង្ហាញខ្លួនរបស់លោក មាស មុត នោះលោក មាស មុត មិនអាចត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ឡើយ។ ធ្វើរបៀបនេះគឺជាការសន្និដ្ឋានមិនត្រឹមត្រូវយ៉ាងច្បាស់ក្រឡែតទៅលើអង្គហេតុ និង ជាកំហុសអង្គច្បាប់។

## ៦. សេចក្តីសន្និដ្ឋាន

៩៣. វិធាន ៥៧ មិនអនុញ្ញាតឱ្យដាក់ជនសង្ស័យឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ឡើយ។ អត្ថន័យធម្មតានៃវិធាន ៥៧ តម្រូវឱ្យមានការបង្ហាញខ្លួនលើកដំបូងដោយផ្ទាល់។ គ្មានភាពចន្លោះប្រហោង ភាពមិនច្បាស់លាស់ ឬ ភាពមិនស៊ីសង្វាក់គ្នា នៅក្នុងវិធាន ៥៧ ដែលតម្រូវឱ្យពិនិត្យ

---

[166] មាត្រា ៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

[167] *ដូចខាងលើ* មាត្រា ៦៥។

[168] វិធាន ៤៥(៣) នៃវិធានផ្ទៃក្នុង។ វិធាននេះមានលក្ខណៈដូចគ្នានឹងមាត្រា ១៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

[169] *សូមមើល* កថាខណ្ឌ ២៤ នៃដីកាសម្រេចរងការជំទាស់។

មើលវិធាននីតិវិធីកម្ពុជា ឬ អន្តរជាតិឡើយ។ វិធាននីតិវិធីកម្ពុជា និង អន្តរជាតិមិនគាំទ្រចំណាត់ការរបស់សហចៅក្រមស៊ើបអង្កេត Harmon ឡើយ។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា តម្រូវឱ្យមានការបង្ហាញខ្លួនលើកដំបូងដោយផ្ទាល់។ វិធានអន្តរជាតិនានាទាក់ទងនឹងការជំនុំជម្រះ *ដោយកំបាំងមុខ* គឺមិនពាក់ព័ន្ធ ហើយកាលណាការជំនុំជម្រះបែបនេះត្រូវបានអនុញ្ញាត នោះតម្រូវឱ្យជនជាប់ចោទចូលបង្ហាញខ្លួនលើកដំបូងជាមុនសិន។ ទោះបីជាការដាក់ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ត្រូវបានអនុញ្ញាតនៅ អ.វ.ត.ក. ក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេត Harmon មិនអាចដាក់លោក មាស មុត ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* បែបនេះដែរ។ លោក មាស មុត មិនបានរត់គេច ឬ គេចខ្លួនទៅណាឡើយ។ សហចៅក្រមស៊ើបអង្កេត Harmon ខកខានមិនបានចាត់វិធានការសមស្របទាំងអស់ ដើម្បីធានាឱ្យមានការបង្ហាញខ្លួនលើកដំបូងរបស់លោក មាស មុត នៅមុនពេលចេញដីកាសម្រេចរងការជំទាស់នេះ។ សហចៅក្រមស៊ើបអង្កេត Harmon បានបំពេញកិច្ច *ហួសពីសមត្ថកិច្ច* មានកំហុសអង្គច្បាប់ និង បានឈានទៅរកសេចក្តីសន្និដ្ឋានមិនត្រឹមត្រូវយ៉ាងច្បាស់ក្រឡែត ដែលជាកំហុសអង្គហេតុ។ ដីកាសម្រេចរងការជំទាស់នេះគ្មានសុពលភាព និង ត្រូវតែចាត់ជាមោឃៈ។

**អាស្រ័យហេតុនេះ** យោងតាមសំអាងហេតុទាំងអស់ដែលបានបញ្ជាក់ជូនខាងលើ មេធាវីការពារក្តីសូមគោរពស្នើឱ្យអង្គជំនុំជម្រះមេត្តា៖

ក. **ទទួលយក** បណ្តឹងឧទ្ធរណ៍នេះ។

ខ. **សម្រេច** ថា សហចៅក្រមស៊ើបអង្កេត Harmon មានកំហុសនៅក្នុងការចេញដីកាសម្រេចរងការជំទាស់នេះដោយឯកតោភាគី និង/ឬ

គ. **សម្រេច** ថា សហចៅក្រមស៊ើបអង្កេត Harmon មានកំហុសនៅក្នុងការដាក់លោក មាស មុត ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ហើយនិង

ឃ. **ចាត់ទុកជាមោឃៈ** នូវដីកាសម្រេចរងការជំទាស់នេះ។

សូមអង្គបុរេជំនុំជម្រះមេត្តាទទួលយកបណ្តឹងឧទ្ធរណ៍នេះដោយក្តីគោរព។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០១៥។

សហមេធាវីការពារក្តីលោក មាស មុត

| | |
|---|---|
| អាង ឧត្តម | Michael G. KARNAVAS |